**ឧបសោសង្ហា**

# សាធារណរដ្ឋខ្មែរ-បដិវត្តន៏ពុំអាចរកបាន?

---

វរសញ្ញករ នៃ សាធារណរដ្ឋខ្មែរ

## ពិនិត្យឡើងវិញនូវព្រឹត្តិការណ៏សំខាន់ៗមាននៅក្នុង

## ប្រវត្តិសាស្រ្តខ្មែរ

# ភាគទី១ និង ទី២

**មាតិកាផ្សេង**


**ភាគទី១** ........................................................ 2
**សេចក្តីផ្តើម** .................................................... 3
**ប្រភព នៃពាក្យ កុសាំងស៊ិន** ...................... 13
**កត្តា នៃ ការរលំ សម្តេចសីហនុ** .................. 16
**កត្តា ផ្ទៃក្នុង** .................................................. 17
**កត្តា អន្តរជាតិ : លើឋាន កិច្ចការទូត** ....... 48
**កត្តាគិតិយុត្ត នៃការទំលាក់ ន. សីហនុ** ..... 62
**អភិក្រម នៃការទំលាក់ នរោត្តម សីហនុ** .. 71

ភាគទី២ .......................................................... 86
វឌ្ឍកម្ម នៃកម្លាំងប្រឆាំងសីហនុ................ 87
ផែនការកលយុទ្ធ ........................................... 112
វដ្តប្រហារស្របច្បាប់ .................................... 123
មានបន្ត ក្នុងភាគទី៣ ................................ 138

# ភាគទី១

# សេចក្តីផ្តើម

ក្រោយសង្គ្រាមលោកទី២ នៅទសវត្សរ៍ ៤៥ នៅស្រុកខ្មែរ មាន ចរន្តនយោបាយធំពីរ: រាជនិយមធិបតេយ្យ និង លទ្ធិប្រជាធិបតេយ្យ-ជាតិនិយម។ តែនៅក្នុងពិភពលោក មានចរន្តធំមួយ គឺ ការលុបបំបាត់ ឬ ប្រឆាំងនឹង អាណានិគមនិយម។ តែ មហាអំណាចពីរ ដែល ជាអ្នកឈ្នះសង្គ្រាម លើ របបណាស៊ី នៅអឺរ៉ុប គឺ សហរដ្ឋអាមេរិក និង សហភាពសូវៀត បន្តធ្វើសង្គ្រាម រវាងគ្នា ដែលគេឲឈ្មោះ ថា ‹សង្គ្រាមត្រជាក់› នាំបង្កើត ស្នគ្រក្រុម (bloc) ប្រឆាំងគ្នាពីរ មួយ ជា លោកសេរី ដែលមាន សហរដ្ឋអាមេរិក ជាអ្នកកាន់ទង់ មួយទៀត ជា លោកកុម្មុយនិស្ត ដែលមាន សហភាពសូវៀត ជា ប្រមុខ។ ស្នគ្រក្រុមទាំងពីរ ប្រឆាំងនឹង អាណានិគមនិយមដូចគ្នា ហើយ ជួយដល់ប្រជាជនទាំងឡាយ ដែលរស់នៅ ក្រោមការត្រួតត្រា នៃ អាណានិគមនិយម ឲរំដោះខ្លួនចេញពី គំនាបនោះ។ លោកសេរី ស្នើឲមាន ការកែទម្រង់ នយោបាយដឹកនាំ ដោយ ជ្រើសយក របបលទ្ធិប្រជាធិបតេយ្យសេរី តាមការបោះឆ្នោត រីឯ លោកកុម្មុយនិស្ត វិញ ធ្វើអនុសាស ឲជ្រើសរើស ផ្លូវបដិវត្តហិង្សា រំដោះខ្លួនចេញពី អាណានិគមនិយម និង តស៊ូ វណ្ណៈ រំលាយចោល នូវវណ្ណៈសក្តិភូមិចាស់ច្រែះ ដើម្បី

កសាងសង្គមថ្មី គឺ សង្គម សង្គមនិយម ឬ កុម្មុយនិស្ត។ នៅពេលនោះ ប្រទេសទាំងឡាយ ជាប់ពាក់ព័ន្ធនឹង បញ្ហានោះ មានការបារម្ភ ក្នុងជម្រើស រំដោះខ្លួន ចេញពីគំនាប អាណានិគមនិយម និង ស្វែងរកផ្លូវកសាងប្រទេស តាមទំនើបនិយម។ ជ័យជំនះ បក្ស ចិនកុម្មុយនិស្ត លើក បក្ស គួមិងតាង និង ការប្រកាស សាធារណរដ្ឋចិនប្រជាមានិត នៅឆ្នាំ ១៩៤៩ ជាទិន្នការណ៍ថ្មីមួយនៃពិភពលោក ជាពិសេស ចំពោះប្រទេសយៀកណាម ដែលកំពុង មានសង្គ្រាម ទាមទារ ឯករាជ្យពីបារាំង ដឹកនាំដោយ បក្សកុម្មុយនិស្តយួន។ តែនៅពេលនោះ ប្រទេសមួយចំនួន មានទាំង ចិនកុម្មុយនិស្ត នាំគ្នា បង្កើតចលនា នៃ ផ្លូវទីពាមួយ ដែលជា ចលនា នៃ ប្រទេសមិនចូលក្នុង ស្ទគ្របក្ស លោក សេរី និង លោកកុម្មុយនិស្ត។ ចលនានោះ មានទម្រង់តែមួយពិត តែ គ្មាន ឯកភាពនៃមនោគមវិជ្ជា នៃ ប្រទេស ជាសមាជិកទេ ដូចយ៉ាងប្រទេសចិន ជាប្រទេសកុម្មុយនិស្ត, ឥណ្ឌា ជាប្រទេស អនុវត្ត លទ្ធិប្រជាធិបតេយ្យសេរី, ឥណ្ឌូណេស៊ី ដឹកនាំដោយអ្នកជាតិនិយម តែជា ជនផ្តាច់ការនិយម (លោក ស៊ីកាណូ), យូហ្គោស្លាវី ដឹកនាំដោយ ជនកុម្មុយនិស្ត-ជាតិនិយម (លោក ទីតូ) តែមិនព្រមចំណុះ សហភាពសូវៀតឡើយ ។ល។ សមាសភាព បែបនេះ គ្មានទម្ងន់នយោបាយជាក់ស្តែង លើឆាកនយោបាយ ពិភពលោកនោះឡើយ។ អត្ថ

ភាព របស់ខ្លួន គ្រាន់តែជា ទម្រង់ នៃការសំដែងអារម្មណ៍ ច្រើនជាង ការអនុវត្តិ នៃផែនការ ច្បាស់លាស់ អ្វីមួយ។ បើនិយាយជាសង្ខេប គឺថាជា អង្គការ នៃកិត្យានុភាព របស់អ្នកដឹកនាំ នៃប្រទេសនិមួយៗ ដែលមាន អត្តភាព ខ្លាំង ហើយ ចង់បង្ហាញ នូវឯករាជ្យភាពខ្លួន ចំពោះ សហរដ្ឋអាមេរិក និង សហភាពសូវៀត តែប៉ុណ្ណោះ។

ពេលនោះដែរ នៅឥណ្ឌូចិន បារាំង វិលត្រឡប់មកវិញ ដោយមានបំណងបន្ត អាណានិគមខ្លួន ដែលនាំបង្កើត ជម្លោះនយោបាយ ជាមួយនឹង ចលនា យៀកមិញ[1] ដឹកនាំដោយលោក ហូ ជីញ មិញ ដែលគាត់បានប្រកាស ឯករាជ្យ ប្រទេសយៀកណាម នៅថ្ងៃទី ២៩ សីហា ១៩៤៥ មានឈ្មោះថា សាធារណរដ្ឋ ប្រជាធិបតេយ្យ យៀកណាម បន្ទាប់ពី ព្រះចៅអធិរាជ្យ បៅ ដាវ ដាក់រាជ្យសម្បត្តិ នៅថ្ងៃទី ២៥ សីហា។ ជម្លោះនយោបាយ បានប្រែក្លាយជា ជម្លោះយោធា ដ្បិតនៅថ្ងៃទី ២៣ កញ្ញា កងទ័ពបារាំង បានវាយប្រហារ កងកម្លាំងទ័ពយៀកមិញនៅទីក្រុង សៃហ្គន ដើម្បី ដណ្តើមកាន់កាប់អាគាររដ្ឋបាល។ ពួកយៀកមិញ សងសឹក ដោយសម្លាប់ជនជាតិបារាំងទាំងក្មេងចាស់ ប្រមាណ ១០០នាក់។ តែទោះបីមានវិបត្តិសំខាន់យ៉ាងណាក៏ដោយ នៅខែ មករា ឆ្នាំ ១៩៤៦ លោក ហូ ជីញ មិញ បានរៀបចំបោះឆ្នោត ដើម្បីតែងតាំងសភាជាតិ ហើយ នៅថ្ងៃ

[1] យៀកមិញ មានន័យថា បក្សសម្ព័ន្ធ ដើម្បី ឯករាជ្យ យៀកណាម។

ទី២ មីនា សភានេះ បានបោះឆ្នោតតែងតាំងលោក ហូ ជី ញ មុិញ ជាប្រធានាធិបតី។ បារាំង ព្រមទទួលស្គាល់ សាធារណរដ្ឋ ប្រជាធិបតេយ្យ យៀកណាម ជារដ្ឋសេរី មាន សភាជាតិ, រដ្ឋាភិបាល និង កងទ័ព នៅក្នុងក្រមខណ្ឌ នៃ សហព័ន្ធ ឥណ្ឌូចិន និង សហភាព បារាំង ហើយនៅថ្ងៃទី ១៥ កញ្ញា ឆ្នាំ ១៩៤៦ លោក ហូ ជីញ មុិញ ត្រូវបានរដ្ឋាភិបាលបារាំង អញ្ជើញលោក ធ្វើទស្សនាកិច្ចជាផ្លូវការ នៅស្រុកបារាំង ក្នុងឋានៈលោក ជាប្រមុខរដ្ឋ ដើម្បី ចុះហត្ថលេខា នូវកិច្ចសន្យាបណ្ដោះអាសន្នមួយ រវាង បារាំង-យៀកណាម ក្នុងគោលដៅ នាំមកវិញ នូវភាពស្ងប់ស្ងាត់ រវាងប្រទេសទាំងពីរ។ តែ នៅថ្ងៃទី២១ វិច្ឆិកា ក្រោយពីមានផ្ទុះអាវុធតូចមួយ រវាង ទាហានបារាំង នឹងយៀកមុិញ កងកាំភ្លើងធំបារាំង បានបាច់ទៅលើកំពង់ផែ ហៃហ្វុង នាំវាអោយមានប្រតិកម្ម នៃកងទ័ពយៀកមុិញ ដឹកនាំដោយលោក Vo Nguyen Giap ចូលវាយទីក្រុងហាណូយនៅថ្ងៃទី ១៩ ធ្នូ ហើយបានសម្លាប់ជនជាតិបារាំងជាច្រើន។ នៅពេលជាមួយគ្នានោះដែរ កងយោធភូមិបារាំង នៅ Phu Lan Thuong, Bac Ninh, Nam Dinh, Hué និង Tourane ត្រូវកងទ័ពយៀកមុិញវាយលុកដែរ។ ក្រោយពីលោក ហូ ជីញ មុិញ ចាកចេញពី ទីក្រុង ហាណូយ, នៅថ្ងៃទី២១ ធ្នូ គាត់បានអំពាវនាវ ដល់ប្រជាជនយួន អោយធ្វើសង្គ្រាមព្រៃប្រឆាំងនឹងកងទ័ពបារាំងនៅយៀកណាម ដោយប្រើគ្រប់

សម្ភារៈដែលខ្លួនមាន។ សង្គ្រាមក៏បានផ្ទុះឡើងនៅយៀកណាម ដែលមានរយៈពេលអស់ ២៩ឆ្នាំ (១៩៤៦-១៩៧៥)។ ត្រូវដឹងថា សង្គ្រាម នៅ ស្រុកយួន វាមាន ឥទ្ធិពល មកលើនយោបាយ នៅស្រុកខ្មែរខ្លាំងណាស់ ព្រោះ បក្សកុម្មុយនិស្តយួន តែងតែទុកសង្គ្រាមនោះ ជាសង្គ្រាម រំដោះ ទឹកដីឥណ្ឌូចិនពី អាណានិគមនិយមបារាំង, អាមេរិកាំង ដើម្បីឯករាជ្យ និង ឯកភាពយៀកណាមតែមួយ[2] និង ធ្វើឋបនកម្ម នូវលទ្ធិកុម្មុយនិស្តជាដាច់ខាត ព្រោះគេយល់ឃើញថា គោលដៅនេះ ជា ការធានាចាំបាច់ នៃ ស្ថិរភាព នៃ លទ្ធិកុម្មុយនិស្ត នៅឥណ្ឌូចិន ដែលមាន បក្សកុម្មុនិស្តយួន ជា អ្នកដឹកនាំ និង ប្រជាជនយួន ជាប្រជាជនឈានមុខ។ ការណ៏នេះឯង ជាសេចក្តីពិត សំរាប់ខ្មែរ ក្រោយពីស្រុកខ្មែរទទួលបាន ឯករាជ្យពេញលេញ ពីបារាំងសែស។ កិច្ចព្រមព្រៀងសន្តិភាព នៅទីក្រុងស៊ីណែវ នៅឆ្នាំ ១៩៥៤ រវាង បារាំង និង បក្សកុម្មុយនិស្តយួន ជាជ័យជំនះ នៃដំណាក់ការទី១ របស់បក្សកុម្មុនិស្តយួន។ ជាជំហានចាំបាច់ សំរាប់ បើកយុទ្ធសាស្រ្ត ជាទំហំ នៃ ឥណ្ឌូចិន ដែលខ្មែរយើង ឲឈ្មោះថា ដំណើរយួន ទៅទិសខាងលិច។ ការបង្កើត នៃ រដ្ឋយួនខាងត្បូង ឬ សាធារណរដ្ឋយៀកណាម

[2] នៅថ្ងៃទី២១ ឧសភា ឆ្នាំ ១៩៤៩ រដ្ឋសភាព បានបោះឆ្នោតភ្ជាប់ ដំបន់ Cochinchine នៅក្នុងក្នុងនោះ មាន ទឹកដីកម្ពុជាក្រោម ទៅក្នុងរដ្ឋ ជាសមាជិក នៃប្រទេសយៀកណាម គឺថា សហភាព នៃដំបន់រដ្ឋបី ( l’union des trois Ky) ដែល ប្រជាជនយួន តែងតែទាមទារ។

នៅក្នុង កិច្ចព្រមព្រៀង ស៊ីណែវ ជា ភាគ ទឹកដី និង នយោបាយ នៃស្រុកយួន ដោយបញ្ចូល ទឹកដីកម្ពុជាក្រោម ទៅក្នុងនោះ វាជាបរាជ័យ របស់អ្នកដឹកនាំខ្មែរជំនាន់នោះ។ តែ អ្នកដឹកនាំនោះ បែរជា ក្រឡៃ នូវបរាជ័យនោះ ឲទៅជា មហាជ័យជំនះខ្មែរ ព្រោះស្រុកខ្មែរមិនត្រូវបានគេ បែងចែក ជាពីរដំបន់ ដូច នៅស្រុកយួនចែកជាពីដំបន់, យួនខាងជើង ជាយួនកុម្មុយនិស្ត និង យួនខាងត្បូង ជាយួនសេរី ដែលយកខ្សែស្រប ទី១៧ ជាព្រំដែនរដ្ឋ។ នៅពេលនោះ ផលប្រយោជន៏ខ្មែរ មានតែមួយគត់ គឺ ការបង្កើត គណកម្មាធិការ អន្តរជាតិ ត្រួតពិនិត្យ (C.I.C.) នៃការដកទ័ពបរទេសចេញពីស្រុកខ្មែរ។ យួនកុម្មុយនិស្ត បានដកទ័ព ចេញពីស្រុកខ្មែរ តែ ទឹកដីកម្ពុជាក្រោម ទាំងអស់ ត្រូវបញ្ចូលទៅក្នុង ទឹកដី យួនខាងត្បូង។ ប្រជាជនខ្មែរនៅកម្ពុជាក្រោម ក្លាយទៅជាប្រជាជនយួន។ ហើយនៅក្នុងសង្គ្រាម រវាងយួន នឹងយួនត្រូវគេ ទាំងសងខាង បង្ខំឲចូលធ្វើទាហាន ឬ អ្នករំដោះច្បាំងជួយយួន។ នៅពេល អាមេរិកាំង មកជួយច្បាំងយួនខាងត្បូង គេជ្រើសរើសខ្មែរកម្ពុជាក្រោម ធ្វើជាទាហានក្នុងកងឯកភាពពិសេសមួយ ដែលខ្មែរយើងស្គាល់ឈ្មោះថា ពួក ‹Mike forc›។

ដូចបានជំរាបពីខាងលើរួចមកហើយថា នៅស្រុកខ្មែរមានចរន្តនយោបាយពីរ។ តែពួកកុម្មុយនិស្ត គេបង្កើត

ចរន្ត ទី៣ គឺចរន្តកុម្មុយនិស្ត ដើម្បីជួយយួន ច្បាំងដេញបារាំងពីឥណ្ឌូចិន។ ចរន្ត នៃ ពួកអ្នកប្រជាធិបតេយ្យ-ជាតិនិយម ជាចរន្ត នៃ ពួកអ្នកចេះដឹងអាយខ្មែរ[3] និងបញ្ញាវន្ត មួយក្រុមតូច មានសញ្ញាប័ត្របរទេស មានគំនិត ធ្វើទំនើបកម្ម នូវជីវិតភាពនយោបាយខ្មែរ។ ចរន្ត នៃ ពួកអ្នករាជានិយមធិបតេយ្យ ដែលជា ពួកស្តេច និងមន្ត្រីខ្មែរ ជា អ្នកអភិរក្សនិយម ធ្លាប់តែរស់នៅក្នុងបារមីព្រះមហាក្សត្រ ជាទំនៀមជាតិម៉ឺនឆ្នាំ។ នៅអំឡុងឆ្នាំ ១៩៤៦-១៩៥៥ ចរន្តទាំងនោះ ធ្វើការប្រកួតប្រជែងគ្នាតាមរយៈការបោះឆ្នោតសាកល ដើម្បី យកតួនាទី ជាអ្នកដឹកនាំជាតិ។ គណបក្សប្រជាធិបតេយ្យ ដែលបង្កើតឡើងដោយ ពួកអ្នកប្រជាធិបតេយ្យ-ជាតិនិយម ទទួលបានជំនះ ដឹកនាំរដ្ឋសភា ជា ក្រុមភាគច្រើនដាច់ខាត ហើយបង្កើត រាជរដ្ឋាភិបាល ដឹកនាំជាតិ។ គណបក្ស សេរីភាពបង្កើតឡើង ដោយពួក ពួកស្តេច និង ពួកអភិរក្សនិយមទទួលបានអាសនៈដែរ នៅក្នុងរដ្ឋសភា តែជាក្រុមភាគតិច។ រីឯ គណបក្សប្រជាជន វិញ ជា ស្លាបនយោបាយ នៃបក្សកុម្មុយនិស្តខ្មែរ និយមយួន បានទទួលអាសនៈ តិចតួចណាស់ នៅក្នុងរដ្ឋសភា តែអាច រក្សាបាន នូវអត្តភាពខ្លួន តែមិនទៀងទាត់ លើឆាកនយោបាយជាតិ។ តែដំណើរជាប្រក្រតី នៃ ការអនុវត្តន៍ នៃលទ្ធិប្រជាធិបតេយ្យ

[3] ពួកអ្នកចេះដឹង បានរៀនសូត្រចេះដឹងនៅក្នុងស្រុកខ្មែរ។

តែងតែមានការរំខានជានិច្ច ពីសំណាក់ ព្រះមហាក្សត្រខ្មែរ គឺ ព្រះបាទនរោត្តមសីហនុ ព្រោះ ព្រោះ អង្គ មិនដែលទទួលយល់ព្រមក្នុងចិត្តព្រះអង្គ យករបបប្រជាធិតេយ្យជារបបដឹកនាំជាតិ។ ដូច្នេះ ព្រះអង្គ ធ្វើប្រតិកម្មគ្រប់បែបយ៉ាង ដើម្បីរំខាន នូវដំណើរ នៃលទ្ធិប្រជាធិតេយ្យក្មេងខ្ចីនៅស្រុកខ្មែរ ដូចយ៉ាង រំលាយរដ្ឋសភា ពីរលើក[4] ដោយ បំពានលើច្បាប់រដ្ឋធម្មនុញ្ញ ព្រោះ រដ្ឋសភា ធ្វើនយោបាយ ផ្ទុយពីការចង់បាន របស់ព្រះអង្គ ទោះបី ព្រះអង្គ មានតួនាទីត្រឹមតែជា មហាក្សត្រ នៃរដ្ឋធម្មនុញ្ញ តែប៉ុណ្ណោះ។ ក្រោយមកទៀត គណបក្សប្រជាធិបតេយ្យ ត្រូវបាន ពួកស្លាបឆ្វេង ឬ ពួកអ្នកជឿនលឿននិយម ដណ្តើមកាន់កាប់បាន នូវនាយកដ្ឋាន នៃ គណបក្ស ដែលនាំឲវរជនធំៗ នៃ ពួកអ្នកជាតិនិយម លាលែងចេញពីគណបក្ស ទៅចូលរួម ក្នុង ចលនា សង្គមរាស្ត្រនិយម ដែលបង្កើតឡើង ដោយ សម្តេច សីហនុ បន្ទាប់ពីទ្រង់ ដាក់រាជសម្បត្តិ ថ្វាយជូន ព្រះបិតា ព្រះនាម នរោត្តម សុរាម្រិត្រ។ ការចូលរួមធ្វើសហការនោះ គឺធ្វើឡើង ក្នុងគោលដៅចម្បង គឺ ដើម្បីប្រឆាំងនឹង ពួកជឿនលឿននិយម និងពួកកុម្មុយនិស្តនិយម។ នៅឆ្នាំ ១៩៥៥ ចលនា សង្គមរាស្ត្រនិយម មានជ័យជំនះ ក្នុងការបោះឆ្នោតសាកល ទទួលបានអាសនៈ ៨៣% នៅក្នុង រដ្ឋសភា។ នៅឆ្នាំ ១៩៥៨ ស

[4] ទី១ នៅឆ្នាំ ១៩៤៩; ទី២ នៅឆ្នាំ ១៩៥៣ ហើយប្រកាស ជាតិមានអាសន្ន។

ម្តេចសីហនុ រំលាយ រដ្ឋសភា ម្តងទៀត ព្រោះទ្រង់មាន ទំនាស់ជាមួយរដ្ឋាភិបាល ដឹកនាំដោយ លោក សឹម វ៉ា។ បន្ទាប់មក មានការបោះឆ្នោតសាកល។ លទ្ធផល នៃការ បោះឆ្នោត អោយអំណោយផលដល់ ចលនាសង្គមរាស្ត្រ និយម គឺទទួលបានអាសនៈទាំងអស់ នៅក្នុងរដ្ឋសភា។ នៅឆ្នាំ ១៩៦០ ព្រះមហាក្សត្រ សុរាមារិទ្ធ ទ្រង់សុគត តែ ស ម្តេចសីហនុ មិនអនុញ្ញាត ឲជ្រើសតាំង ហ្លួងថ្មី។ ទ្រង់ទុក រាជបល័ង្គ អោយនៅទំនេរ ហើយ រកមធ្យោបាយ ឲសភា ជាតិ ធ្វើច្បាប់ ដើម្បី តែងតាំងព្រះអង្គ ជា ប្រមុខរដ្ឋ អស់ មួយជីវិត។ នៅឆ្នាំ ១៩៦៦ សម្តេចសីហនុ ប្រកាសឲមាន ការបោះឆ្នោតសាកល និង សេរី គឺ ចលនា សង្គម លែង ជ្រើស បេក្ខជនតំណាងរាស្ត្រ ឲប្រជាពលរដ្ឋ សម្រាំងយក តំណាងរបស់ខ្លួន ដូច្នេះ សមាជិក នៃចលនាសង្គមរាស្ត្រ និយម អាចមាន លទ្ធភាព ឈរឈ្មោះជាបេក្ខជន ដោយ ខ្លួនឯង។ លទ្ធផល នៃការបោះឆ្នោត គឺ ពួកអ្នក ស្តាំនិយម ទទួលបានជ័យជំនះ ដែលនាំអោយ សម្តេច សីហនុ ជ្រើសយក លោក ឧត្តមសេនីយ លន់ នល់ ជានាយ រដ្ឋមន្ត្រី។ ដើម្បី ត្រួតពិនិត្យ រដ្ឋាភិបាល របស់ លន់ នល់ ស ម្តេចសីហនុ ទ្រង់បង្កើត បរិរដ្ឋាភិបាល[5] ដែលមាន

[5] បរិរដ្ឋាភិបាល គឺ រដ្ឋាភិបាលនៅជិតខាង ឬ នៅក្នុងប្រទេសជាមួយគ្នា។ ជាទម្រង់ រដ្ឋាភិបាលប្រឆាំង (contre-gouvernement) ដូចនៅ ប្រទេស អង់គ្លេស។

សមាជិក សុទ្ធតែអ្នកឆ្វេងនិយម។ នៅឆ្នាំ ១៩៦៧ មានការបះបោរ នៃពួកកសិករ នៅភូមិសំឡូត ដែលមានកម្មាភិបាលយួនកុម្មុយនិស្ត ជាអ្នកដឹកនាំលាក់មុខ។ ស្របពេលនោះដែរ លោក លន់ នល់ មានគ្រោះថ្នាក់ចរាចរណ៍, លោក ក៏បានសុំលាពីដំណែង នាយករដ្ឋមន្ត្រី។ ដើម្បីប្រឈមមុខនឹងការបះបោរ សម្តេចសីហនុ ទ្រង់ បង្កើតរាជរដ្ឋាភិបាល ពិសេស ដឹកនាំដោយទ្រង់ផ្ទាល់។ រាជរដ្ឋាភិបាលនោះឯង ដែលបញ្ជាឲ កងទ័ពអាកាស ទំលាក់គ្រាប់លើភូមិសំឡូត នាំឲស្លាប់ ប្រជាកសិករជាច្រើន។ នៅឆ្នាំ ១៩៦៨ សម្តេច សីហនុ ទ្រង់បង្កើត រាជរដ្ឋភិបាលថ្មីមួយទៀត ដាក់ឈ្មោះថា រដ្ឋាភិបាល លាភជ័យចុងក្រោយ ដឹកនាំដោយ សម្តេច ប៉ែន នុត ដែលជាជនស្មគ្រពួកគ្មានលក្ខខណ្ឌ នឹងព្រះអង្គ។ នៅឆ្នាំ ១៩៦៩ សម្តេច ប៉ែន នុត សុំលាលែងពីដំណែង នាយករដ្ឋមន្ត្រី ដែលនាំឲ សម្តេច សីហនុ បង្កើត រាជរដ្ឋាភិបាលថ្មីមួយទៀត ដឹកនាំដោយ លោក លន់ នល់។ រដ្ឋាភិបាលនេះ ទ្រង់ឲឈ្មោះថា រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ។ ក្នុងរដ្ឋាភិបាលនោះ មានទ្រង់ ស៊ីសុវត្ថិ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រីទី១។ ក្រោយបន្តិមក លោក នល់ នល់ មានជម្ងឺ ទៅព្យាបាលរោគនៅស្រុកបារាំង។ តែលោក មិនលាលែងពីតំណែងទេ តែលោក ប្រគល់ដំណែង នាយរដ្ឋមន្ត្រីស្តីទី ដល់ទ្រង់ សិរិមតៈ។ រដ្ឋាភិបាលស្រោចស្រង់ជាតិ ធ្វើគំរោងច្បាប់បី ដាក់

ជូនរដ្ឋសភា អនុម័ត បានសំរេចដូចបំណង ដែលជាច្បាប់ នៃ ‹សេរីកម្ម សេដ្ឋកិច្ច និង ធានាគារ›។ ច្បាប់ថ្មីនេះ វាផ្តុយស្រឡះ ពីនយោបាយ សេដ្ឋកិច្ច របស់សម្តេច សីហនុ នាំឲទ្រង់ មានទំនាស់នឹង រដ្ឋសភាផង និង រដ្ឋាភិបាលផង។ នៅថ្ងៃទី៦ មករា ឆ្នាំ ១៩៧០ សម្តេច សីហនុ ទ្រង់យាងទៅស្រុកបារាំង គ្មានអោយដំណឹងដល់ រដ្ឋាភិបាលជាមុន ដើម្បី ធ្វើអារោគ្យកម្មសុខភាព ក្រោយពីទ្រង់ ទទួល នូវបរាជ័យនយោបាយផ្ទាល់ នៅពេល សមាជជាតិ លើកទី ២៨[6] ដែលជាសមាជជាតិ ចុងក្រោយ នៃ របប សង្គមរាស្ត្រនិយម ព្រោះទ្រង់ ពុំអាចផ្តួល រដ្ឋាភិបាលស្រោចស្រង់ជាតិបាន។ ព្រឹត្តិការណ៏ នយោបាយ ផ្សេងៗទៀត ដែលយើងលើកយកមក លាត្រដាង យ៉ាងពិស្តាខាងក្រោមនេះ គឺជាដំណើរ ដើរទៅរក ការបង្កើត របប សាធារណរដ្ឋខ្មែរ។

## ប្រភព នៃពាក្យ កូសាំងស៊ិន

ស្រុកខ្មែរ បាត់ទឹកដីមួយចំណែកធំនៅទិសខាងកើត គឺទឹកដី កម្ពុជាក្រោម ស្ថិននៅក្នុងដំបន់ កូសាំងស៊ីន។ ដូច្នេះនៅក្នុងការចេះដឹងជាទូទៅ គួរយើងលើកយក

[6] ត្រូវដឹកថា សម្តេចសីហនុ មិនអនុញ្ញាត ឲពួកតំណាងរាស្ត្រ ចូលរួមប្រជុំន នៅក្នុងសមាជជាតិនោះឡើយ ដោយសារ ព្រះអង្គ មានជម្លោះនយោបាយ ជាមួយរដ្ឋសភា។

ប្រភព នៃពាក្យ កូសាំងស៊ីន មកជំរាប ដល់អ្នកអាន ទុកជាការបើកវង់ក្រចកមួយ ក្នុងព្រឹត្តិការណ៍ នៃការទំលាក់ សម្តេច សីហនុ ពីមុខតំណែង និង ការបង្កើត របប សាធារណៈរដ្ឋ ព្រោះ ទឹកដីកូសាំងស៊ីន ជាចំណែកមួយ របស់ស្រុកខ្មែរ ហើយ វាជាប្រភព នៃជម្លោះអចិន្ត្រៃយ៍នៅក្នុងអារម្មណ៍ខ្មែរ រវាង ស្រុកខ្មែរ នឹង ស្រុកយួន។ និយាយអំពីនយោបាយ នៃស្រុកខ្មែរ វាតែងតែមានជាប់ពាក់ព័ន្ធជានិច្ចនឹងពាក្យ កូសាំងស៊ីននេះជានិច្ច ព្រោះវាជារបួស របស់ប្រជាជាតិខ្មែរ ដែលមានយួន ជាអ្នកបង្ក និង របប រាជានិយម ជាអ្នកទទួលខុសត្រូវ និង ជាពិរុទ្ធិរបប។

ពាក្យនេះ មានតម្លៃបីយ៉ាងខុសគ្នា នៅក្នុង អក្សរសិល្ប ភូមិសាស្ត្រ នៃជនជាតិអឺរ៉ុប :

១. ពីឆ្នាំ ១៥០២ ដល់ ១៦១៥ : កូសាំងស៊ីន កំណត់ នូវ រាជាអាណាចក្រ អណ្ណាម ទាំងមូល គឺ ខាងជើង ពីព្រំដែនចិន រហូតមកខាងត្បូង ដល់ ព្រំដែន នគរចំប៉ា។

២. ពីឆ្នាំ ១៦១៥ ដល់ ១៨៨២ : កូសាំងស៊ីន ជាឈ្មោះ ភាគមួយ នៃនគរអណ្ណាម ដែលស្ថិតនៅខាងត្បូង នៃតុងកឹង ចន្លោះ ខាងជើង គឺ តំបន់ Dong Hoi និង ព្រំដែនខាងត្បូង នៃអណ្ណាម (ព្រំដែននោះ ចេះតែរំអិលជានិច្ច ទៅទិស ខាងត្បូង បណ្តាលអោយទឹកដី នៃអណ្ណាមកាន់តែរីកធំៗ ឡើង)។

៣. ពីឆ្នាំ ១៨៨៣ ដល់ ១៨៨៧ : កូសាំងស៊ីន កំណត់ ដែនដីឧបទ្វីប នៃអាណានិគមបារាំងខាងត្បូង ; រីឯ ភាគកណ្តាល បារាំង យកឈ្មោះចាស់ អណ្ណាម សំរាប់ កំណត់តែដែនដី ស្ថិតនៅត្រង់ចន្លោះ តុងកឹង និង កូសាំងស៊ីន ដែលមួយភាគធំជាទឹកដី នៃអតីតនគរចំប៉ា។

ដូច្នេះ ចាប់ពីឆ្នាំ ១៨៨៣ បារាំង បែងចែកទឹកដីអាណានិគមខ្លួននៅយៀកណាម ជាបីតំបន់ គឺ តុងកឹង, អណ្ណាម និង កូសាំងស៊ីន ដែលយើងយកមកប្រើ រហូតមកដល់សព្វថ្ងៃនេះ សំរាប់សំគាល់ប្រទេសយៀកណាម។

ពាក្យកូសាំងស៊ីន មានប្រភពចេញពីពាក្យជប៉ុន ដែលហៅ នគរអណ្ណាម ថា កូស៊ី គឺមានន័យថា នគរនៅភាគមស្ទឹម នៃនគរចិន ហើយពាក្យនេះ ត្រូវបានពួកអ្នកជំនួញ Portuguais គេយកមកប្រើ ដោយបន្ថែមពាក្យ ស៊ីន (Chine) គឺថា កូស៊ីស៊ីន (កូស៊ី ភាគខាងចិន) ដើម្បី មិនអោយច្រឡំគ្នានឹង ដំបន់ កូសាំង នៅឥណ្ឌា។ ពាក្យនេះ គេចាប់មានប្រើក្នុង មជ្ឈដ្ឋានសាសនាកាតូលិញ នៅដើមសតវត្សទី១៧, ហើយ សរសេរអក្សរ[7] ខុសគ្នាៗ ដូចយ៉ាង : Cocicina, Caucincina, Cauchina សំរាប់កំណត់

[7] សរសេរជាលើកដំបូង នៅអំឡុងឆ្នាំ ១៦១៨ និង ១៦៣០ ចុះផ្សាយនៅឆ្នាំ ១៦៣១។

*(note de bas de page - suite)*

រាជអាណាចក្រខាងត្បូង នៃពួកង្វៀង ដែលប្រឆាំងនឹងអំណាចព្រះចៅយួនអណ្ណាម[8]។

## កត្តា នៃ ការរលំ សម្តេចសីហនុ

ទោះបី សម្តេចសីហនុ ទ្រង់ ចោទប្រកាន់ដល់ សហរដ្ឋអាមេរិកថា តាមរយៈ អង្គការ CIA បានចូលរួមផ្ទាល់ ជាមួយ រដ្ឋាភិបាល ស្រោចស្រង់ជាតិ ដើម្បីទំលាក់ព្រះអង្គពីដំណែង ប្រមុខរដ្ឋអស់មួយជីវិត ដែលជាបំណង ធ្លាប់មានពីមុនៗ រួចមកហើយ តាំងពីឆ្នាំ ១៩៥៤ តែពុំបានសំរេច ដូចយ៉ាងការចូលរួមជាមួយ ជនក្បត់ជាតិ មាន លោក សម សារី និង ដាប ឈួន ជាអាទិ៍ ដើម្បី សម្លាប់ព្រះអង្គ ឬ ទំលាក់ព្រះអង្គ ពីដំណែង តែការចោទនេះ ត្រូវរដ្ឋាភិបាល ស្រោចស្រង់ជាតិ ពោលអះអាងថា ការទំលាក់ សម្តេចសីហនុ គឺធ្វើឡើង ដោយ ស្របច្បាប់រដ្ឋធម្មនុញ្ញ និង ឆ្លើយនឹង សេចក្តីនឿយណាយ ឬ សេចក្តីក្តៅក្រហាយ នៃ ប្រជាពលរដ្ឋ នៅចំពោះមុខ គ្រប់អំពើខុសច្បាប់ និង បំភាន់ របស់សម្តេច សីហនុ និង ប្រព័ន្ធនយោបាយ ដែលផុតសម័យ គឺ របបសង្គមរាស្ត្រនិយម។

[8] ដកស្រង់ពីឯកសារ នៃសាលាបារាំងចុងបូព៌ាប្រទេស : sur le nom de Cochinchine par L. AUROUSSEAU, professeur de chinois d'Ecole Française d'Extrême-Orient.

របបនេះ ទទួលបរាជ័យជាក់ស្តែង តែ សម្តេច សីហនុ រហូតមកដល់ដើមឆ្នាំ ១៩៧០ ទ្រង់ នៅមិនព្រមទទួលស្គាល់ជាដាច់ខាត នូវ ការប្រឡំ និង កំហុសទាំងឡាយ ដែលទ្រង់បានធ្វើរួចមក។ ការពិត វាមានកត្តា ជាច្រើន នៅស្រុកខ្មែរ ដែលនាំឲមាន វិបត្តិនយោបាយសំខាន់ ក្នុងនោះមាន ទង្វើបរទេសមួយចំណែក រួមនឹង កត្តាផ្ទៃក្នុង ជាច្រើន។

## កត្តា ផ្ទៃក្នុង

### វិបត្តិ សេដ្ឋកិច្ច

នយោបាយ សេដ្ឋកិច្ច របស់សម្តេច សីហនុ តាំងពី ឆ្នាំ ១៩៥៥ មក នាំឲមាន នូវការផ្លាស់ប្តូរ រហ័ស ជាវិជ្ជមាន នៅក្នុងវិស័យខ្លះៗ តែ ជាទូទៅ វាជួបប្រទះ នូវបរាជ័យ ជាក់ស្តែង ដែលតម្រូវ ឲមាន កំណែទំរង់ ជាចាំបាច់ នៅ ឆ្នាំ ១៩៧០។

**១. ទ្រឹស្តី** : លទ្ធិសង្គមនិយម ពុទ្ធសាសនា នៃ ចលនា សង្គមរាស្ត្រនិយម ដែលបង្កើតដោយសម្តេច សីហនុ ក៏ ដូចគ្នានឹង លទ្ធិសង្គមនិយម នៃតតិយលោក គឺគ្មាន មាន បតិដ្ឋាភាគ នៃ វិទ្យាសាស្ត្រឡើយ (consistance scientifique)។ ជាទូទៅ គឺគ្រាន់តែជា ការតម្លើង នៃទឹកចិត្ត រំភើបញ្ញប់ញ័រ និង ការរក្សា នៃប្រពៃណីជាតិ សំរាប់

ជួយ រក្សា នូវអំណាច នៃ វណ្ណៈ នៃពួកអ្នកដឹកនាំអភិរក្សនិយម តែប៉ុណ្ណោះ។ យ៉ាងណាមិញ លទ្ធិសង្គមរាស្ត្រនិយម មានទម្រង់ក្រៅជា របប នយោបាយ និង សេដ្ឋកិច្ច បើកចំហដល់ លទ្ធិប្រជាធិបតេយ្យសេរី។ របបនេះ មាន គោលការណ៍សំខាន់ជាទ្រឹស្តី បីយ៉ាង : ទី១ កាត់បន្ថយ នូវទុក្ខវេទនា របស់ប្រជារាស្ត្រ; ទី២ យក ប្រពៃណីខ្មែរ, ពុទ្ធសាសនា និង រាជានិយម ជាគ្រឹះ ; ទី៣ មានមូលដ្ឋាន ជាតិនិយម។ រួមមក ទ្រឹស្តីនោះ វានៅជិតគ្នានឹង របបបិតុនិយមអភិរក្ស[9]។ បើយោងតាម គោលវិធី នៃទ្រឹស្តីនោះ គឺមានការទទួលស្គាល់ នៃ សេរីភាពបុគ្គល និង បដិសេធនូវ គ្រប់ សកម្មភាព នៃ ការបំពានអំណាច។ តែគេដឹងថាការអនុវត្តន៍ នៃរបបសង្គមរាស្ត្រនិយម វាផ្ទុយស្រឡះពីទ្រឹស្តីមូលដ្ឋានរបស់ខ្លួន ព្រោះ សម្តេច សីហនុ ទ្រង់យកវាមកធ្វើជាឧបករណ៍ នៃតម្រេង នៃអំណាចរបស់ព្រះអង្គ។

**១. នយោបាយសេដ្ឋកិច្ច** : ប្រវត្តិសាស្ត្រ នយោបាយខ្មែរមាន បែកចែកជាពីរសម័យ : អំឡុងឆ្នាំ ១៩៥៤-១៩៦៣, គឺជាសម័យ សេរីនិយម។ គេសំគាល់ឃើញថា មរតក នៃអាណានិគមបារាំង វានៅមានឥទ្ធិពលខ្លាំង នៅក្នុងការគ្រប់គ្រងកិច្ចការរដ្ឋ គឺថា មជ្ឈការលើសលន់ នៃអំណាចរដ្ឋ។ ប្រភាពនេះ ជាឧបសគ្គចម្បងមួយ ដល់ការធ្វើកំណែទំ

[9] បិតុនិយមអភិរក្ស (paternalisme conservateur) គឺជារបប ទុកអ្នកដឹកនាំជាបិតាជាតិ។

រង់ នូវរថនាសម្ព័ន្ធរដ្ឋ សំរាប់ទ្រទ្រង់នយោបាយសេដ្ឋកិច្ច ទំនើប ស្របនឹងសេចក្តីត្រូវការពិត នៃប្រជាជាតិ។ មួយ វិញទៀត កង្វះ នៃការគ្រប់គ្រងម៉ឺងម៉ាត់ នៃជំនួយ បរទេស (អាមេរិកាំង) នាំអោយវាគ្មានប្រសិទ្ធិភាព ដល់ នយោបាយសេដ្ឋកិច្ច និង បង្កើត នូវអំពើពុលរលួយ នៅ ក្នុងមជ្ឈដ្ឋាន អ្នកគ្រប់គ្រងសេដ្ឋកិច្ច។

ដូច្នេះ នយោបាយ សេរីនិយមនោះ វានាំទៅរក ទំនាល់ជា ប្រត្យក្សភាព នៃអំណាចរដ្ឋមជ្ឈការ និង ការចាំបាច់ នៃ សេដ្ឋកិច្ចផ្សារ។ តាមការយល់ឃើញ របស់ពួកអ្នកជឿន លឿននិយម មាន លោក ខៀវ សំផន ជាម្ចាស់គំនិត ក្នុង ឋានៈ ជារដ្ឋមន្ត្រី ថែងនៅក្នុង សេចក្តីរាយការណ៍ របស់ លោក នៅឆ្នាំ ១៩៦៣ ជូនដល់ សម្តេចសីហនុ ក្នុងនោះ មានលើកឡើង នូវភាពមិនសមហេតុផលមួយចំនួន នៅ ក្នុងនយោបាយសេដ្ឋកិច្ចជាតិ។ ការណែនាំនេះ នាំអោយ សម្តេច សីហនុ យកវា មកធ្វើជា គោលការណ៍នយោបាយ ថ្មី គឺ ទ្រង់សំរេច បោះបង់ចោល នូវ ជំនួយ របស់សហរដ្ឋ អាមេរិក នៅខែ វិច្ឆិកា ឆ្នាំ ១៩៦៣ ដែលទ្រង់ទុកជា ជំនួយមានចំណង[10] ហើយ ធ្វើ ជាតិូបនីយកម្ម នៃ ធានា

[10] ត្រូវដឹងថាគ្រប់ជំនួយ របស់សហរដ្ឋអាមេរិក ដល់ប្រទេសជាមិត្ត, អាមេរិកាំងតែងតែ ដាក់លក្ខខណ្ឌចាំបាច់អោយគោរព គឺ គោលការណ៍ នៃសិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យ។ គោលការណ៍នេះឯង ដែលសម្តេច សីហនុ ទុកជាជំនួយមានចំណង ព្រោះជាគោលការណ៍ រំខានដល់នយោបាយរបស់ព្រះអង្គ។

ការ និង ពាណិជ្ជកម្ម ទំនិញ នាំចូល និងនាំចេញ (អហរណកម្ម និង នីហរកម្ម)។ សួរថា តើនយោបាយថ្មីនោះ មានប្រសិទ្ធភាព ដែរឬទេ ? ដើម្បី ឆ្លើយ នូវសំនួរនេះ គួរយើងលើកយកនយោបាយសម្តេច សីហនុ ចាំពីឆ្នាំ ១៩៦៣ មកធ្វើវិភាគ ដើម្បីឆ្លុះមើល នូវការពិតមួយចំនួន ដែលនាំអោយព្រះអង្គជួបនឹងវិបត្តិនយោបាយ ដែលខ្លួនព្រះអង្គជាអ្នកបង្កើត។ នៅឆ្នាំ ១៩៦៣ គេអាចទុកជាសំណក នៃនយោបាយ របស់សម្តេច សីហនុ ដែលស្ថិតនៅលើទំនាលនាំរំអិលធ្លាក់ទៅក្នុង សំណាញ់ពីងពាង របស់ ចិន និងយួនកុម្មុយនិស្ត ដែលពួកគេ ត្រូវការសម្តេច សីហនុ ដើម្បីបំរើផលប្រយោជន៍ របស់ពួកគេ។ ក្រោយពី សម្តេច សីហនុ យកជំនួយចិន មកប្តូរនឹងជំនួយអាមេរិកាំង, ក្នុងរយៈពេលពីរបីឆ្នាំកន្លងមក សេដ្ឋកិច្ចខ្មែរ ធ្លាក់ទៅក្នុងភាពស្លុតស្គឹង។ ដូច្នោះ រដ្ឋខ្មែរ ស្ថិតនៅក្នុងភាពទ្រុឌចុង រហូតដល់ទៅគ្មានថវិការ សំរាប់បង់បៀវត្សដល់ ពួកអ្នករាជការ ស៊ីវិល និង យោធា[11] ដែលនាំអោយសម្តេច សីហនុ បង្ខំចិត្ត បង្កើត នូវរដ្ឋាភិបាលស្រោចស្រង់ជាតិ ដឹកនាំដោយ លោក លន់ នល់។ រាជរដ្ឋាភិបាលនេះ មានបេសកកម្មធំបីយ៉ាង : ១. តម្រង់វិញ នូវសេដ្ឋកិច្ចជាតិ, ២.

[11] ដើម្បីអាចបង់បៀវត្ស ដល់ពួកអ្នករាជការ សម្តេច សីហនុ អនុញ្ញាតអោយបង្កើតគ្រឹះស្ថានល្បែងធំពីរ មួយនៅទីក្រុងភ្នំពេញ មួយទៀតនៅទីក្រុងព្រះសីហនុ ដើម្បីយកអាករ។

ស្វែងរកផ្លូវនយោបាយថ្មី សំរាប់អនាគតជាតិ, ៣. ពិនិត្យឡើងវិញ នូវនយោបាយ កិច្ចការបរទេសខ្មែរ ជាពិសេស ការទំនាក់ទំនង ជាមួយពួកយួនកុម្មុយនិស្ត។

**៣. ការកត់ត្រា នៃ បរាជ័យ** : តុល្យការ ដែលជាមហន្តរាយ ដល់សេដ្ឋកិច្ចជាតិ មានចែងនៅក្នុង សេចក្តីរាយការណ៍ របស់ រដ្ឋមន្ត្រី អេង ហ៊ុន ចុះផ្សាយនៅក្នុង ទស្សនាវដ្តី ‹កម្ពុជាថ្មី› លេខទី១ នៅឆ្នាំ ១៩៧០។ តែ សម្តេច សីហនុ ទ្រង់មិនសូវយកចិត្តទុកដាក់ តែទ្រង់ ក៏មិនបដិសេធនោះដែរ។ ក្នុងសេចក្តីរាយការណ៍នោះ មានបង្ហាញ នូវវិបត្តិមួយចំនួន ដូចយ៉ាង : មាននៅក្នុង វិស័យកសិកម្ម ដែលប៉ះពាល់ផ្ទាល់ ដល់ ៩០% នៃ ប្រជារាស្ត្រខ្មែរ។ លទ្ធផលអវិជ្ជមាន ធ្ងន់ធ្ងរក្រៃ គឺមកពី អវត្តមាន នៃ វិនិយោគ ជាមូលដ្ឋាន ចាំបាច់ ដល់ ការអភិវឌ្ឍន៍ នៃ កសិកម្មប្រពៃណី ដូចយ៉ាង ការបញ្ចូលទឹកក្នុងស្រែចំការ ជាអាទិ៍។ បរាជ័យ នៃ សហករណ៍, វិធានការ ប្រឆាំងនឹង កម្ចីយកការប្រាក់ហួសប្រមាណ, ការឆ្លៀតរកកម្រៃ ពីកសិករ ពីសំណាក់អាជ្ញាធរ និង ការបំផ្លាញ ធនធានធម្មជាតិជាតិ ដែលជាបរាជ័យ នាំ នូវទំនញ់ នៃ ទិន្នផល និង ការបង្កើតផលដែលបង្ខាំង នូវការផ្តួតផ្តើម របស់កសិករមិនឲធ្វើកើត ហើយជួយជំរុញ ឲមាន វិបត្តិនយោបាយ គឺ បង្កើត នូវកំហឹងពីសំណាក់ប្រជាកសិករ។

តែ វប្បកម្ម ឧស្សាហកម្ម ដូចយ៉ាង ការដាំដើមកៅស៊ូ, កាហ្វេ, តែ, ដើមក្រចៅ មានលទ្ធផលល្អប្រសើរ តែ ជោគជ័យ នេះ វាមានផលប៉ះពាល់ តិចតួចណាស់ ដល់ ជីវិតភាព នៃ ប្រជាកសិករខ្មែរ។

ក្នុងវិស័យ ឧស្សាហកម្ម លទ្ធផល វាគ្មានការលើកទឹកចិត្តឡើយ ព្រោះ វាខ្វះ នូវពួកមូលធនអោយ។ នៅឆ្នាំ ១៩៦០ សម្តេច សីហនុ ទ្រង់ យកជំនួយ ចិនកុម្មុយនិស្ត មកធ្វើអភិវឌ្ឍ នូវបណ្តាញ សហគ្រាសជាតិ និង ក្រុមហ៊ុន សេដ្ឋកិច្ចចំរុះ តែគ្មានជោគជ័យឡើយ។ បរាជ័យ មាន ហេតុផលពីរយ៉ាង : អវត្តមាន នៃ សនិទានភាព ក្នុងការបង្កើត និង ការសង់ រោងចក្រ ; ការគ្រប់គ្រង មិនល្អ និង អំពើអាក្រក់ របស់ ពួកអ្នកដឹកនាំ ជាអ្នករាជការ។

ក្នុងវិស័យ ពាណិជ្ជកម្ម និង ធានាគារ ការកែទម្រង់ នៅឆ្នាំ ១៩៦៣ គ្មានមានលទ្ធផលជាវិជ្ជមាននោះឡើយ។ ក្រុមហ៊ុនរដ្ឋ អហារណកម្ម និង នីហរកម្ម ផ្តាច់មុខ នៃ ពាណិជ្ជកម្ម ក្រៅប្រទេស និង ភណ្ឌាគាររដ្ឋ ដែលមានតួនាទីដើមជាអ្នក លក់ និង ទិញ ផលិផល មួយចំនួន ក្លាយទៅជាសម្បត្តិផ្ទាល់ខ្លួនដ៏ធំ របស់ពួកអ្នកដឹកនាំ នាំឲពួកនោះមានសម្បត្តិ ហើយ ផ្ញើ រូបិយបណ្ណ មកទុក នៅក្នុងធានាគារ នៅបរទេស ជាពិសេសនៅស្រុកបារាំង។

នៅឆ្នាំ ១៩៧០ មានការស្វែងរក នូវ ដំណោះស្រាយ ពិតប្រាកដ នៃ បរាជ័យសេដ្ឋកិច្ច។ ការពិភាក្សា គឺនៅក្នុងសំ

នួរថា តើត្រូវធ្វើ តាមទិសណា ? អ្នកខ្លះ យល់ឃើញថា ត្រូវមាន អនុស្ថានប័ន (orientation) ទូទៅ ជានយោបាយដែលអាចអោយប្រជារាស្ត្រគ្រប់ស្រទាប់ មាន សោមនស្សដោយ គ្រាន់តែ សាកល្បង ធ្វើឲបានប្រសើរឡើង នូវអ្វីដែលបានធ្វើរួចហើយ។ ចរន្តគំនិត មួយទៀត យល់ឃើញថា គឺ ត្រូវ ប្តូរ នយោបាយសេដ្ឋកិច្ច សង្គមនិយមទាំងមូលហើយ យក នយោបាយ សេរីនិយម មកជំនួសវិញ។ ពួកមានគំនិតនេះឯង ច្រើនជាពួកអ្នកស្តាំនិយម មើលឃើញ ថា វិនិយោគ នៃមូលធន បរទេស ឬ ជំនួយ នៃ សហរដ្ឋអាមេរិក ជា គម្នាស់មួយសំខាន់ ដើម្បី ដោះស្រាយ នូវវិបត្តិសេដ្ឋកិច្ចជាតិបើសិនជាមានការគ្រប់គ្រងម៉ត់ចត់។ ចរន្ត នោះ ជា មតិភាគច្រើន នៅស្រុកខ្មែរ នៅឆ្នាំ ១៩៦៦ ហើយហាក់បីដូចជាអាច ប្លុងចិត្ត សម្តេច សីហនុបាន តែផ្ទុយទៅវិញ នៅក្នុងសមាជជាតិ នៅមាត់ទ្វារឆ្នាំ ១៩៧០ គេឃើញថា ទ្រង់ បែរជាប្រឆាំងចេញមុខនឹង នយោបាយសេដ្ឋកិច្ចសេរី នៃ រដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលមានការគាំទ្រពីរដ្ឋសភាជាតិ។ គេអាចនិយាយបានថា សេរីកម្ម នៃ សេដ្ឋកិច្ច នៅឆ្នាំ ១៩៧០ ស្ទើកើតមានព្រមគ្នានឹង កក្តា នៃការរលំ នៃសម្តេច សីហនុ តែម្តង។

## វិបត្តិ សីលធម៌

វិបត្តិ សីលធម៌ មានជាទូទៅ នៅក្នុងស្រុកខ្មែរ តែ ទម្រង់ នៃ អកុសល វាមានកំរិតខុសគ្នា ទៅតាម មជ្ឈដ្ឋាន នៃ សង្គម ឬ វណ្ណៈក្នុងសង្គម។ ប្រជាកសិករ ដែលជា ថ្នាក់អ្នកក្រ ដឹងច្បាស់ថា ការជិះជាន់គ្មានមេត្តា ពីសំណាក់ រាជការគ្រប់ក្រសួង ព្រោះពួកគាត់ជា ជនរងគ្រោះផ្ទាល់នឹងអំពើនោះ។ អំពើពុករលួយ មាននៅគ្រប់ថ្នាក់ នៃអ្នករាជការគឺថា អ្នកធំស៊ីតាមធំ អ្នកតូចស៊ីតាមតូច។ អំពើពុករលួយនោះ មានរហូតនៅក្នុងអង្គការ កាកបាទក្រហម ដែលជា អង្គការមនុស្សធម៌ ក្លាយជាអង្គការ កៀបសង្កត់រាស្ត្រ។ នៅឆ្នាំ ១៩៧០ ការគាបគៀតនយោបាយ កាត់តែមានកំរិតកាន់តែតឹងតែងឡើង ដែល អនុញ្ញាត ឲប៉ូលិស នយោបាយ និង យោធា អាចចាប់ខ្លួន ជនណាដែល គេមានការសង្ស័យ ជូន គ្មានសមហេតុផលសោះ ថា ធ្វើសកម្មភាព វិទ្ធស្សនា ប្រឆាំងនឹង នយោបាយខ្ពង់ខ្ពស់របស់សម្ដេច សីហនុ។

ប្រជាកសិករ មានពិធុរក្រៃ តែទោះបីយ៉ាងណា ពួកគាត់មិនដាក់កំហុសដល់សម្ដេច សីហនុ ព្រោះ ពួកគាត់យល់ឃើញជាទូទៅថា សម្ដេច ជា កត្តបការៈ ប្រឆាំងនឹង ការបំពានដល់ពួកគាត់ ពីសំណាក់ ពួកមន្ត្រី។ ហើយ សម្ដេច សីហនុ ទ្រង់ប្រសប់ណាស់ នៅពេល សមាជជាតិម្ដងៗ

ទ្រង់ បញ្ឆោត និង ពង្រីង តាម សុរោហារ ចិត្តថ្លើមប្រជារាស្ត្រ ឲស្រឡាញ់ងប់ ដល់ព្រះអង្គ។
តែ នៅក្នុង មជ្ឈដ្ឋាន ពួកអ្នករាជការ និង អ្នកចេះដឹង, ស្ថានភាព វាខុសប្លែក ពី ស្ថានភាព នៃ ប្រជាកសិករ។ ក្រុមនោះ ស្ថិត នៅក្នុងប្រព័ន្ធដឹកនាំ ហើយ ទទួលបាន អត្ថប្រយោជន៍ ដោយសារ ពួកខ្លួនគ្មានជម្រើស តែ មាន បុគ្គល ឯកា មួយចំនួន បដិសេធ ចូលរួមចំណែក រកអត្ថប្រយោជន៍ សំរាប់អាត្មា ហើយ ដកខ្លួនចេញពី ប្រព័ន្ធដឹកនាំ ដោយបាន ផ្តន្ទាទោសវា នៅក្នុង អារម្មណ៍ ដ៏ជូរចត់ និង ហេវកម្លាំងថា សម្តេច សីហនុ និង ពួកអ្នកអបអមជិតស្និតនឹងទ្រង់ ជា អ្នកសម្របសម្រួលរួម ឲមាន ប្រព័ន្ធដឹកនាំ ពុករលួយ ជាទូទៅ ដោយ គ្មានទោសកំហុស អ្វីឡើយ។ ជាពិសេស បុគ្គលសីហនុ ទ្រង់ មានអភ័យឯកសិទ្ធិ ព្រហ្មទណ្ឌ សំរាប់ ការពារព្រះអង្គ នូវគ្រប់អំពើខុសច្បាប់ទាំងឡាយ ដែលព្រះអង្គបានប្រព្រឹត្ត ដោយផ្ទាល់ខ្លួនក្តី ឬ ដោយ បរិវា របស់ទ្រង់ក្តី។ នៅ ទីក្រុងភ្នំពេញ ដែលជារូបភាព នៃសង្គមទំនើបខ្មែរ ប្រែក្លាយទៅជាកន្លែងគ្មាន តម្លៃប្រពៃណីជាតិ ដោយសារ តម្លៃ លុយកាក់ និង ពុករលួយ វាជ្រាបចូល ទៅក្នុងសរសៃឈាមសង្គមទំនើបនោះ ដែលនាំអោយ យុន្តកម្ម នៃអំពើពុករលួយ វាប្រព្រឹត្តទៅ កាត់តែប្រសើរឡើង ព្រោះ វាមាន ពួកមន្ត្រីពុករលួយ និង ក្រុមហ៊ុនបរទេស ស៊ុមគ្រលុំ ថែមទៅ

ទៀត ដើម្បី នាំគ្នាលួចជំនួយបរទេសគ្រប់វិស័យ ជួនកាលមានការសមគំនិត ពីប្រទេសផ្តល់ជំនួយថែមទៀត ក្នុងគោលបំណង រក អតិថិជន សំរាប់គេ ដែលបង្កើតរឿងអាស្រូវ គ្រប់ស្ថាប័នរដ្ឋ។ ជួលកាល មានការព្រមព្រៀង ពីសម្តេច សីហនុ ដល់ អ្នកស៊ីសំណូក ដែលជា ដៃគូនយោបាយ ដើម្បី សម្រុះសម្រួល ទំនាស់នយោបាយ។ សម្បត្តិ មានបានពីអំពើពុករលួយ របស់ពួកស៊ីសំណូក ជួនកាល គេយក ទៅដូរជា រូបិយប័ណ្ណ យកទៅដាក់ ក្នុងធនាគារ នៅបរទេស, ជួនកាល គេយកទៅសង់ ភូមិគ្រឹះ ឆើតឆាយ ដើម្បី ជួលឲ ពួកអ្នកជំនាញបរទេស បានប្រាក់ឈ្នួលផ្ទះថ្លៃបំផុត។ តែបន្ទាប់ពីឆ្នាំ ១៩៦៣, ការបដិសេធ នៃ ជំនួយអាមេរិកាំង នាំឲបាត់ នូវធនធានសំខាន់ នៃប្រព័ន្ធនេះ ដូចយ៉ាង ពួកអ្នកជំនាញបរទេស គេវិលត្រឡប់ទៅប្រទេសគេវិញ ដែលនាំ អ្នកមានវិទ្យាជួល ពិបាករក អ្នកជួល។

ជាតិរូបណីយកម្ម តាមផម្នូតា វាជាឱកាសល្អមួយ សំរាប់លាងសំអាត នូវប្រព័ន្ធពុករលួយ តែវា គ្រាន់តែមានអនុភាព ត្រឹមតែ ការផ្លាស់ប្តូរ មន្ត្រី គ្មានសមត្ថភាព ឬ ស៊ីសំណូក ដាក់ មន្ត្រី មាន សមត្ថភាព ផ្នែកបច្ចេកទេសជំនួស តែប៉ុណ្ណោះ ព្រោះថាអកុសល វាដុះស្លែ នៅក្នុងអំណាច ថ្នាក់ដឹកនាំ ជាន់ខ្ពស់រួចទៅហើយ។

គួរលើកជាឧទាហរណ៍ នៃអំពើពុករលួយសំខាន់ៗមួយចំនួន មកបង្ហាញ ដូចជា : ការជំនួញ នៃ ការបង្ហូរទឹកនៅរោគចក្រ ផ្ញើបីយ៉ែរ នៅកំពុងសោម ដែលមានគ្រួសារក្មេង របស់សម្តេច សីហនុ ជាអ្នកស៊ីសំណូក- ការជំនួញ ទឹកដោះគោខាប់ ដែលមាន ក្រុមមន្ត្រី ដឹកនាំ នៃភណ្ឌាគាររដ្ឋ ជាអ្នកស៊ីសំណូក- ការជំនួញ ខ្ទឹមស នាំចូលពីស្រុកចិនដីគោក ដែលមាន អតីតនាយករដ្ឋមន្ត្រី ជាអ្នកស៊ីសំណូក- រត់គយ ទំនិញ គ្រប់បែបយ៉ាង នៅតាមព្រំដែន ខ្មែរ-យួនខាងត្បូង ជាពិសេស រត់គយ អង្ករ ផ្តល់ឲពួកយៀកកុង ដែលមាន ពួកឧត្តមមន្ត្រីមួយក្រុម និងរាជវង្សានុវង្ស ជាអ្នកស៊ីសំណូក ឬ ជាអ្នករត់គយតែម្តង- ការជំនួញ ក្រណាត់ ដែលរដ្ឋសភា យកមកពិនិត្យ ព្រោះមាន ការចូលរួម ពីសំណាក់ ឥស្សរជន ជាសមាជិក នៃរាជរដ្ឋាភិបាល ហើយជា បងថ្លៃ របស់សម្តេច សីហនុ។

អំពើពុករលួយ ត្រូវបានខ្មែរលើកមកនិយាយ និង ខ្សឹបពេញនគរ ហើយហាក់បីមាន ការប៉ុនប៉ង ជាទូទៅ ចង់ដោះស្រាយបញ្ហា ព្រោះវាជា មហាភ័យជាតិ។ ព្រឹត្តិប័ត្រ បរិដ្ឋាភិបាល បានចុះផ្សាយ នូវសុន្ទរកថា របស់សម្តេច សីហនុ ដែលទ្រង់បានរិះគន់ អំពី ការស៊ីសំណូក។ តែមតិខ្មែរមួយចំនួន យល់ឃើញថា ព្រះអង្គខ្លួនឯង ក៏មានការចូលចំណែកនោះដែរ។ ព្រះរាជអនុញ្ញាត ឲបើក កាស៊ីណូ នៅភ្នំពេញ នៅឆ្នាំ ១៩៦៨ នាំបង្កើត នូវអំពើ អសីលធម៌

គ្រប់បែបយ៉ាង ដែលនាំឲ ឥស្សរជន ជាអ្នកស្នេហាជាតិ មួយចំនួន បាត់ នូវសេចក្ដីទុកចិត្ត លើព្រះអង្គ។ បន្ថែមទៀត ចាប់ពីឆ្នាំ ១៩៦៦ សកម្មភាព មួយចំណែកធំ របស់សម្ដេច សីហនុ គឺ ថតកុន។ ទ្រង់ យកមធ្យោបាយរដ្ឋ មកប្រើ សំរាប់បំរើ ព្រះរាជហឫទ័យផ្ទាល់ខ្លួន។ មួយវិញទៀត នរណាក៏យល់ថា ខ្សែភាពយន្ត ដែលសម្ដេច សីហនុ ជាអ្នកបង្កើត, អ្នកដឹកនាំរឿង និង ដើរតួឯកខ្លួនឯង មិនសូវមាន គុណភាពសិល្ប: និង ភាពសមសួន នោះឡើយ។ ចំពោះ អ្នកឆ្វេងនិយម ខ្សែភាពយន្ត របស់សម្ដេច សីហនុ វាបានលាតត្រដាង នូវរូបភាព នៃវណ្ណៈអ្នកដឹកនាំ រស់នៅក្នុង ប្រណិតភាព និង អសីលធម៌។

អសីលធម៌នេះឯង ដែលនាំអោយមានពាក្យ គេនិយាយចំអកថា កាសីណូ, កាកបាទក្រហម និង កុន ជា ស្ដុំបី សំរាប់ទ្រទ្រង់ ប្រព័ន្ធ នៃសីហនុនិយម។ តែ ការចំអកនេះ វាលាក់បាំង នូវ ការនឿយណាយ និង សេចក្ដីអម៉ាស់មុខ នៃជនខ្មែរទាំងឡាយ ដែលខ្លួនមាន អារម្មណ៍ដឹងថា ការនិយាយចំអកនេះ វាគួរឲអស់សំណោចទៅវិញចំពោះខ្លួន ព្រោះខ្លួនឯងតែម្ដង ជាជនរងគ្រោះ។

**វិបត្តិ ស្ថាប័ន**

វិការភាគជាទូទៅ នៃរចនាសម្ព័ន្ធ រដ្ឋបាល, ហិរញ្ញវត្ថុ និង ធម្មនុញ្ញ វាស្ទើគ្មាន ឧបាយណាមួយ អាចទប់ទល់វាបាន នោះឡើយ។

ប៉ុន្តែ ពីដំបូងមក ស្រុកខ្មែរ មាន សមតា ល្អមគ្រប់គ្រាន់ សំរាប់ធ្វើការ នៅក្នុង រចនាសម្ព័ន្ធ ជាមរតក នៃអាណានិគមបារាំង សំរាប់ដំណើរការ នៃរដ្ឋទំនើបនៅពេល នោះ។ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ ជាមូលដ្ឋាន សំរាប់ ពង្រឹង និង រៀបចំ បន្ថែម ជាស្ថាប័នរដ្ឋ អោយសមស្របទៅតាម សេចក្តីត្រូវការ របស់ប្រជាជាតិខ្មែរ នៅក្នុង លទ្ធិប្រជាធិបតេយ្យសេរី។ តែនៅឆ្នាំ ១៩៥៦, សម្តេច សីហនុ ទ្រង់ធ្វើការ កែទម្រង់ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ អោយ ចុះសំរុងនឹង នយោបាយ របស់ព្រះអង្គ ដែលមានចលនាសង្គមរាស្ត្រ និយម ជាម៉ាស៊ិន ដឹកនាំ ដែលទ្រង់ទុកជា ចលនាសាមញ្ញ មួយ ដែល ប្រជារាស្ត្រ អាចងាយស្រួលយល់បាន អំពីគោល វិធី នៃដំណើរការ នៃវា។

តែបន្តិចម្តងៗ មក ម៉ាស៊ិន នៃចលនាសង្គមនោះ វា ទន្ទ្រានយកអំណាចរដ្ឋបាល តាំងពីថ្នាក់ឃុំ រហូតដល់ ខេត្ត ព្រោះ មន្ត្រីរាជការគ្រប់ថ្នាក់សុទ្ធជាសមាជិក នៃ ចលនា ដែលនាំអោយរដ្ឋបាល លែងមានដំណើរការធម្មតា ហើយ អាថ្មាធរ បង្ហាញ នូវអនានុភាព អាចជានា នូវ

ភាគកម្មមាំមួន នៃប្រជាជន ក្នុងកិច្ចការសាធារណៈ[12]។ ការណ៍នេះ ពង្រឹង នូវមជ្ឈការ នៃអំណាចចលនាសង្គម ហើយ តាមផ្លូវនេះឯង ដែល អំណាច នៃវណ្ណៈដឹកនាំ កាន់តែពង្រឹង ជាអន្លោចៗ ក្នុងដំណើរការ នៃគុណភាព មិនល្អ ដូចយ៉ាង : ការរំលោភអំណាច ជាមូលដ្ឋាន នៃ បច្ចេកទេស នៃការគ្រប់គ្រង, ការកេងប្រវ័ញ្ច លើប្រជារាស្ត្រ ដើម្បី បំបានអាត្មា ជាគោលដៅ។

បរាជ័យ ដោយអាការពិសេស យ៉ាងធ្ងន់ គឺមាន នៅក្នុង បណ្ដាខេត្រទាំងឡាយ ដែលបានបង្កើតថ្មី។ បរាជ័យនោះ គឺ បញ្ហា នៃ បូរណកម្ម នៃប្រជាជនរស់នៅលើភ្នំ សព្វអន្លើ ក្នុងប្រទេស តែបញ្ហា ពិសេស គឺមាន នៅ តំបន់ ព្លសាន ក្នុងខេត្រ រតនគិរី និង មណ្ឌលគិរី ព្រោះ ចៅហ្វាយខេត្រ តែងតាំង មាន អារម្មណ៍ ថាជា ទណ្ឌកម្ម ដល់ខ្លួន ត្បិត ខ្លួន ត្រូវទៅរស់នៅ ក្នុងព្រៃភ្នំ ដាច់សង្វែងពី សង្គមអារ្យៈ ហើយអ្នករាជការខេត្រ មិនសូវមាន សមត្ថភាព និង ច្រើនតែបំពានទៅលើ ប្រជាជន។

ហើយអាក្រក់ទៀត គឺក្នុងអំឡុងឆ្នាំ ១៩៦៥-៦៦, រចនាសម្ព័ន្ធ នៃរដ្ឋបាលទាំងមូល វាគ្រេចក្រោមអនុភាព នៃ ប្រតិបត្តិមួយចំនួន អម្បាលដូច : ១. ការតែងតាំង នាយទាហានជាន់ខ្ពស់ ជា ចៅហ្វាយខេត្រ នៅខេត្រថ្មីៗ ដែល

12 បញ្ហានេះ វាមានជាទូទៅនៅក្នុង តតីយលោក។
*(note de bas de page - suite)*

នាំឲ ឯកភាព នៃរដ្ឋបាល នៃព្រះរាជាណាចក្រ បាក់បែក ជាចំណង់ ធ្វើកងទ័ព ឃ្លាន នូវនយោបាយ-រដ្ឋបាល[13] ដែលនាំឲ រដ្ឋបាលកណ្តាល និង ក្រសួងមហាផ្ទៃ មានអារម្មណ៍ ថា គេ ហូតអំណាច របស់ខ្លួន ផ្តល់ទៅឲ ក្រសួងការពារជាតិ។ ២. ការតែងតាំង ព្រះរាជប្រតិភូ ទីក្រុង ដាក់នៅក្រោមការត្រួតត្រាផ្ទាល់ នៃ សម្តេច សីហនុ ហើយ លែងនៅក្រោមអំណាច រដ្ឋាភិបាល។ ជួនកាលទៀត ព្រះរាជប្រតិភូ ត្រូវបាន សម្តេច សីហនុ ប្រគល់ឲធ្វើ បេសកកម្ម កិច្ចការរាជការ គ្មានមានកំរិតសមត្ថកិច្ច រដ្ឋបាល ច្បាស់លាស់ ដែលជាប្រភព នៃទំនាស់ ជាមួយ អំណាច នៃរដ្ឋបាលកណ្តាល ពោលថា ជាមួយ ក្រសួងពាក់ព័ន្ធ។ ការមិនគោរពច្បាប់រដ្ឋបាល នេះ ជាដំបូង វាគ្មាន ចេតនា នយោបាយ ទេ។ តែក្រោយមក គឺចាប់ពីឆ្នាំ ១៩៦៦ ក្នុងទំនាស់ រវាង រដ្ឋាភិបាល នឹង សម្តេច ព្រះប្រមុខរដ្ឋ ដែលជា ទំនាស់កំបាំង ដូច្នេះ ការតែងតាំង ព្រះរាជប្រតិភូ ចំពោះសម្តេច សីហនុ វាក្លាយទៅជា មធ្យោបាយនយោបាយ របស់ទ្រង់ សំរាប់ លោតផ្លោះលើ អំណាច របស់រដ្ឋាភិបាល។

[13] Politico-administratif។
*(note de bas de page - suite)*

ទំនាស់ចម្បង ដែលអាចទុកជា សង្គ្រាម រដ្ឋបាល គឺកើតមកពី រដ្ឋាភិបាល[14] បង្កើត ការិយាល័យ ប្រជាសង្គ្រោះ[15] ក្នុង ភ័យអាសន្នទឹកលិច នៅគ្រប់ខេត្ត ដើម្បី ដោះស្រាយជាប្រញាប់ និង ផ្ទាល់នៅទីកន្លែង ដល់គ្រប់បញ្ហា ដែលប្រជាជន បានជួបប្រទះ។ ការិយាល័យនោះ ទទួលបានជោគជ័យ ជាមួយនឹង ប្រជាជនរងគ្រោះ តែជោគជ័យនោះ ចំពោះ សម្តេច សីហនុ វិញ ទ្រង់ ទុកវាជា ការគំរាមដល់ អំណាច របស់ទ្រង់។ នៅពេលនោះដែរ ពួក កុម្មុយនិស្ត ក៏ទុក ជោគជ័យនេះ ជា គ្រោះថ្នាក់មួយ ដល់ខ្លួន ក៏សម្រេច ឆ្លើយតប តាម ការញុះញង់ ប្រជាជន រស់នៅភូមិសំឡូត ឲបះបោរ ប្រឆាំងនឹង រដ្ឋាភិបាល។

លើឋាន ហិរញ្ញវត្ថុ, បាតុភូត នៃ ភាពរលួយ គឺមានកាន់តែច្បាស់ឡើង។ ជាសង្ខេប គឺ : អន្តរធាន នៃ ថវិកាជាតិ ពិប្រាកដ លើកលែងតែ ថវិកាប្រតិបត្តការ ដែលការអនុវត្តន៍ ស្ថិតនៅត្រឹមតែ ការគ្រប់គ្រង ហិរញ្ញវត្ថុ បែបចាត់ការរហ័ស។ សំណង់បរិក្ខារ, ការវិនិយោគ, ចំណាយសង្គមកិច្ចទាំងឡាយ បានផនធានមក ឬក៏ ពី វិភាគទាន នៃអ្នកស្មគ្រជួយ ឬក៏ ពី ជំនួយ របស់សម្តេច សីហនុ តាមរយៈ សន្និធិជួយជាតិជនុបត្ថម្ភ[16] និង សន្និធិជួយឋបនាការជាតិ[17]។

[14] រដ្ឋាភិបាល នៅពេលនោះ (ឆ្នាំ ១៩៦៦) ដឹកនាំដោយ លោក លន់ នល់។
[15] B.A.A.I : Buraux d'Aide et d'Assistance à la population.
[16] Caisse nationale d'entraide.
[17] Caisse d'édification nationale.

រីឯ ការងារសង្គមតូចៗ គឺ កាកបាទក្រហម ជា អ្នកផ្តល់ជំនួយ។ សន្និថ្ឋ័យទាំងឡាយនោះ ទទួលបានអំណោយជាច្រើន ពី ឯកជន គ្រប់មជ្ឈដ្ឋាន ស្មគ្រជួយ, ជំនួយ ពីរដ្ឋ និង សហគ្រាសរដ្ឋ។ ដើម្បី រក្សា ដំណែង ពួក ប្រធានអគ្គនាយក នៃ សហគ្រាសរដ្ឋ ត្រូវចាំបាច់ ផ្តល់ជាកម្រៃទូលាយ ដល់ សន្និថ្ឋ័យ ដែលបានរាប់ឈ្មោះខាងលើ។

លើឋាន ធម្មនុញ្ញ សម្តេច សីហនុ ពីដំបូង ទ្រង់ ចេះប្រមាណ មិនភាន់ប្រែ នូវស្ថាប័ន ប្រជាធិបតេយ្យ ឆ្នាំ ១៩៤៧ ទោះបី ទ្រង់ មិនពេញ ព្រះហរទ័យនឹងវាក៏ដោយ។ ទ្រង់គ្រាន់ តែបន្ថែម និង ប្តូរចំណុចខ្លះៗ តាមការពិសោធន៍ អោយវាស្របទៅនឹង នយោបាយ របស់ទ្រង់។ តែ ចាប់ពីឆ្នាំ ១៩៥៥ មក ក្រោយពីសង្គម ទទួលបានជ័យជំនះដាច់មុខក្នុងការបោះឆ្នោត, វិសោធនកម្មរធម្មនុញ្ញ របស់សម្តេច សីហនុ វាប៉ះពាល់ដល់ខ្លឹមសារ នៃរដ្ឋធម្មនុញ្ញតែម្តង គឺ ទ្រង់ បានប្តូរ នូវដំណើរការ នៃប្រជាធិបតីសភា អោយទៅជា ប្រជាធិបតីផ្ទាល់ (démocratie direct)។

គេអាច ចង្អុលចរិកលក្ខណ: នូវ ទ្រឹស្តីថ្មី របស់សម្តេច សីហនុ ជា បីលក្ខណ:សំខាន់ៗ។ ទី១ នៅមានការរស់នៅបាន នៃ របបតំណាង ដែលមានតម្លៃ ជាការធានា ដល់ ការបោះឆ្នោត តែ ក្នុងនោះ គ្មានជម្រើស សេរី ពិត តែ សម្តេច សីហនុ បិនប្រសប់ លៃរើស បេក្ខជន តំណាងរាស្ត្រ

ដែលជាសមាជិក សង្គម ឲប្រជារាស្ត្រមើលឃើញថា មាន សមតា ត្រឹមត្រូវ។ ទី២ ការឃោល រវាងប្រព័ន្ធ សភា ដែល មាន រដ្ឋាភិបាល ជាអ្នកទទួលខុសត្រូវ និងប្រព័ន្ធ ប្រធានាធិបតីនិយម ជាការណ៍ (de fait) ដោយសារ អំណាចទាំងឡាយ វានៅក្នុងកណ្តាប់ដៃ សង្គម ទាំងអស់ ពោលថា នៅក្នុង សណ្តាប់ដៃ សម្តេច សីហនុ ជាប្រមុខរ ដ្ឋ។ ទី៣ គឺ ប្រព័ន្ធ នៃ ប្រជាធិបតីផ្ទាល់ តាមការបង្កើត ស្ថាប័ន ធម្មនុញ្ញ ពីរ គឺ សមាជជាតិ និង ប្រជាមតិ។

តែក្រោយមក ប្រព័ន្ធ នោះ ស្គាល់ នូវការវិវត្តន៍ ជាការណ៍ ធ្វើឲលប់ នូវភាពជាប់លាប់ និង ខ្លឹមសារ នៃ លទ្ធិប្រជាធិ បតេយ្យ។ ក្នុង រយៈពេល សមាជជាតិ វាក្លាយជា វេទិកា សម្រាប់ សម្តេច សីហនុ ទ្រង់សំដែង នូវមនោវិក័តិ នយោបាយ របស់ទ្រង់ ដែលវាស្ទើរតែក្លាយភ្លាមជាច្បាប់។ ដូច្នេះ សមាជជាតិ វាក្លាយរហ័ស ទៅជា ឧបករណ៍ នៃ ឧបាយបញ្ឆោត របស់សម្តេច សីហនុ ដែលនាំអោយវា បាត់បន្តិចម្តងៗ នូវតម្លៃដើម របស់វា។

រដ្ឋសភា របស់ សង្គម បាត់ នូវ ភាពតំណាង។ តែនៅឆ្នាំ ១៩៦៦ ដែលជាឆ្នាំដែល សម្តេច សីហនុ ធ្វើសេរីកម្ម នូវការ បោះឆ្នោត ដោយយកគោលការណ៍ នៃ បេក្ខភាព សេរី នៅក្នុងក្របខណ្ឌ សង្គម។ សេរីកម្មនេះ បណ្តាឲមាន កម្ម វិបាកដល់ សម្តេច សីហនុ ព្រោះ វានាំកើត នូវកម្លាំង

នយោបាយស្វយ័ត នៅរដ្ឋសភា ដែលជាកម្លាំង មាន ទំនាស់ផ្ទាល់នឹងព្រះអង្គ។ នៅចំពោះមុខ សញ្ញានេះ សម្តេច សីហនុ ទ្រង់ បាត់ នូវសេចក្តីឈ្លាតវៃនយោបាយ, ទ្រង់គិតតែ រកមធ្យោបាយ ប្រឆាំងយកឈ្នះដាច់ខាត នឹងអ្វី ដែលទ្រង់ទុកជា ការគំរាម ដល់ព្រះអង្គ ដូចយ៉ាង ការបង្កើត បរិរាជរដ្ឋាភិបាល ប្រឆាំងនឹង រាជរដ្ឋាភិបាល កើតចេញពី រដ្ឋសភា - បង្កើត គណកម្មការ ធ្វើ អង្កេត លើសកម្មភាព រាជរដ្ឋាភិបាល - តែងតាំង ព្រះរាជប្រតិភូ ជាអាចិ៍។ ដូច្នេះ បរិរាជរដ្ឋាភិបាល ក្លាយជា អង្គការ ប្រឆាំងនឹង រាជរដ្ឋបាលពេញច្បាប់ ជួនកាលរហូតដល់ ទៅជំទាស់ចំពោះនឹង សេចក្តីសម្រេច របស់រាជរដ្ឋាភិបាល តែម្តង។

នៅឆ្នាំ ១៩៧០, ស្ថាប័នជាតិ វាគ្រាន់តែជា មុខផ្ទះខ្មែរ តែ នៅក្រោយផ្ទះ ដែលគេមើលមិនឃើញ វាមានការប្រយុទ្ធ នយោបាយ នៅក្នុង របបសក្តិភូមិ រវាង ស្តេច នឹង នាម៉ឺនធំ នៅក្នុង ព្រះរាជាណាចក្រ។

## វិបត្តិ នយោបាយ

យើងលើក ប្រធានបទមួយ ដើម្បីសង្ខេប អំពីនយោយបាយ ផ្ទៃក្នុង របស់សម្តេច សីហនុ ចាប់ពីឆ្នាំ ១៩៥៤ ដែលទ្រង់ អោយឈ្មោះថា ‹នយោបាយ បង្រួបបង្រួម ជាតិ›។ នយោបាយនេះ គឺមានគោលដៅ ក្នុងក្របខណ្ឌ

សង្គម ប្រមូល ខ្មែរអ្នកជាតិនិយម ទាំងឡាយ ដែល មិន ចង់ ចូលរួមសកម្មភាព ក្នុង គណបក្សនយោបាយ។

គំនិត បង្រួបបង្រួមជាតិនេះ ចាប់មានកំណើត ពីឆ្នាំ ១៩៥២ ដែលជាចម្លើយនឹង តម្រេកអំណាច របស់សម្ដេច សីហនុពីរយ៉ាង បន្ទាប់ពីព្រះអង្គ មានចំណាប់អារម្មណ៍ ថា : ទី១ គឺ ត្រូវធ្វើភ្លាម ជា កលយុទ្ធ នយោបាយ គឺត្រូវ រំលាយ នូវឆាកនយោបាយ នៃគណបក្សនយោបាយ ចំណាស់ទាំងឡាយ ជាពិសេស គឺ គណបក្សប្រជាធិបតេយ្យ ដែល បន្ទាប់ពីឆ្នាំ ១៩៤៧ គណបក្សនេះ បានបង្ហាញ នូវ ភស្តុតាង នៃអសមត្ថភាព និង ខ្វះ នូវបក្ខភាព ឬ ចាស់ ទុំនយោបាយ របស់ខ្លួន។ ទី២ គឺ ធ្វើសំរាប់ រយៈពេលវែង ហើយមានខ្លឹមសារ ជាជម្រៅ : គឺ ជៀស កុំឲមាន ការប្រេះ ជាជម្លោះនយោបាយ រវាង ពួកអ្នកឆ្វេងនិយម មាន និន្នាការ មាក្ស ឬ កុម្មុយនិស្ត ដែលជា ពួកអតីត នៃ ចលនា ខ្មែរយៀកមិញ នឹងពួក អ្នកជាតិនិយម មាន និន្នាការ ស្តាំនិយម ដែលមាន សុភចិត្តនឹង (favorable) លោកសេរី។ ចំពោះសម្ដេច សីហនុ ការរួបរួម នៃ ពួកទាំង នោះ ជា លក្ខខណ្ឌ ចាំបាច់ដើម្បីរក្សា សន្តិភាព នៅក្នុង ប្រទេស។ សន្តិភាពនេះ ត្រូវការការអះអាង នៃ នយោបាយ អព្យាក្រិត្រ នាំបង្អក នូវការបន្ត នៃបញ្ហា អន្តរជាតិ នៅស្រុកខ្មែរ តាមសង្គ្រាមត្រជាក់ រវាង លោក សេរី និង លោកកុម្មុយនិស្ត។ ដូច្នេះ ការរួបរួមជាតិ វានាំ

ជៀសវៀង នូវការបាក់បែកខ្មែរនិងខ្មែរ កើតពីបញ្ហាទាំងឡាយនោះ។ ការពិត សង្គម គ្មានប្រាថ្នា ផ្តល់ជូនទ្រឹស្តី ដល់ ពួកអ្នកស្តាំនិយម ដែលមាន សុភចិត្តនឹង អាមេរិកាំង និង ពួកមាក្ស ដែលយកបដិវត្តន៍វណ្ណៈជាគោលការណ៍, តែ សង្គម មានទំនោរ ធ្វើយ៉ាងណា កុំឲមានការប៉ះទង្គិចគ្នា រវាងក្រុមទាំងពីរ ដែលនឹងអាចនាំបង្កើតឲមាន ជាកម្លាំងតស៊ូមនោគមវិជ្ជា រៀបចំឡើងជាអង្គការ។ សង្គម ទប់កុំឲមាន ការប្រយុទ្ធបក្សពួក កើតឡើងបាន នៅក្នុងចលនា ហើយ ដាក់កំរិតដល់ ក្រុមនិមួយៗឲគោរព នូវអាជ្ញាកណ្តាល របស់សម្តេច សីហនុ។

នៅអំឡុងឆ្នាំ ១៩៥៤-១៩៦៧, សម្តេច សីហនុ ទ្រង់បានជ្រើសរើសវិធីសាស្ត្រដ៏ប្រសប់ គឺ ទ្រង់ ដើរតួនាទី រវាង ចរន្តទាំងពីរ, យោល ជូនកាល ទៅខាងម្ខាង ជូនកាល ទៅខាងម្ខាងទៀត ហើយ អនុវត្ត នូវកូនប្រយោល (contre-poids)។ តែទ្រង់ វាយប្រហារ ដល់ឥស្សរជននយោបាយមួយចំនួន គ្មានហេតុផល ដែលទ្រង់ទុកជាគ្រោះថ្នាក់ដល់អំណាច របស់ទ្រង់ ដោយចោទថា រួមគំនិតក្បត់ ជាមួយបរទេស ដើម្បី ទ្រង់ អាចកំចាត់ចោល ដូចជា ករណីលោក សម សារី ។ល។ ចំណែក ខាងឆ្វេងនិយមវិញ, ទ្រង់មាន ល្បិច ល្បិតល្បុន ដូចយ៉ាង ទ្រង់ មិនដែលហាម គណបក្សប្រជាជន ជា បក្សកុម្មុយនិស្ត អោយមានអត្ថភាពជា គណបក្សនយោបាយពេញច្បាប់ តែ ទ្រង់ បង្កើត

ទំនាស់ជានិច្ច ជាមួយ ក្រុមអ្នកដឹកនាំបក្សនេះ គ្រប់ឱកាសសាធារណៈ,ជួនកាល ទ្រង់ ផ្តន្ទាទោស ពួកនោះ ផ្ទាល់តែម្តង តាមការធ្វើសម្ភាជខ្ទាប់ខ្លួន តាមល្បិច តិច ឬច្រើន ទៅលើពួកនោះ។ ជួនកាល អញ្ជើញ វរជនក្បាលទូក ឲមកកាន់ដំណែង ក្នុងរដ្ឋាភិបាល តែ ដកចេញវិញ យ៉ាងប្រញាប់ ដូចជាករណី លោក ខៀវ សំផន និង ហ៊ូ យន់ ដើម្បីកុំអោយពួកនោះមាន ឥទ្ធិពលខ្លាំង ក្នុងឆាកនយោបាយជាតិ។ នៅឆ្នាំ ១៩៦៣, ទ្រង់ បដិសេធ នូវជំនួយអាមេរិកាំង នាំឲ ពួកឆ្វេងនិយម ទុកជាជ័យជំនះរបស់ពួកគេ តែ ភ្លាមៗ ទ្រង់ រាប់អានជាថ្មី នូវនយោបាយស្តាំនិយម ព្រោះ ទ្រង់នៅមានគោលបំណង រក្សាសមតានៃនយោបាយ របស់ព្រះអង្គ លើឆាក អន្តរជាតិ, តែនយោបាយក្នុងប្រទេស របស់ទ្រង់ គេឃើញបែរកាន់តែខ្លាំងឡើង ទៅរក មហាអំណាចចិនកុម្មុយនិស្ត។ តែនៅឆ្នាំ ១៩៦៧, វាមានកើតជម្លោះ ខ្មែរ-ចិន ដោយសារ ពួកខ្មែរកុម្មុយនិស្ត និយមចិន ធ្វើអំពើឆ្គង មកក្នុងនយោបាយផ្ទៃក្នុង ដែលនាំ សម្តេច សីហនុ កាន់តែមិនទុកចិត្ត ពួកឆ្វេងនិយម ថែមទៀត។

ល្បែងនយោបាយរបស់សម្តេចសីហនុ ធ្វើជា កូនប្រយោលរវាង ពួកអ្នកស្តាំនិយម និង ឆ្វេងនិយម វាមានដំណើរការនៅអំឡុងឆ្នាំ ១៩៦៦-៦៧ មកដល់ដែន កំណត់របស់វា ព្រោះ ការធ្វើសេរីកម្ម នៃការបោះឆ្នោត រើសតំណាងរាស្ត្រ

នៅឆ្នាំ ១៩៦៦ ដែលជាទំនើង របស់សម្ដេច សីហនុ វានាំបង្កើត ទិន្នការណ៍ថ្មី គឺ ប្រសូតិបាន នូវរដ្ឋសភាជាតិ មានពណ៌ ជារដ្ឋសភា នៃអ្នកស្ដាំនិយម។
មតិខ្លះ យល់ឃើយថា សម្ដេច សីហនុ ទ្រង់ធ្វើបែបនេះ គឺនៅក្នុងគោលដៅ ដើម្បីទម្លាក់ តំណាងរាស្ត្រ ឆ្វេងនិយមមានប្រជាប្រិយ តាមការបោះឆ្នោតសេរី ដូចជា លោកខៀវ សំផន, ហ៊ូ យន់ និង ហ៊ុយ នឹម។ មតិនេះ បើវាពិតជាផែនការកលល្បិច របស់សម្ដេច សីហនុ, លទ្ធផល វាមិនដូចការចង់បាន របស់ទ្រង់នោះឡើយ ព្រោះថា អតីតតំណាងរាស្ត្រ ទាំងបីរូបនោះ ជា បេក្ខជន ជាថ្មី ត្រូវបានប្រជាជន ក្នុង មណ្ឌលបោះឆ្នោត របស់ពួកគាត់ បោះឆ្នោតឲគាត់ យ៉ាងច្រើនបំផុត ហើយ ពួកអ្នកស្ដាំនិយមទទួលបានជោគជ័យ ដោយ ដណ្ដើមបាន នូវអាសនៈ ជាច្រើន នៅក្នុងរដ្ឋសភា។ ការជ្រើសរើស លោក លន់ នល់ដោយ រដ្ឋសភាថ្មី ជា នាយករដ្ឋមន្ត្រី នាំឲមាន ការសើរើនៃនយោបាយសេដ្ឋកិច្ចមួយចំនួន របស់សម្ដេច សីហនុ។ ចំពោះ ពួកអ្នកឆ្វេងនិយម ទិន្នការណ៍ថ្មីនេះ វាគំរាមផ្ទាល់ដល់គោលនយោបាយរបស់ពួកខ្លួន។ ត្រូវដឹងដែរថា ពួកកុម្មុយនិស្តខ្មែរ តែងតែទុក នយោបាយ បង្រួបបង្រួមជាតិ របស់សម្ដេច សីហនុ ជា បដិបដិវត្តន៍ របស់ពួកខ្លួន។ ក្រោយពី មានសម្ពាធហិង្សា ពីសំណាក់ សម្ដេច សីហនុ ចាប់ពីឆ្នាំ ១៩៦៧ មកលើពួកខ្លួន ដូចយ៉ាង : ឃាតកម្ម

នយោបាយ ទៅលើ សមាជិកបក្ស ជំរុញឲ្យ គស្សរជន មួយចំនួន រត់ចូលព្រៃ ដើម្បី ធ្វើការតស៊ូ បែបថ្មី គឺ ការតស៊ូប្រដាប់អាវុធ។ ជម្រើសនេះ នាំឲសម្តេច សីហនុ បាត់ នូវកូនប្រយោល សំរាប់ល្បែង នយោបាយ របស់ទ្រង់ នៅចំពោះមុខ ពួកអ្នកស្តាំនិយម ដែលកាន់តែសកម្មឡើង ហើយមាន សុភាចិត្តនឹង នយោបាយ បង្រ្កាប ពួកកុម្មុយនិស្ត តាមមធ្យោបាយក្តៅ ព្រោះយល់ឃើញថា អង្គការនេះ ជា អង្គការ រណបបក្សកុម្មុយនិស្តយួន។

**លើបាន យោធា**

សន្តិភាពខ្មែរ នៅឆ្នាំ ១៩៧០ មានន័យ មិនដាច់ខាតនោះឡើយ។ បន្លូក នៃ អសន្តិសុខ ចាប់ផុះចេញ ហើយវានឹងអាច ផុះរាលដាល ដែលនឹងនាំ ប្រជាជាតិ ជួបប្រទះនឹងបញ្ហាគ្រប់បែបយ៉ាង។ វាក៏មានកើតមែន ក្រោយពីថ្ងៃទី ១៨ មិនា។ គេបែងចែក កន្លែងឈះភ្លើងខ្លាំង ៤កន្លែង : បញ្ហា ជាមួយយួនខាងត្បូងនៅតាមព្រំដែន, ចលនាខ្មែរសេរី, ការបះបោរនៅក្នុងប្រទេស និង ការរុកចូល នៃ ពួកយៀកកុង មកក្នុងដែនដីខ្មែរ។

**១. បញ្ហា ជាមួយយួនខាងត្បូង**

គឺជា ការទទួលថ្មបាក់ ពីសង្រ្គាម នៅ ស្រុកយួន។ ឧប្បត្តិហេតុ ទី១ គឺកើតឡើង នៅ ស្រុក បូកែវ នៅឆ្នាំ ១៩៥៨។ បន្ទាប់មក វាកាន់តែមាន បន្តៗទៀត គ្មានដាច់។

ជូនកាល វាគឺជា ការលុកលុយ តូចៗមួយចំនួន, ការរំលោភ ព្រំដែន មិនធ្ងន់ធ្ងរ ; ជូនកាល ជា ឧប្បត្តិហេតុ អស្ចារ្យ : ជាការទំលាក់គ្រាប់បែក លើភូមិ ចន្ទទ្រា នៅឆ្នាំ ១៩៦៦, នៅភូមិ ដាក់ដាំ នៅឆ្នាំ ១៩៦៩។ ខាង អាមេរិកាំង និង យួនខាងត្បូង គេអះអាងថា វាជា ការច្រឡំ ដែលមិនអាចជៀសបាន កើតពី ស្ថានភាព នៃ សមរភូមិ។ គេលើកឡើងថា មកពី លក្ខណៈ នៃ ព្រំដែន មិនច្បាស់លាស់, ពីចំណុចនៃទិដ្ឋភាព សម្ភារៈ ដល់ គតិយុត្ត និង ការរត់ចូល នៃ ពួកយៀកកុង មកក្នុងស្រុកខ្មែរ ដែល គេលើកសិទ្ធិ ដេញតាមសត្រូវ មកធ្វើជា ការសំអាង។ ជូនកាល គេសុំទោស ហើយ សងជាជម្ងឺចិត្ត ដល់ជនរងគ្រោះ។

ខាង សម្តេច សីហនុ ការវិភាគ វាខុសគ្នា។ ឧប្បត្តិហេតុម្តងហើយម្តងទៀត គឺជា នយោបាយជាប្រព័ន្ធ នាំយកស្រុកខ្មែរ បញ្ចូលទៅក្នុងសង្គ្រាម គឺជួយអាមេរិកាំង តាមការធ្វើ ប្រតិបត្តិការសឹករួម។ ចំពោះ សម្តេច សីហនុ ព្រំដែន ដែលបារាំងទុកឲខ្មែរ វាហាក់ដូចជាគ្រប់គ្រាន់ ព្រោះថា ចាប់ពីឆ្នាំ ១៩៦៦ ព្រំដែននេះ រាជរដ្ឋាភិបាលខ្មែរ យកមកប្រើជាមូលដ្ឋាន សំរាប់ធ្វើសកម្មភាពទូតទាំងឡាយនៅលើឆាកអន្តរជាតិ។ នៅចំពោះមុខបញ្ហា មានទីតាំងពួកយៀកកុង នៅក្នុងដែនដីខ្មែរ ជាដំបូង សម្តេច សីហនុ ទ្រង់បដិសេធជាដាច់ខាត, បន្ទាប់មក ទ្រង់ថាជា កិច្ចការសុទ្ធសាធ របស់ខ្មែរ តែជាបញ្ហាមាន វិសាលភាពមាន

កំណត់ (une portée limitée) ចំពោះខ្មែរ ហើយ រាជរដ្ឋាភិបាល និង កងទ័ពខ្មែរ អះអាងថា តែងតែប្រយុទ្ធប្រឆាំងមិនដាច់ ហើយ វាមានលទ្ធផលជាក់ច្បាស់។

ឧប្បត្តិហេតុទាំងឡាយ ដែលមានកើតឡើង វាមានប៉ះពាល់ដល់ប្រជាជន រស់នៅតាមព្រំដែន តែប៉ុណ្ណោះ ហើយនៅទីកន្លែង ដែលមានមនុស្សរស់នៅតិចតួចណាស់ តែសម្តេច សីហនុ ជួនកាល ទ្រង់យកមកឃោសនា បំប៉ោងជាផ្លូវការ ដើម្បី យកចំណេញនយោបាយ។ តែ លទ្ធផល វានាំឲមានភាពចម្រូងចម្រាស ដល់ខ្លួនព្រះអង្គទៅវិញ គឺការលាតត្រដាង នូវវត្តមាន ពួកយៀកកុង ក្នុងស្រុកខ្មែរ ដែលនាំឲមាន ការលើកឡើង អំពី ‹សិទ្ធិដេញតាមសត្រូវ› ដែល ជា ការកំហែងមួយ ដល់នយោបាយអព្យាក្រឹតខ្មែរ។ ការកំហែងនេះ វាមានរូបភាព ជាផ្កាភ្លើង វាអុជឆេះ ជាព្រឹត្តិការណ៍សំខាន់ នៅឆ្នាំ ១៩៧០ នោះឯង។

នៅខែសីហា ឆ្នាំ ១៩៧៣, សារព័ត៌មាន « le Monde » បង្ហាញថា រដ្ឋបាល លោកប្រធានាធិបតី Nixon បានអនុញ្ញាតឲទំលាក់គ្រាប់បែក ជាប្រព័ន្ធ មកលើស្រុកខ្មែរ តាំងពីមុន ថ្ងៃទី១៨ មិនា ឆ្នាំ ១៩៧០ មកម្លេះ។ ការណ៍នេះ អាចចាត់ទុកជា ភស្តុតាងមួយថា អន្តរាគមន៍ អាមេរិកាំង មិនអាចបដិសេធបាន នៅស្រុកខ្មែរ មិនមែនកើតមក ពីការរាតត្បាតពួកយៀកកុង ក្រោយពី ការទម្លាក់សម្តេច សីហនុ នោះទេ។ សម្តេច សីហនុ ខ្លួនឯង ក៏បាន

សារភាពថា ទ្រង់បានអនុញ្ញាត ៦ អាមេរិកាំង ទម្លាក់គ្រាប់បែក ជាប្រតិបត្តិការតូច នៅស្រុកខ្មែរ កាលទ្រង់នៅកាន់អំណាច ដោយសារ ពួកយៀកកុង កាន់តែរុករានចូលមកក្នុងទឹកដីខ្មែរ កាន់តែខ្លាំងៗ។ ដូច្នេះ កាសែត Le Monde គ្រាន់តែបញ្ជាក់ថា ការអនុញ្ញាត របស់សម្តេចសីហនុ អោយកងទ័ពយៀកកុង ចូលមកតាំងមូលដ្ឋានសឹក នៅស្រុកខ្មែរ វាបែរជាទៅជានយោបាយប្រឆាំងនឹងព្រះអង្គទៅវិញ ដែលជាកត្តា បង្កើត នូវព្រឹត្តិការណ៍ ថ្ងៃទី ១៨ មីនា ដែលអ្នកកាសែត គេយកពាក្យ រដ្ឋប្រហារស្របច្បាប់មកសរសេរនោះឯង។

## ២. ពួកខ្មែរសេរី

ពួកខ្មែរសេរី ដឹកនាំដោយ លោក សឺន ង៉ុកថាញ់ មិនទុកជាគ្រោះថ្នាក់ធំ លើថាន យោធា នោះទេ។ ចលនានេះធ្វើសកម្មភាព បន្តពីសម័យអាណាមិគមនិយម ប្រឆាំងនឹង បារាំង និង សីហនុ នៅអំឡុងឆ្នាំ ១៩៤៧-៥៤ ត្រូវគេបានស្គាល់តាមរយៈ មគ្គុទេសក៍ របស់ខ្លួន គឺលោក សឺន ង៉ុកថាញ់ ដែលគេយល់ឃើញថា គាត់ធ្វើបដិវត្តន៍មួយដ៏ចម្លែក។

លោក សឺន ង៉ុកថាញ់ ជាអ្នកជាតិនិយម ប្រឆាំងនឹងបារាំង និង រាជានិយម។ នៅសម័យបារាំង កំពុងជួបប្រទះ នូវការរំជើបរំជួលនយោបាយ នៅឥណ្ឌូចិន, អាណាព្យាបាល បារាំង មានការពិបាកនឹងចាត់ទុក សឺន ង៉ុកថាញ់ ជា

អ្នកបដិវត្តន៏ បែបណាពិប្រាកដ, ជាទូទៅ គេគ្រាន់តែ ចាត់ទុកគាត់ ជា អ្នកប៉ះបោរជម្មតាម្នាក់។ នៅក្នុង សកម្មភាពបដិវត្តន៏របស់ លោក សឺង ង៉ុកថាញ់ គាត់មាន ទំនាក់ទំនង ជិតស្និត ជាមួយ ពួក ខ្មែរយៀកមិញ ច្រើន ជាង ខ្មែរសេរី តែ ហាក់បី លោក ជា ឥស្សរជននយោបាយ ម្នាក់គត់ ដែលអាច ធានា នូវការទំនាក់ទំនង រវាង និន្នាការ នយោបាយ ផ្សេងគ្នាៗ និង ចងជាសហព័ន្ធ នៃ ក្រុមពួកអ្នកប៉ះបោរទាំងឡាយបាន។ លោក ជា ឥស្សរជន រងគ្រោះ នឹងរាជបូជនីយកិច្ច ដើម្បី ឯករាជ្យជាតិ ដឹកនាំ ដោយ សម្តេច សីហនុ ព្រោះ ក្សឹយនោះ សម្តេច សីហនុ បើកទ្វារឲ ពួកកុម្មុយនិស្ត ចូលរួបរួម ក្នុងល្បែង នយោបាយជាតិ របស់ព្រះអង្គ តែទ្រង់ បិទទ្វារ ចំពោះ លោក សឺង ង៉ុកថាញ់ មិនអោយគាត់មាន លទ្ធភាព និង សេរីភាព ចូលរួមចំណែក ក្នុងកិច្ចការនយោបាយជាតិ ដែលនាំអោយគាត់ មានប្រតិកម្មដាច់ខាត ជ្រើសយក ការតស៊ូអាវុធ ប្រឆាំងនឹងសម្តេច សីហនុ តែម្តង។ តែគេ សង្កេតឃើញថា សកម្មភាព យោធា របស់គាត់ វាស្ថិតនៅ តែតាម ព្រំដែន ខ្មែរ-សៀម ហើយនៅក្នុង ដំបន់ព្រៃភ្នំ ដែលពិបាកនឹងចូលទៅដល់។ តែ នៅពេលនោះ ព្រឹត្តិការ ណ៏ អន្តរជាតិ ទាំងក្នុងប្រទេស និង ក្រៅប្រទេស ក៏មិនផ្ត ល់ជូនគាត់ នូវសន្លឹកបៀ សំរាប់គាត់លែង ជាមួយសម្តេច សីហនុ។ ដូច្នោះ គាត់ក្លាយ ជាសត្រូវនឹង សីហនុ មុនអ្វីៗ,

ដូច្នេះ គាត់នៅសល់តែ ការស្វែងរក នូវការគាំទ្រ ពីសត្រូវរួម ប្រឆាំងនឹង សីហនុ តែប៉ុណ្ណោះ ដូចជា យួនខាងត្បូង និង សៀម និង ប្រហែលតាមរយៈអាមេរិកាំង។ គាត់ទទួលបាន នូវការឧបត្ថម្ភ នៃ ធនធានមនុស្ស មួយចំនួនធំ ក្នុងចំណោម ជនជាតិខ្មែរភាគតិច រស់នៅក្នុងប្រទេសទាំងពីរនោះ។ តែនៅពេលនោះ អ្វីដែលជា សត្រូវនឹងសីហនុ ខ្មែរភាគច្រើននៅក្នុងស្រុកខ្មែរ ទុកជា សត្រូវនឹង ប្រជាជាតិខ្មែរ ដែលសម្តេច សីហនុ ប្រកាសថា ជាជនក្បត់ជាតិ។

ចាប់ពីឆ្នាំ ១៩៦៨, គេមានចំណាប់អារម្មណ៍ថា ចលនាខ្មែរសេរី ចាប់មានសន្ទុះ ដោយសារមាន ការចុះចូល ពីសំណាក់ខ្មែរកម្ពុជាក្រោម រស់នៅកម្ពុជាក្រោម និង ខ្មែរកម្ពុជាក្រោម រស់នៅស្រុកខ្មែរ។ ពួកទាំងពីរ ចងគ្នា ជាកម្លាំងនយោបាយមួយ ដែលអាចនាំ នូវគ្រោះថ្នាក់ដល់សម្តេច សីហនុ។ តែ បន្ទាប់មក វាហាក់បីដូចជា កម្លាំងអ្នកស្តាំនិយមនៅក្នុងប្រទេស ក្តាប់ស្វានការនយោបាយបាន ហើយដើរតួផ្តាច់មុខ ជាមេដឹកនាំ នៃក្រុមអ្នកប្រឆាំងនឹងនយោបាយ របស់សម្តេច សីហនុ ផ្សេងៗទៀត។ ការណ៍នេះ នាំ អោយសម្តេច សីហនុ ទ្រង់មាន អារម្មណ៍ព្រួយបារម្ភ អំពីគ្រោះថ្នាក់នេះ តែ ទ្រង់ ពុំអាចធ្វើអ្វី ប្រឆាំងនឹងវាបាននោះឡើយ ព្រោះ ព្រះអង្គខ្លួនឯង តែងតែយកកម្លាំង ពួកស្តាំនិយម ទប់នឹង កម្លាំង ពួកឆ្វេងនិយម

និង ផ្ទុយមកវិញ។ នៅឆ្នាំ ១៩៦៩ មានផ្ទុះ ករណីមួយ នៅភ្នំ មាលៃ គឺ ខ្មែរសេរី ចំនួន ជាង១០០ នាក់ សូមចុះចូលនឹង សីហនុ ដែលនាំអោយមានមតិខ្លះយល់ឃើញថាព្រឹត្តិការណ៍នេះ ជា ប្រតិបត្តការ របស់ពួកស្តាំងនិយម, ដែលមានពួក CIA នៅពីក្រោយ, បញ្ជូល ពួកខ្មែរសេរី មកក្នុងក្រុងភ្នំពេញ ដើម្បី ចូលរួមធ្វើសកម្មភាពធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ជាមួយកម្លាំង ខាងក្នុង។ តែទោះបីពួកខ្មែរសេរី ជាចលនាតស៊ូប្រដាប់អាវុធ តែលើឋានយោធា ក្នុងទសវត្ស ៦០ ចលនានេះ មានសកម្មភាពយោធា តិចតួចណាស់ នៅក្នុងស្រុកខ្មែរ ហើយ នៅក្នុងមជ្ឈដ្ឋាន នៃកងខេមរៈភូមិន្ទ ពួកនាយទាហាន មិនមាន សាមានចិត្ត ជាមួយនឹងពួកខ្មែរសេរីសោះឡើយ ព្រោះពួកនាយទាហានខ្មែរ ភាគច្រើន សុទ្ធតែជាអ្នករាជានិយម។

## ៣. ការប៉ះបោរ បង្កឡើងដោយពួកកុម្មុយនិស្ត

ត្រូវធ្វើការបែកចែក រវាង ការបះបោរ កសិករ មានកើតឡើងនៅឆ្នាំ ១៩៦៧ ហើយ ព្រាចបន្តិចៗម្តង តាមជនបទ និង ការបះបោរ នៃវិប្រជា រស់នៅក្នុងតំបន់ភ្នំ នៅខេត្តតាមព្រំដែន ពាយ័ត្យ (រតនគីរី, មណ្ឌលគីរី) នៅឆ្នាំ ១៩៦៨។

ការបះបោរ កសិករ នៅឆ្នាំ ១៩៦៧ នាំឲមាន ភាពចម្រូងចម្រាស និង ការវិភាគខុសៗគ្នា។ អ្នកសង្កេតការបរទេស

ខ្លះ ទុកការបះបោរនោះ ជាបរាជ័យ នៃប្រព័ន្ធដឹកនាំសីហ
នុនិយម និង ការបំពាន នៃពួកមន្ត្រីរាជការខេត្ត។ តែ ស
ម្តេច សីហនុ ទ្រង់យល់ឃើញថា ជាស្នាដៃ របស់ពួកកុម្មុយ
និស្ត ដែលមានបរទេសជាអ្នកកាន់ការ។ ដូច្នោះ ទ្រង់
បដិសេធ ប្រកបដោយការឈឺចិត្តថា គ្មានខ្មែរណា ជំទាស់
នឹង អំណាច របស់ទ្រង់នោះទេ ដែលវានាំឲមានការប្រេះ
ឆា ដល់ សាមគ្គីជាតិ ដែលទ្រង់ជាតំណាង នៃការរួបរួមជា
តិ។ តាមទ្រង់ ការបះបោរនោះ គឺ ជាការប្រឆាំងនឹង
នយោបាយរីបជាន់ នៃ រដ្ឋាភិបាលបច្ចុប្បន្ន ដឹកនាំដោយ
ពួកអ្នកស្តាំនិយម។
ការណ៏នេះ, គេមិនអាចជំទាស់បានថា វាគ្មានមូលដ្ឋាន
ពិត នៃប្រជាចលនា នោះបានឡើយ ដែលជាចម្លើយនឹង
ការបំពាន លើប្រជាកសិករ ពីសំណាក់ ពួកមន្ត្រីរាជការ
ខែត្រមួយចំនួន។ តែត្រូវដឹកថា ពួកទាំងនោះ ជា ពួក
អ្នកអបអម ព្រះរាជវង្សានុវង្ស ទទួលបានដំណែង។ ដូច្នេះ
វាមានការពិបាកនឹងហួត ការទទួលខុសត្រូវ របស់សម្តេច
សីហនុ។ តែ ការមិនសប្បាយចិត្ត នៃប្រជាជន នៅពេល
នោះ គឺភ្លាមឡើង ត្រូវបាន ពួកកុម្មុយនិស្ត យកមក
គ្រប់គ្រងបាន ហើយយកមកប្រើ ជាការព្រមាន ដើម្បី
ជំទាស់នឹង នយោបាយគាបគៀ្បតដល់បក្សខ្លួន របស់ស
ម្តេច សីហនុ និង រដ្ឋាភិបាល ដឹកនាំដោយលោក លន់ ន

ល់ ដែលពួកកុម្មុយនិស្ត ទុកជាសត្រូវនឹង បដិវត្តន៍ របស់បក្ស។
រីឯ តួនាទីបរទេស វិញ វាពិបាកនឹងបញ្ជាក់ឲយើញច្បាស់លាស់។ តែមាន អ្នកសង្កេតការបរទេសខ្លះ ជឿជាក់ថា ពួកកុម្មុយនិស្ត ចិន និង យួន ជាអ្នកនៅពីក្រោយ និង ជាអ្នកដឹកនាំផ្ទាល់ នៃឧទ្ទាមកម្មនោះ ព្រោះពួកគេ មិនអាចឲឱកាសដ៏កំរមាននោះ គឺ ប្រជាបះបោរ និង មានលក្ខណៈជាតិពិត ប្រឆាំងនឹង រដ្ឋាភិបាល ស្តាំនិយម របូតពីដៃគេបាននោះទេ។ តែពួកគេ ត្រូវធ្វើយាងណា កុំឲការមានការបះទង្គិចខ្លាំងនឹង សីហនុ ដែលគេចាត់ទុកជាអ្នកអ្នកដឹកនាំ ជាតិនិយម និង ជឿនលឿននិយម ដែលការរលំនៃទ្រង់ វានាំអោយ ពួកស្តាំនិយមជ្រុល មានសុភចិត្តនឹងអាមេរិកាំង អាចនឹងឡើងកាន់អំណាចជំនួស។

## កត្តា អន្តរជាតិ : លើបាន កិច្ចការទូត

គេអាចផ្តល់ នូវគុណូបការៈ ដល់ សម្តេច សីហនុ ដែលទ្រង់បានធ្វើឲស្រុកខ្មែរ ស្ថិតនៅក្រៅសង្គ្រាម នៅស្រុកយួន ចំនួន ១៥ ឆ្នាំ ដោយយក កិច្ចព្រមព្រៀង ទីក្រុង ស៊ីណែវ នៅឆ្នាំ ១៩៥៤ ជាអាវុធ សំរាប់ការពារ នូវអធិបតេយ្យភាព និងបូរណភាពទឹកដីខ្មែរ។ ទ្រង់ យក អព្យាក្រឹតភាព ជា ខ្សែនាយកនយោបាយ តាមការប្រកាសជាឧឡារិកថា

ប្រទេសកម្ពុជា ជាស្រមោច ដូច្នេះត្រូវនៅក្រៅពីវង់ នៃជម្លោះ នៃដំរី ទើបស្រុកខ្មែរបានសុខ។
កត្តា អន្តរជាតិនេះឯង ក៏ជាចំណុចក្តៅ នៃ ទំនាស់មតិរវាង សម្តេច សីហនុ ផ្លាក់ពីតំណែង ភៀសខ្លួនទៅជ្រកកោន នៅទីក្រុងប៉េកាំង និង អំណាចថ្មី នៅ ស្រុកខ្មែរ។
ពីទីក្រុង ប៉េកាំង សម្តេច សីហនុ អះអាងថា ការពិត សហរដ្ឋអាមេរិក (ស.រ.អ.) មិនដែល ទទួលស្គាល់ អព្យាក្រឹតភាព របស់ស្រុកខ្មែរ នោះឡើយ។ ស.រ.អ. សាកល្បងគ្រប់ល្បិច ដើម្បីបញ្ចូលស្រុកខ្មែរ ទៅក្នុងប្រព័ន្ធ O.T.A.S.E. ហើយ ធ្វើគ្រប់បែបយ៉ាង កុំឲ អន្តរជាតិ ទទួលស្គាល់ អព្យាក្រឹតភាពខ្មែរ។ ស.រ.អ. គាំទ្រ ដោយអាក្រក់ និង ផ្តើនឲមានសង្គ្រាម ជាមួយខ្មែរ តាមព្រំដែន ខ្មែរ-សៀម និង ខ្មែរ-យួន។ ដោយមាន ការអស់សង្ឃឹម នឹងអាច ប្តូរនយោបាយខ្មែរបាន, ស.រ.អ. បានសាកល្បង សម្លាប់ សីហនុ ដែលជាតំណាង នៃអព្យាក្រឹតភាព ដែលជាមធ្យោបាយតែមួយគត់ អាចធានា ចំពោះមហាអំណាចកុម្មុយនិស្តមាន ចិន និង សូវៀត នៅក្នុងចម្បាំង នៅយៀកណាម។
ចំពោះ រដ្ឋាភិបាលភ្នំពេញ គេនៅតែរក្សា នូវគោលនយោបាយ នៃអាព្យាក្រឹតភាព តែទុក អាព្យាក្រឹតភាព របស់សម្តេច សីហនុ ជា របស់ក្លែងក្លាយ ដែលនាំប្រជាជាតិ បែរកាន់តែខ្លាំងឡើងទៅរក លោកកុម្មុយនិស្ត។

ជាការពិត, វាគ្មានការសង្ស័យអ្វីនោះឡើយថា សន្តិភាព នៅស្រុកខ្មែរ មានពិត នៅក្នុងកំឡុងឆ្នាំ ១៩៥៤-១៩៧០ មិនមែនដោយសារ បំណង របស់អន្តរជាតិឡើយ គឺវាជា នយោបាយផ្ទាល់ របស់សីហនុ។ ប្រត្យក្សភាពនេះ ដែល សង្គម តែងតែ យកមកឃោសនា តែចាប់ពីឆ្នាំ ១៩៦៥ អព្យាក្រឹតភាព របស់សម្តេច សីហនុ វារលុបនៅស្រពេច ស្រពិល។ ពាក្យស្លោកថា ‹សីហនុគឺជា ការបដិសេធ នៃ មនោគមវិជ្ជាបរទេស›, ‹សីហនុ គឺជាសន្តិភាព› វាលែងជា កម្លាំងកៀងគរ និង លែងជាការពិត។ ខ្មែរជាច្រើន ចាប់ ផ្តើមយល់អំពី អព្យាក្រឹតភាព ក្លែងក្លាយ របស់សីហនុ ហើយ កាន់តែអាចយល់បាន នូវការផ្តល់យោបល់ ពី សំណាក់មហាអំណាច ប្រឆាំងនឹង លទ្ធិកុម្មុយនិស្ត ថា លទ្ធិ នេះ ជាសេចក្តីចង្រៃមួយ ដល់មនុស្សជាតិ។

មកដល់ឆ្នាំ ១៩៧០, វិបត្តិ នៃ អព្យាក្រឹតភាពខ្មែរ វាក្លាយ ជាវិបត្តិ នៃប្រជាជាតិតែម្តង ព្រោះមាន កើតព្រឹត្តិការណ៍ មួយចំនួន នៅស្រុកខ្មែរ ដែលប៉ះពាល់ផ្ទាល់ដល់ សេចក្តី ពិត នៃវា។ ដូច្នេះ លើឋាន មនោគមវិជ្ជា នៃ ចលនាសង្គម រាស្ត្រនិយម របស់សម្តេច សីហនុ ដែលទុកជាផ្លូវកណ្តាល ដោយផ្អែកលើអព្យាក្រឹតភាព រវាង លោកសេរី និង លោក ម៉ាក្សនិយម វា មិនអាចមាន ទំហំ អាចរក្សា នូវស្ថេរភាព នយោបាយ របស់ព្រះអង្គ បានទៀតឡើយ។ លើឋាន រចនាសម្ព័ន្ធសេដ្ឋកិច្ច ឬ ដំណើរ នៃជាតូបនីយកម្ម, បដិ

សេរីនិយម ពីឆ្នាំ ១៩៦៤ ផ្ដល់ នូវចំណាប់អារម្មណ៍ ថា សីហនុនិយម វាកំពុងរំអិលទៅរក លោកកុម្មុយនិស្ដ និង នយោបាយសេដ្ឋកិច្ច បែបសង្គមនិយម ទទួលបរាជ័យជាក់ស្ដែង។ លើបាន យោធា វាចាប់ផ្ដើមមាន ការប្រជល់មុខគ្នា រវាង កងទ័ព អាមេរិកាំង-យួនខាងត្បូង និង កងទ័ពយួនកុម្មុយនិស្ដ នៅលើទឹកដីខ្មែរ ដែលនាំអោយសម្ដេច សីហនុ ពិបាកនឹងពន្យល់ ដល់សហគមន៍អន្តរជាតិអំពី នយោបាយអព្យាក្រឹតភាពខ្មែរ។ ចំនួនបូក នៃវិបត្តទាំងឡាយនោះ វាហាក់ដូចជា សម្ដេច សីហនុ ឆ្លៀតយកផល ពីនយោបាយ អព្យាក្រឹតភាព រហូតដល់កំរិតមួយ ដែល ទ្រង់ពុំអាចអនុវត្តវាបាន ព្រោះព្រះអង្គខ្លួនឯង ជាអ្នកបំពានវាតែម្ដង។

អព្យាក្រឹតភាពខ្មែរ នៅលើឆាកអន្តរជាតិ គ្មានការទទួលស្គាល់ ពីមហាអំណាចលោកសេរី ព្រោះគេយល់ថា វាគ្មានសេចក្ដីពិត និង អនុវត្តបានត្រឹមត្រូវ។ គេដឹងថា ពីដំបូងទីមក នៅក្នុងរយៈពេល នៃប្រធាននាធិបតី របស់លោក Eisenhower រដ្ឋបាលអាមេរិក គេសាកល្បង បំពាក់ និង នាំស្រុកខ្មែរ ចូលរួម តិចច្រើនក្ដី ក្នុង នយោបាយរបស់គេ គឺ ‹ទប់ទល់[18] នឹងកុម្មុយនិស្ដ› នៅដំបន់អាស៊ី ព្រោះគេយល់ឃើញថា ទស្សនៈ នៃអព្យាក្រឹតភាព នៅពេលដែល កម្លាំងកុម្មុយនិស្ដ កំពុងរាតត្បាតយ៉ាងខ្លាំង,

[18] នយោបាយទប់ទល់ : politique « containement »។

តាមយោបល់ របស់លោក John Foster Dulle, រដ្ឋលេខាធិការ នៃសហរដ្ឋអាមេរិក[19], នៅឆ្នាំ ១៩៥៦ ជា ទស្សនៈ កាន់តែមិនអាចយកមកប្រើបាននោះឡើយ លើកលែងតែក្នុងកាលៈទេសៈពិសេសមួយ។ មិនតែប៉ុណ្ណោះ ទស្សនៈនេះ យកវា មកអនុវត្តនៅតំណ្ឌូចិន វាជា អសីលធម៌ និង ជាការមើលឃើញដ៏ខ្លីមួយ។

តែ ចំណង់ តាមការសម្គាត របស់អាមេរិកាំង នៅចំពោះមុខ ការបដិសេធដ៏ស្វាហាប់ របស់សីហនុ វាហាក់បីដូចជាផ្តល់ នូវជោគជ័យនយោបាយផ្ទៃក្នុង ដល់ព្រះអង្គ តែក្រោយមក ជាអកុសល ទ្រង់ យកវាមក ពន្លិច នៅលើឆាកអន្តរជាតិ ព្រោះ ការពោលអះអាង របស់ព្រះអង្គថា ស្រុកខ្មែរ ជាប្រទេសអព្យាក្រឹត និង ការអនុវត្តិ វាខុសគ្នាកាន់តែខ្លាំងឡើងៗ ដែលនាំអោយ អព្យាក្រឹតភាពនោះ បាត់តម្លៃទាំងមូល របស់ខ្លួន នៅលើឆាកអន្តរជាតិ និង បង្អត់ ដល់កងទ័ពខ្មែរ នូវសព្វាវុធទំនើប សំរាប់ការពារជាតិ នៅចំពោះមុខ ការគំរាមកំហែង នៃកម្លាំងកុម្មុយនិស្តយួន។

## អព្យាក្រឹតភាពខ្មែរ ប្រទល់នឹង លោកកុម្មុយនិស្ត

ចំពោះសម្តេច សីហនុ ពីដំបូងឡើង អព្យាក្រឹតភាព វាជាបញ្ញើមួយ ឲលោកកុម្មុយនិស្ត ហើយទុកជា ទ្រនាប់ នៃនោយបាយផ្ទៃក្នុង និង ក្រៅប្រទេស។ វាជា អព្យាក្រឹត

[19] រដ្ឋមន្ត្រីក្រសួងការបរទេស នៃសហរដ្ឋអាមេរិក។

ភាព មានគោលបំណង បញ្ចូលនៅក្នុង កិច្ចព្រមព្រៀង នៅទីក្រុងស៊្សឺណែវ នៅឆ្នាំ ១៩៥៤ ដែលនៅពេលនោះ គេ ទុក ជាកិច្ចព្រមព្រៀងនេះ សំរាប់ការពារ នូវប្រយោជន៍ នៃប្រជាពលរដ្ឋ នៅឥណ្ឌូចិន។ នៅទសវត្ស ៦០ ពួកកុម្មុយ និស្តឥណ្ឌូចិន មានកម្លាំងខ្សោយ ប្រទល់នឹង អន្តរាគមន៍ អាមេរិកាំងផ្ទាល់នៅឥណ្ឌូចិន ដែលនាំអោយសម្តេច សីហ នុ ស្ថិតនៅស្ទៀមមួយរយៈ ដើម្បីយកពេលវេលា សំរាប់ ពិចារណា និង រៀបចំស្រុកខ្មែរ ដោយប្រកាន់គោលជំហរ ពីរយ៉ាង : មិនគាំទ្រ ចិន និង យួន កុម្មុយនិស្ត និង មិន ទុកខ្លួនជា អ្នកប្រឆាំងនឹងសហរដ្ឋអាមេរិក ហើយ ទ្រង់ បានជ្រើសរើស យកនយោបាយ ជិតនឹងលោកសេរី ដោយ ទទួលយកជំនួយ សេដ្ឋកិច្ច និង យោធា របស់អាមេរិកាំ ង។ បន្ទាប់មក ទ្រង់ បានជ្រើសរើស ចិនកុម្មុយនិស្ត ដោយបញ្ឈប់ នូវការទំនាក់ទំនងផ្លូវទូត ជាមួយ ចិនតៃ វ៉ាន់។ ជាជម្រើសមួយ អាចចាត់ទុកថា សមហេតុផលដែរ បើយោងតាម ទម្ងន់នយោបាយ រវាង ចិនទាំងពីរលើ ឆាកអន្តរជាតិ។ តែការវិវត្តន៍ នៃ ព្រឹត្តិការណ៍នយោបាយ ពិភពលោក និង សង្គ្រាមនៅយៀកណាមខាងត្បូង នាំដួរ នូវសមតា នៃមូលដ្ឋានអព្យាក្រឹតភាពខ្មែរ ព្រោះស្រុកខ្មែរ ស្ថិតនៅក្នុង ដំបន់ភូមិសាស្ត្រមួយ ដែលនាំអោយខ្លួន នោះបីចង់ ឬ មិនចង់ ទៅជាកូនសោមួយសំខាន់ នៅ ក្នុងជម្លោះអាវុធ រវាង យួនខាងត្បូង និង យួនខាងជើង

នៅក្នុងបរិបទ នៃសង្គ្រាមត្រជាក់ រវាង លោកសេរី និង លោកកុម្មុយនិស្ត។

ចំពោះ សម្តេច សីហនុ របត់ នយោបាយ របស់ព្រះអង្គទៅរកលោកកុម្មុយនិស្ត គឺមកពីសម្លាតចិត្ត និង អាវុធ ពីសំណាក់ សហរដ្ឋអាមេរិក និង យួនខាងត្បូង មកក្នុងទឹកដីខ្មែរ ដែលនាំឲទ្រង់ មានបារម្ភអំពី អន្តរាយ នៃចក្រពត្រអាមេរិកាំង មកលើអំណាចទ្រង់។ មូលហេតុមួយទៀត គឺ សម្តេច សីហនុ មានការបារម្ភខ្លាំង ខ្លាចវាសនា របស់ព្រះអង្គ ដូចលោក Gno Dinh Diem ប្រធានាធិបតីយួនខាងត្បូង (១៩៥៥-១៩៦៣) ដែលត្រូវទាហានយួនសម្លាប់នៅក្នុងរដ្ឋប្រហារយោធា ដែលមាន CIA នៅពីក្រោយ។ ដូច CIA ធ្លាប់រៀបចំធ្វើ តែមិនបានសម្រេច ជាមួយលោកឧត្តមសេនីយត្រី ដាប ឈួន នៅឆ្នាំ ១៩៥៩ មកលើរូបព្រះអង្គ។ ឃាតកម្មលោក Diem នោះ វាតាមលងព្រះអង្គជានិច្ច ដែលនាំអោយព្រះអង្គ តែងតែគេចចេញពីស្រុកខ្មែរ កាលណាព្រះអង្គ ជួបនឹងវិបត្តនយោបាយធំៗនៅក្នុងប្រទេស ដូចនៅឆ្នាំ ១៩៦៦, ឆ្នាំ ១៩៦៩ នៅក្រោមរដ្ឋាភិបាលដឹកនាំដោយលោក លន់ នល់ ទ្រង់យាងចេញពីកម្ពុជាទាំងយប់ ដោយមិនប្រាប់ដល់រដ្ឋាភិបាលជាមុនហើយ ក្រោយៗមកទៀត ព្រះអង្គ មិនដែលគង់យូរឡើយនៅក្នុងស្រុក រហូតសុគតនៅប្រទេសចិន។

ជាដំបូង ការបែរទៅរកលោកកុម្មុយនិស្ត គឺគ្រាន់តែជាការរក នូវកូនប្រយោល (contre-poids) ថ្មី ដើម្បីឆ្លើយនឹងស្ថានការជាក់ស្តែងតែប៉ុណ្ណោះ។ តែបន្ទាប់ពីព្រឹត្តិការណ៍ថ្ងៃទី១៨ មីនា ឆ្នាំ ១៩៧០ ដោយទ្រង់ឃើញជាក់ច្បាស់នៃការទំលាក់ព្រះអង្គពីដំណែង ពីសំណាក់ពួកស្តាំនិយមដែល ទ្រង់ ជឿងជាក់ថា មានការឃុបឃិតពី CIA, ការបែរទៅរកលោកកុម្មុនិស្ត វាទៅជាកិច្ចការផ្ទាល់ខ្លួន របស់ព្រះអង្គតែម្តង ពោលថា ជាជម្រើស ដើម្បី សងសឹកនឹងពួកអ្នកទម្លាក់ព្រះអង្គ។

សម្លាជ ពីសំណាក់អាមេរិកាំង វាពិតជាមាន តែនៅឥណ្ឌូចិន ស្ថានភាព នៃពួកកុម្មុយនិស្ត នៅយួនខាងត្បូង ចាប់ពីឆ្នាំ ១៩៦៣ និង វិបត្តិ នៃ របប Diem វាមិនដូចគ្នានៅឆ្នាំ ១៩៥៤ នោះទេ។ ពួកកុម្មុយនិស្ត ប្តូរ សកម្មភាព ពីដំណាក់ការ នៃវិធីស្និងស្នាធ៌ ទៅ ដំណាក់ការ នៃសកម្មព្រោះ គេយល់ថា ពួកគេមានកម្លាំងតស៊ូមួយ ដែលគេអាចយកវាមកប្រើបាន លើឆាកនយោបាយ និង យោធាហើយ គេយល់ឃើញថា ស្រុកខ្មែរ វាជាទឹកដីមានប្រយោជន៍ សំរាប់ ការតស៊ូអាវុធ របស់គេ នៅយួនខាងត្បូង ដូច្នេះគេត្រូវ បង្ខំដល់ សម្តេច សីហនុ ឲទ្រង់ជួយដល់ការតស៊ូរបស់គេ ផ្ទាល់តែម្តង លើសពី គ្រាន់តែបដិសេធ មិនស៊ូគ្រជាមួយអាមេរិកាំង។ ការបង្ខំនោះ នាំឲ សម្តេច សីហនុ ស្ថិតនៅក្នុងស្ថានភាព ពិបាកប្រទល់នឹង ពួកកុម្មុយ

និស្តយួន : ម្យ៉ាងដោយសារ ទ្រង់ មានការប៉ុនប៉ង និង ប្រហែលជា ទុកវាជាការចាំបាច់ផង ដោយយកយួន កុម្មុយនិស្ត ជាអ្នកគាំទ្រប្រឆាំងនឹង ការគំរាមកំហែងពី សំណាក់ អាមេរិកាំង និង យួនខាងត្បូង ; ម្យ៉ាងមួយ ទៀត ដោយសារទ្រង់ ខ្លាចមានកើតកម្លាំងតស៊ូអាវុធ នៃ ពួកកុម្មុយនិស្តខ្មែរ នៅក្នុងស្រុក ដោយមាន ពួកយួន កុម្មុយនិស្ត ជាអ្នកគាំទ្រ ប្រឆាំងនឹងព្រះអង្គ។ ទីបំផុត ត្រូវបន្ថែមថា សម្តេច សីហនុ ទ្រង់ មានការភ័យខ្លាច នូវ យថាភាព ដែលបានរៀបរាប់ខាងលើនេះ មិនតែប៉ុណ្ណោះ ទ្រង់ មានជំនឿស៊ប់ថា ទៅអនាគត ពួកយួនកុម្មុយនិស្ត ច្បាស់ជាឈ្នះគេ នៅអាស៊ី។ នៅលើទស្សនៈមូលដ្ឋាននេះ ទ្រង់ ក៏យល់ព្រម ដោយស្ម័គ្រចិត្ត ជួយពួកនោះ កាន់តែ ច្រើនឡើង រហូត មានការប៉ះពាល់ដល់ គោលការណ៍ នៃអ ព្យាក្រឹតភាពតែម្តង។ ដូចយ៉ាង ការផ្តាច់ទំនាក់ទំនងទូត ជាមួយយួនខាងត្បូង និង ការបង្ខិតចូលទៅជិត ទៅវិញ ទៅមក ជាមួយ យួនកុម្មុយនិស្ត រហូតដល់ដាក់ទូត ជាមួយយួនខាងជើង និង ទទួលស្គាល់ រដ្ឋាភិបាល ប ណ្តោះអាសន្ននៃសាធារណរដ្ឋយៀកណាម (G.R.P.V.N.) ឬ យៀកកុង។ នៅឆ្នាំ ១៩៦៩, សម្តេច សីហនុ បានអញ្ជើញ លោក Huyn Tan Phat ជាប្រមុខរដ្ឋាភិបាល យៀកកុង មកធ្វើទស្សនកិច្ច ជាផ្លូវការនៅស្រុកខ្មែរ។ វិបត្តិផ្លូវទូត ជាមួយ សភាពសូវៀត នៅឆ្នាំ ១៩៦៥ (ឧប្បត្តិហេតុ នៃ កូ

រ៉េខាងជើង) និង នៅឆ្នាំ ១៩៦៧[20] ជាមួយ ចិនប្រជាមានិត វាគ្រាន់តែជាឧប្បត្តិហេតុធម្មតា គ្មានប៉ះពាល់អ្វីបន្តិចឡើយ ដល់ ការចងមិត្តភាព រវាង ខ្មែរ នឹង យួនខាងជើង និង យៀកកុង។ មិនតែប៉ុណ្ណោះ សម្តេច សីហនុកាន់តែ គ្មានការសង្ស័យថា ពួកយួនកុម្មុយនិស្ត មិនបង្កើត ចលនាតស៊ូអាវុធកុម្មុយនិស្តខ្មែរ ក្នុងស្រុក ដើម្បីប្រឆាំងនឹងព្រះអង្គ។ នយោបាយ របស់សម្តេច សីហនុបែបនេះ វាបំបែកអស់ នូវតម្លៃអព្យាក្រឹតភាពខ្មែរ។ ដូច្នេះ នៅលើឆាកអន្តរជាតិ, គេចាប់ផ្តើមទុក អព្យាក្រឹតភាពខ្មែរ ជា អព្យាក្រឹតភាពអកម្ម ជាមួយពួកយួនកុម្មុយនិស្ត ឬ អព្យាក្រឹតភាពក្លែងក្លាយ ដែល អាមេរិកាំង មិនអាចយល់ព្រមបានជាដាច់ខាត។

តែ វិបត្តិ ជាមួយ ចិនប្រជាមានិត នៅឆ្នាំ ១៩៦៧ នាំឲ សម្តេច សីហនុ ស្វែងរកការទំនាក់ទំនងជាថ្មី ជាមួយសហរដ្ឋអាមេរិក តែវាហាក់បីដូចជារបត់នោះ វាពិបាកខ្លាំងណាស់ ចំពោះទ្រង់ ព្រោះ ការស្ព័គ្រ (engagement) របស់ទ្រង់ ជាមួយ ពួកកុម្មុយនិស្ត មានជម្រៅជ្រៅខ្លាំងណាស់ទៅហើយ ដែលនាំឲទ្រង់មិនអាចបែរក្រោយវិញបាន។ សម្តេច សីហនុ បានសន្និដ្ឋាន ថា ទ្រង់នឹងបន្ត ការស្ព័គ្រនោះ តាមការបញ្ជាក់ របស់ទ្រង់ ដល់ពួកអ្នកដឹកនាំ ចិន

[20] ចិនលូកដៃចូលក្នុងនយោបាយផ្ទៃក្នុងខ្មែរ ដោយបានជួយគាំទ្រការបះបោរកសិករនៅភូមិសំឡូត។

និង យួន កុម្មុយនិស្តនៅពេលបុណ្យសព លោក ហូ ជីញមុី ញ នៅទីក្រុងហាណូយ។

តែ សម្តេច សីហនុ នៅតែរស្វែងរក នូវការទំនាក់ទំនងជាថ្មី ជាមួយសហរដ្ឋអាមេរិក ដូចយ៉ាង នៅថ្ងៃទី ១១ មិថុនា ឆ្នាំ ១៩៦៨ ខ្មែរ និង អាមេរិកាំង មាន ការប្រាស្រ័យទាក់ទង នៃកិច្ចការទូត ជាថ្មីឡើងវិញ។ តែនៅក្នុងមជ្ឈដ្ឋាននយោបាយអាមេរិកាំង វាមានបែកជាពីរមតិផ្ទុយគ្នា : ទី១ គឺ គេលែងមានជំនឿ ទៅលើអព្យាក្រឹតភាពខ្មែរ ដូច្នេះ ត្រូវរកមធ្យោបាយ នាំស្រុកខ្មែរ ឲ្យចូលមកខាងអាមេរិកាំង តែប៉ុណ្ណោះ។ ទី២ ជាមតិភាគតិច ដែលនៅមានជំនឿថា សម្តេច សីហនុ អាច កែ អព្យាក្រឹតភាពខ្មែរឲ្យល្អវិញបាន។ ពួកទាំងនោះ គឺជាបក្សពួក របស់លោក Mick Mansfield សមាជិកព្រឹទ្ធសភាអាមេរិកាំង ដែលលោកនៅមានជំនឿថាលោក អាចនឹងនាំ សម្តេច សីហនុ អោយមករកផ្លូវត្រូវវិញបាន។

## អព្យាក្រឹតខ្មែរ និង លោកខាងលិច

អព្យាក្រឹតភាព វាអាចមានប្រសិទ្ធភាព លុះត្រាតែមានការគាំទ្រពីសំណាក់ នៃប្រព័ន្ធធានាអន្តរជាតិ។ ដូច្នេះ បើសិនជា សម្តេច សីហនុ ចង់ឲ្យមានការធានា គឺ ត្រូវទ្រង់បង្ហាញ នូវគុណភាព នៃអព្យាក្រឹតភាពខ្មែរ។ ត្រូវដឹងថា ស្រុកខ្មែរ នៅពេលនោះ មាន អង្គការអន្តរជាតិពីរ សំរាប់

ការពារ បូរណភាពទឹកដី គឺ : អង្គការសហប្រជាជាតិ (អ.ស.ប.) និង គណកម្មការអន្តរជាតិត្រួតពិនិត្យ (C.I.C.) នៃកិច្ចព្រមព្រៀង ស្សឺណែវ។
ទំនាក់ទំនង ជាមួយ អ.ស.ប. វាមាន ជូនកាលល្អ ជួនកាលមិនល្អ។ តែ អ.ស.ប. តែងតែរកជានិច្ច នូវការសម្រួល នៃភាពតានតឹង លើមូលដ្ឋាន ពិត និង ស្មើគ្នា។ តែនៅក្នុងបញ្ហា ខ្មែរ-យួនខាងត្បូង ដែលជាបញ្ហា ជាមួយអាមេរិកាំងដែរ មន្ត្រីទូតខ្មែរ ហាក់បីដូចជា មិនមានទំហំនឹងអាចយកឈ្នះ អ្នកទាំងពីរនេះបាន នៅអ.ស.ប. ព្រោះ អ.ស.ប. តែងតែ សំដែង នូវការប្រយ័ត្ន ក្នុងការរកដំណោះស្រាយ ដូចយ៉ាង សិទ្ធិដេញតាមកងទ័ពយៀកកុងរបស់ កងទ័ពអាមេរិកាំង និង យួនខាងត្បូង មកក្នុងទឹកដីខ្មែរ។ នៅឆ្នាំ ១៩៦៤ រាជរដ្ឋាភិបាលខ្មែរ ប្តឹងទៅក្រុមព្រឹក្សាសន្តិសុខ នៃ អ.ស.ប. ពីការឈ្លានពាន នៃកងទ័ពអាមេរិកាំង មកក្នុងទឹកដីខ្មែរ។ នៅខែ ឧសភា-មិថុនា នៅពេលប្រជុំពិសេសស្តីពីពាក្យបណ្តឹងខ្មែរ នៃ ក្រុមព្រឹក្សាសន្តិសុខ លោក Stevenson តំណាង សហរដ្ឋអាមេរិក នៅ អ.ស.ប. បានបង្ហាញ នូវ ភាពពុំត្រឹមត្រូវ (incohérence) នៃបណ្តឹងនេះ ដោយលើកជាសំនួរថា តើហេតុអ្វី ក៏ខ្មែរ មិនសុខចិត្តឲ C.I.C. ត្រួតត្រាឲបានជិតដល់ នៅតាមព្រំប្រទល់ ខ្មែរ-យួនខាងត្បូង ដែលជា អង្គការពេញច្បាប់មួយ អាចមានសមត្ថភាពនឹង អាចនាំមក

នូវសន្តិសុខ តាមព្រំដែន។ ការសម្ដែងនេះ នាំឲអ្នកតំណាងខ្មែរ រកហេតុសំអាងពុំបានមកឆ្លើយតបវិញ។ តែ អ.ស.ប. បានបង្កើត គណកម្មការមួយ[21] ឲមកពិនិត្យកន្លែងកើតហេតុចុងក្រោយ។ បន្ទាប់មកគណកម្មការនោះ បានធ្វើសេចក្ដីរាយការណ៍សម្រាលមួយ ក្នុងនោះ គេពុំដាក់កំហុស ដល់យួនខាងត្បូងនោះទេ ហើយគ្រាន់តែសូមឲគូវិវាទ ធ្វើការចរចាគ្នា ដើម្បី រកដំណោះស្រាយ កុំឲមានកើតហេតុទៅថ្ងៃមុខ តែប៉ុណ្ណោះ។ សេចក្ដីសម្រេចនេះ ជាបរាជ័យ នៃភាគីខ្មែរទាំងស្រុង។

ពិតណាស់ហើយថា C.I.C. វាជាវត្ថុជាតុប្រទើសរំខានមួយដល់សម្ដេច សីហនុ និង យួនកុម្មុយនិស្ត ចាប់តាំងពី ភាគីទាំងពីរ មានទំនាក់ទំនងសម្ងាត់ នៃការប្រើដែនដីខ្មែរជាជម្រងយោធា នៃពួកយៀកកុង។ រឿងនេះ អាមេរិកាំងដឹងច្បាស់ថាមានពិត ហើយទទូច ឲខ្មែរអនុញ្ញាត ឲ C.I.C. ធ្វើកិច្ចការខ្លួនតាមសេរី លើដែនដីខ្មែរ នៅក្នុងក្របខណ្ឌកិច្ចព្រមព្រៀង ស៊ឺរ៉ែណេវ។ ដើមឡើយ ពួកយួនកុម្មុយនិស្តសូមឲ គណកម្មការនេះ ត្រួតពិនិត្យ នូវការបញ្ចូល អាវុធយុទ្ធភ័ណ្ឌមកក្នុងស្រុកខ្មែរ ព្រោះយល់ឃើញថាអាមេរិកាំងផ្ដល់ជំនួយយោធា អោយខ្មែរ តែក្រោយមក គំនិត នេះ វាទៅជាកាំបិទមុខពីរ ព្រោះពួកខ្លួន មានការអនុញ្ញាតពី

[21] ជាដើមគំនិត របស់ប្រទេស កូដីហ្វូរ។ គណកម្មការមានសមាជិក៣នាក់។

សម្ដេច សីហនុ ប្រើកំពុងផែ កំពង់សោម សំរាប់នាំចូល អាវុធយុទ្ធភ័ណ្ឌ ពីប្រទេសចិន និង សហភាពសូវៀត សំរាប់ ចាំងនៅយួនខាងត្បូង។ ត្រូវដឹងថា ប្រតិភូទាំងបី នៃ C.I.C. មាន អកប្បកិរិយា ផ្សេងៗគ្នា : ពួកឥណ្ឌា ហាក់ បីដូចជា ព្រមទទួល ដោយមានការប្រយ័ត្ន នូវការពន្យល់ នៃរាជរដ្ឋាភិបាលខ្មែរ, តែពួក ប៉ូលូញ ហាក់បីដូចជា ការពារប្រយោជន៍ពួកកុម្មុយនិស្តតែម្ដង, រីឯ ពួក កាណាដា វិញ ដែលជាដំណាងលោកខាងលិច មានអកប្បកិរិយា ផ្ទុយពី ប្រតិភូ នៃប្រទេស ប៉ូលូញ ដែលនាំឲបែកឯកភាព នៃគណកម្មការ ហើយលែងមាន សេចក្ដីរាយការណ៍ទោល ផ្ដល់ឲ អ.ស.ប.។ ប្រតិភូនិមួយៗ ក្លាយជាភាគី ការពារតែ ប្រយោជន៍ បក្សពួកខ្លួនរៀងៗខ្លួន។ ប្រតិភូ ឥណ្ឌា រួម ជាមួយប៉ូលូញ តែងតែធ្វើ សេចក្ដីរាយការណ៍ ផ្ទុយពី ប្រតិភូ កាណាដា។ សម្ដេច សីហនុ មើលឃើញគ្រោះថ្នាក់ ដល់ អព្យាក្រឹតភាព ផ្អៀងទៅកាន់លោកកុម្មុយនិស្ត របស់ទ្រង់ ទ្រង់ក៏សម្រេចចិត្ត បញ្ឈប់សកម្មភាព C.I.C. នេះ តែម្ដង។ ការណ៍នេះ ជាកំហុសមួយខ្លាំងណាស់ ចំពោះ ប្រជាជាតិខ្មែរ គឺព្រះអង្គ បោះបង់ ខែលអន្តរជាតិ សំរាប់ ការពារបូរណភាពដែនដីខ្មែរ។

វាមានការយល់ឃើញពីរយ៉ាងខុសគ្នា ទៅតាម អ្នកគាំទ្រ និង អ្នកប្រឆាំងនឹង សម្តេច សីហនុ។ ចំពោះ ពួកអ្នកគាំទ្រសីហនុ គឺទុកគ្មានរុញរា នូវការទំលាក់នោះ ជារដ្ឋប្រហារ មានបរទេសជាអ្នកបង្កើតឡើង។ សារព័ត៌មាន បារាំង Le Monde (២១ មីនា ១៩៧០) សរសេរថាជា ‹រដ្ឋប្រហារពេញច្បាប់›។ គេប្រើពាក្យពេញច្បាប់នេះ ព្រោះ អ្នកសរសេរពិបាក ជ្រើសរើស នូវភាពស្មោះត្រង់ នៃសតិបញ្ញា និង ព្រលឹង នៃប្រព័ន្ធនយោបាយ របស់សម្តេច សីហនុ ដែលមានរូបភាព ជារបបផ្តាច់ការមួយ។ ដូច្នេះ វាគ្មានមធ្យោបាយផ្សេងណាមួយទៀត នៅក្នុងបរិបទពេលនោះ អាចរំលំ របបសីហនុនិយមបាន ក្រៅតែពីធ្វើរដ្ឋប្រហារ ឬធ្វើបដិវត្តន៍ តែប៉ុណ្ណោះ។ តែ រាជរដ្ឋាភិបាល នៅពេលនោះ បានជ្រើសរើស យកផ្លូវច្បាប់មកប្រើ ដើម្បីដកហូតអំណាចផ្តាច់ការពីសម្តេច សីហនុ។

ទោះបីមានការប៉ុនប៉ង នៃពួកបញ្ញវន្តបរទេស និង ខ្មែរមួយចំនួន ពន្យល់បែបជា ការវិភាគគតិយុត្ត ថា ការទំលាក់ សម្តេច សីហនុ មានការរៀបចំច្បាស់លាស់ នៃពួកស្តាំនិយម និង ទ្រង់ សិរិមតៈ ដោយមានជំនួយពី CIA : ដូចយ៉ាង យកពួកខ្មែរសេរី និង រណសិរ្សរួបរួម នៃសេរីការ

នៃជាតិសាសន៍ ត្រូវបានគេជិះជាន់សង្កត់សង្កិន[22] មកជួយជាកម្លាំងផ្ទៃក្នុង។ ហើយនិង ប្រើឧបករណ៍ រដ្ឋាភិបាល ដើម្បី ធ្វើអោយ សម្តេច សីហនុ ស្ថិតនៅក្នុង សភាពឯកា ដោយដកហូត នូវគ្រប់មធ្យោបាយ នៃសកម្មភាពផ្ទាល់ របស់សីហនុ នៅក្នុងកិច្ចការរដ្ឋបាល និង ទៅលើប្រជាករ ដូចយ៉ាង នៅឆ្នាំ ១៩៦៩ រាជរដ្ឋាភិបាល បាន ធ្វើការសម្រេច បីយ៉ាង :

១. ចរាចរ រដ្ឋាភិបាល ដល់ រដ្ឋបាលគ្រប់ថ្នាក់ ហាមមិនឲធ្វើការទាក់ទងផ្ទាល់ជាមួយខុទ្ទកាល័យនៃព្រះប្រមុខរដ្ឋ។ គ្រប់កិច្ចការរដ្ឋ ត្រូវទាក់ទង តាមផ្លូវរដ្ឋាភិបាល តែមួយគត់។

២. ចរាចរ ដល់ ប្រធានអគ្គនាយក នៃ សហគ្រាសជាតិ ហាម មិនអោយ បង់ប្រាក់ ជូនដល់ហិបប្រាក់ពិសេស របស់សម្តេច សីហនុ ដែលជាមធ្យោបាយហេរញ្ញវត្ថុ របស់ទ្រង់ សំរាប់ចំណាយ គ្មានកំរិត និង គ្មានការត្រួតពិនិត្យ ពីអង្គការជាតិណាមួយ។

៣. ក្រសួងព័ត៌មាន ត្រូវភ្ជាប់នឹង ទីស្តីការ នៃនាយករដ្ឋមន្ត្រី។ ការសម្រេចនេះ គឺ ខាយាំង កុំអោយ សម្តេច សីហនុ

[22] (F.U.L.R.O) រណសិរ្សនេះ រួបរួម ដោយជនជាតិ ភាគតិចមួយចំនួន រស់នៅ ដំបន់អគ្នេយ៍ នៃ ឥណ្ឌូចិន ក្នុងទឹកដីយួនខាងត្បូង ដែលបារាំងអោយឈ្មោះថា Montagnard។ រណសិរ្សនេះ បង្កើតដោយ អាមេរិកាំង ជួយច្បាំងប្រឆាំងនឹងយួនកុម្មុយនិស្ត។

ប្រើក្រសួងនេះជា ឧបករណ៍ សំរាប់ធ្វើការឃោសនា នូវនយោបាយ នៃទ្រង់។
សួរថា ការវិភាគនេះ វាជាការពិតដែរឬទេ ? គំនិតពីរប្រឆាំងគ្នា ដែលយើងលើកមកបង្ហាញខាងក្រោមនេះ។

## និក្ខេបបទ នៃភាគីប្រឆាំងគ្នា

**គោលជំហរ របស់សម្ដេច សីហនុ** : (ដកស្រង ពីសេចក្ដីប្រកាស របស់សម្ដេច សីហនុ ចុះថ្ងៃទី ២០ មីនា ឆ្នាំ ១៩៧០) ទុក ការទំលាក់ទ្រង់ ដោយ សភាជាតិ (រដ្ឋសភាជាតិ និង ក្រុមព្រឹក្សា នៃព្រះរាជាណាចក្រ) ជាអំពើឥតស្របច្បាប់ ព្រោះថា នៅឆ្នាំ ១៩៦០ ទ្រង់ ត្រូវបានតែងតាំងជាប្រមុខរដ្ឋអស់មួយជីវិត ដោយ សភាជាតិ ស្របតាមច្បាប់ នៃរដ្ឋធម្មនុញ្ញ ហើយ ទ្រង់ បានធ្វើសច្ចាប្រណិធាន នៅចំពោះមុខ សភាជាតិ ស្របតាមច្បាប់ នៃរដ្ឋធម្មនុញ្ញ ថែមទៀត។ ម្យ៉ាងវិញទៀត នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ ឥតមាន បទបញ្ញតិ ណាមួយ ដែលអនុញ្ញាត អោយ សភាជាតិ និង រដ្ឋាភិបាល អាចដកដំណែងប្រមុខរដ្ឋ បាននោះទេ ព្រោះជាដំណែង តែងតាំងអស់មួយជីវិត។ ដូច្នេះ មានតែ តាមផ្លូវ ប្រជាមតិ ប៉ុណ្ណោះទេ ដែលអាចហូតដំណែង ប្រមុខរដ្ឋបាន។ ដូច្នេះ ទ្រង់មិនខ្លាច យកបញ្ហានេះ ដាក់អោយ ប្រជាមតិ ជាអ្នក

សម្រេច ក្នុងលក្ខខណ្ឌ អោយមាន ការជានា ដល់សុវត្ថិភាពដល់ទ្រង់ជាមុន។

**គោលជំហរ របស់រាជរដ្ឋាភិបាល** : (ដកស្រង់ពី សេចក្តីប្រកាស របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ៥ មេសា ឆ្នាំ ១៩៧០) នៅឆ្នាំ ១៩៦០ បន្ទាប់ពីប្រជាបាតុកម្ម សម្តេច សីហនុ ត្រូវបាន ប្រកាស ជាប្រមុខរដ្ឋ អស់មួយជីវិត ដោយ ប្រធានរដ្ឋសភា នៅក្នុង អង្គប្រជុំជាសាធារណៈ ដោយគ្មាន ការបោះឆ្នោតជាមុន។ ក្រោយពីការប្រកាសនេះមក គឺគ្រាន់តែមានការទះដៃ ពីសំណាក់ តំណាងរាស្ត្រ ដើម្បីអនុម័តនូវការប្រកាសនោះ តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ នៅថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០, បន្ទាប់ពីប្រជាបាតុកម្ម ប្រឆាំងនឹងសីហនុ, សភាជាតិ បានប្រកាស ដកដំណែង ប្រមុខរដ្ឋអស់មួយជីវិត ពីសម្តេច សីហនុ តាមការបោះឆ្នោត ជាសាធារណៈ នៅលើវេទិកា (s’est prononcé au scrutin public à la tribune) : ៩២ សម្លេងចេញពី ៩២ មានវត្តមាន។ ដោយអាស្រ័យ ក្បួន ស្របនិយម នៃទម្រង់ (règle du parallélisme des formes), អ្វីដែល សភាជាតិ នៅពេលនុះ បានបង្កើតឲមាន, សភាជាតិមួយទៀត ក៏អាច លុបវិញបាននោះដែរ។ ដូច្នេះ បើ រដ្ឋសភា នៅឆ្នាំ ១៩៦០ បានតែងតាំង សម្តេច សីហនុ ជាប្រមុខរដ្ឋ, សភាជាតិ នៅឆ្នាំ ១៩៧០ ក៏អាចដកហូតតំណែងព្រះអង្គបានដែរ នៅក្នុងទម្រង់ច្បាប់ដូចគ្នា។ ដូច្នេះ វាគ្មានចាំបាច់មាន បទបញ្ញ

តិ យ៉ាងច្បាស់ណាមួយ សំរាប់ទំលាក់ ប្រមុខរដ្ឋនោះឡើយ។ ម្យ៉ាងមួយទៀត សម្តេច សីហនុ ទាមទារ ថាតំណែងខ្លួន ជាតំណែងអស់មួយជីវិត។ ជាជម្មតា នៅក្នុង រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ គេឃើញមានតែ ព្រះមហាក្សត្រ ម្នាក់គត់ ដែលទទួលតំណែង អស់មួយជីវិត។

ស្រុកខ្មែរ ជា រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ, នៅពេលណា ដែលព្រះមហាក្សត្រ សុគត, ក្រុមព្រឹក្សារាជសម្បត្តិ ត្រូវ ជ្រើសរើស ព្រះមហាក្សត្រថ្មី (មាត្រា ៣០)។ ក្នុងករណី ដែល កាលៈទេសៈ មិនអនុញ្ញាតអោយធ្វើបាន ដោយហេតុផល រដ្ឋ, ក្រុមព្រឹក្សារាជសម្បត្តិ ត្រូវ បោះឆ្នោត ជ្រើសរើស ក្រុម ព្រឹក្សា រាជានុសិទ្ធិ ដែលជា អ្នកទទួល ជាបណ្តោះអាសន្ន នូវរាជាពុទ្ធសិទ្ធិ (មាត្រា ៣០ស្ទួន)។ គឺ បើគ្មាន ក្រុមព្រឹក្សា រាជានុសិទ្ធិ ទើបអាចនឹងតែងតាំង ប្រមុខរដ្ឋ ដើម្បី ជំនួស ក្រុមព្រឹក្សានោះ (មាត្រា ១២២)។ ដោយហេតុនេះ, ប្រមុខរដ្ឋ មិនអាចមានសិទ្ធិ លើសពី ក្រុមព្រឹក្សារាជនុ សិទ្ធិ ដែលខ្លួនជំនួស បាននោះ។ តែបើខ្លួន ធ្វើការ អះអាងថា ខ្លួនជាបុគ្គលអភិសិត្ត, គ្មាននរណា អាច រំលោភបាន និង មានតំណែងអស់មួយជីវិត ដូចព្រះមហា ក្សត្រ ហើយខាឃាំង មិនអោយមានព្រះមហាក្សត្រ គ្រង រាជសម្បត្តិ គឺច្បាស់ជាខ្លួនជា អ្នកដណ្តើមរាជ្យ នោះឯង។ ដូច្នេះ អាណត្តិ របស់ប្រមុខរដ្ឋ វាគ្រាន់តែ បណ្តោះអាសន្ន, មិនទៀង និង គេអាចដកហូតបាន។

បើយោគតាម រដ្ឋធម្មនុញ្ញ, អាណត្តិ របស់ប្រមុខរដ្ឋ រាពុំ អាចលើសពី អាណត្តិ របស់ក្រុមរាជនុសិទ្ធិ បាននោះឡើយ (៤ ឆ្នាំ) ព្រោះ ប្រមុខរដ្ឋ ជាអ្នកជំនួស ក្រុមព្រឹក្សានេះ។ បើ យោងតាម ហេតុផលត្រឹមត្រូវ (logique) នៃរដ្ឋធម្មនុញ្ញ, ប្រមុខរដ្ឋ ត្រូវជ្រើសរើសឡើង រៀងរាល់ដើម នៃ នីតិកាល សភា ជានិច្ច ដែល សម្តេច សីហនុ ទ្រង់មិនដែលយកមក អនុវត្ត នោះឡើយ តាំងពីព្រះអង្គ ត្រូវបាន ប្រធានរដ្ឋ សភា ប្រកាសតែងតាំងព្រះអង្គជាព្រះប្រមុខរដ្ឋ នៅឆ្នាំ ១៩៦០។ ដូច្នេះ មកដល់ឆ្នាំ ១៩៦៥, ព្រះអង្គ លែងមានឋា នៈជា ប្រមុខរដ្ឋស្របច្បាប់។

សម្តេច សីហនុ យល់ឃើញថា មានតែប្រជាមតិទេ ដែល អាចដកហូតដំណែងព្រះអង្គបាន។ នៅត្រង់ចំណុចនេះ រដ្ឋធម្មនុញ្ញ បដិញ្ញាតថា ប្រជាមតិ អាចធ្វើបាន លុះ ត្រាតែមានទំនាស់ រវាង រដ្ឋសភា នឹង សមាជជាតិ ហើយ នៅក្នុងករណី ដែលអង្គការតំណាងប្រជាពលរដ្ឋ (រដ្ឋសភា) យល់ឃើញថា ត្រូវធ្វើចាំបាច់។ មាត្រា បដិញ្ញាតថា : រដ្ឋ សភា អាចអោយរៀបចំធ្វើ ប្រជាមតិ លើ សំនួរទាំងឡាយ ណា ដែលជាប្រធានបទ នៃការសម្រេចចិត្តមួយ របស់ សមាជជាតិ[23]។

[23] L’assemblée peut instituer un referendum sur les questions qui ont fait l’objet d’une résolution du Congrès.

មួយវិញទៀត តាមទស្សនៈ ក្រមព្រហ្មទណ្ឌ, សម្តេច សីហនុ អាចនឹងមានគ្រោះថ្នាក់ដល់ព្រះអង្គ ពីបទ បំពានរដ្ឋធម្មនុញ្ញ។ មាត្រា ២២១ បដិញ្ញាត ថា : វិច្ឆេទកម្ម ដែលមានគោលដៅ ដួរ ឬ បំផ្លាញ... រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រ ...ត្រូវបានផ្តន្ទាទោស ជាទោសឧក្រិដ្ឋ កម្រិតទី៣។ ក្នុងករណី ដែល សម្តេច សីហនុ បានបំពាន រដ្ឋធម្មនុញ្ញ ដោយចាប់ឃុំឃាំង និង ប្រហារជីវិត នូវ ជនខ្មែរទាំងឡាយ ដែលប៉ូលិស មានការសង្ស័យ ជា ខ្មែរក្រហម។ ក្នុងករណីនេះ ទ្រង់បានបំពាន បទប្បញ្ញត្តិ រដ្ឋធម្មនុញ្ញ ដែលធានា ដល់ប្រជាពលរដ្ឋ នូវសេរីភាព និង សុវត្ថិភាពសាធារណៈ។ វិច្ឆេទកម្ម ប្រឆាំងនឹង រដ្ឋធម្មនុញ្ញ គឺ មានការបកស្រាយតាមផ្លូវច្បាប់ ហើយត្រូវតែអនុវត្ត។

លើសពីនេះទៅទៀត សម្តេច សីហនុ បានអនុញ្ញាតអោយកងទ័ព ពួកយៀកកុង ឈ្លានពានដែនដីខ្មែរ ហើយប្រឆាំងនឹង ការប្រកាស នូវភាពអាសន្ន នៃ រដ្ឋសភា។ មិនតែប៉ុណ្ណោះ ទ្រង់បាន បណ្តេញ C.I.C. ព្រោះមិនចង់អោយ គណកម្មការនេះ ធ្វើការកត់ហេតុ នៃវត្តមាន នៃពួកយៀកកុង នៅក្នុងដែនដីខ្មែរ។

យើងឃើញថា និក្ខេបបទ របស់សម្តេច សីហនុ គឺផ្អែកលើអំណាច នៃប្រជាពលរដ្ឋ គឺថា មានតែ ប្រជាមតិ ដែលអាចហូតតំណែងទ្រង់បាន។ រីឯ រាជរដ្ឋាភិបាល វិញ ផ្អែកលើអំណាច សភាជាតិ ដែលជាតំណាង នៃប្រជាពលរដ្ឋ។

បដិយោគ នៃនិក្ខេបបទទាំងពីរខាងលើនេះ វានៅមានភាពចម្រូងចម្រាស់ រហូតមកដល់សព្វថ្ងៃនេះ នៅក្នុងមតិសាធារណៈជន។ សពសម្តេច សីហនុ ជាអ្នកឈ្នះ ហើយត្រូវ គណបក្សប្រជាជនខ្មែរ ដែលជាបក្សកាន់អំណាច គេទុកព្រះអង្គ ជាវិរបុរសជាតិ, នៅក្នុងករណីនេះ ធ្វើអោយនិក្ខេបបទ របស់សម្តេច សីហនុ ក្លាយជា និក្ខេបបទជាផ្លូវការ។ ដូច្នេះ គេទុកការទំលាក់សម្តេច សីហនុ ជារដ្ឋប្រហារ បង្កឡើង ដោយពួកជនក្បត់ជាតិ ដែលគេហៅថាបន លន់នល់។ តែនៅមុខ ការពិតមួយ ដែលមានច្បាប់ជាកំណល់, ការទុក ជារដ្ឋប្រហារ វាជាការយល់ឃើញ ដ៏អាក្រក់អាក្រី ព្រោះជាយោបល់ ដោយមិនគិតដល់ រដ្ឋសភា ដែលជា ស្ថាប័នដំណាងប្រជាពលរដ្ឋ។ ត្រូវដឹងថា រដ្ឋសភា នីតិកាល ១៩៦៦-១៩៧០ ជាតំណាងប្រជារាស្ត្រខ្មែរ ដោយយថាភាព មិនមែនដូច រដ្ឋសភា មុនៗ ដែលគណកម្មការនាយក នៃចលនាសង្គម ជាអ្នកជ្រើសរើសបេក្ខជនតំណាងរាស្ត្រ អោយប្រជារាស្ត្រ ជ្រើសរើសនោះឡើយ។ យើងដកស្រង់ ព្រះសុន្ទរថា នៃ សម្តេច សីហនុ ទ្រង់ថ្លែងទៅកាន់រដ្ឋសភា :

« ...*វាចា ជាបឋមរបស់ខ្ញុំ គឺខ្ញុំថ្លែងជូន សហជីវិនី សហជីវិន នូវសេចក្តីសរសើរ យ៉ាងខ្លាំង ចំពោះ និង យ៉ាងខ្លាំងក្លាបំផុតរបស់ខ្ញុំ។ សហជីវិនី សហជីវិន ជាអ្នកតំណាងរាស្ត្ររបស់ប្រជារាស្ត្រខ្មែរ ដោយ យថាហេតុ មិនមែនដូចអ្នក*

*តំណាងរាស្ត្រមុនៗ ដែលជាបេក្ខជន ដែលគណកម្មធិការនាយកសង្គមយើង ចាត់តាំង ហើយដែលអ្នកបោះឆ្នោតភាគច្រើន បញ្ចេញមតិ យល់ព្រមនោះទេ។ ហេតុនេះ អត្ថន័យ នៃអាណត្តិ របស់សហជីវិនី សហជីវិន មានភាពរឹងប៉ឹង រកអ្នកណាជំទាស់ពុំបាន ដោយហេតុថា ជនរួមជាតិ នៃយើង មានសេរីភាព ពេញទី ក្នុងការជ្រើសរើស។ ខ្ញុំសូមសរសើរផងដែរ ចំពោះអ្នកបោះទូទៅ ដែលបានបញ្ចេញឲយើញការឆ្អិនឆ្អៅខាងនយោបាយខ្លួន ដោយនាំគ្នាទៅបោះឆ្នោត ក្នុងសេចក្តីរៀបរយ និង ដោយគោរពាវិន័យ នៃពលរដ្ឋ។ ប្រទេសយើង ដែលបានបង្ហាញឲយើញនូវដំណើរ នៃលទ្ធិប្រជាធិបតេយ្យ ពិតប្រាកដ បែបនេះ អាចមានសេចក្តីឆ្ងើងបាន ដោយសមហេតុផល នៅពេលដែល ពួកមហាអំណាច ក្នុងលោក ដែលតាំងខ្លួនជាសេរីនោះ ហ៊ានលើកយកមកធ្វើជាឱទាហរណ៍ នូវការបោះឆ្នោតបន្លំ ដែលរបបគ្រប់គ្រង នៃព្រៃនគររៀបចំប្រឌិតឡើង។ ក៏ប៉ុន្តែ យើងមិនត្រូវភ្លេចឲសោះថា លទ្ធិប្រជាធិបតេយ្យខ្មែរនេះ ដែលខ្ញុំ ប្រឹងប្រែង សម្រឹតសម្រាំង និងជាទី សង្ឃឹមរបស់ខ្ញុំ អាចរស់បាន មកទល់នឹងពេលនេះ ហើយ អាចមានលក្ខណៈ បែបនេះបាន គឺដោយសារសង្គមយើង...* »

យោគតាម ព្រះសន្ទុកថានេះ យើងឃើញថា រដ្ឋសភាជាតិខ្មែរ នីតិកាល ១៩៦៦-១៩៧០ មានសុពលភាព អាច ដក

ហូតតំណែង ប្រមុខបាន ដោយសារខ្លួនជា រដ្ឋសភា របស់ប្រជារាស្ត្រខ្មែរ ដោយ យថាភាព។

## អភិក្រម នៃការទំលាក់ នរោត្តម សីហនុ

ការរលំ នៃ សម្តេច សីហនុ ដោយខ្លួនឯង, នៅក្នុងករណីដែល ដំណួលនេះ ជា លទ្ធផល នៃភាពរលួយ នៃរបបគ្រប់គ្រងសង្គម និង ការមិនពេញចិត្តទូទៅ នៃគ្រប់កម្លាំងនយោបាយជាតិ ដែលហាក់បី គ្មានពាក់ព័ន្ធសោះនឹង ដំណើរបន្តចាំបាច់ នៃនយោបាយ ក្រោយពីការរលំនេះ។ ការណ៍នេះ ជាការបារម្ភមួយ ចំពោះ របបថ្មី ក្នុងការទាក់ទាញគ្រប់កម្លាំងនយោបាយ អោយគាំទ្រខ្លួន និងការទទួលស្គាល់ខ្លួន ជា របបពេញច្បាប់ ពីសំណាក់ សហគមអន្តរជាតិ។

**ព្រឹត្តិការណ៍**

ដើម្បី ស្រួលតាមដាន លើអភិក្រម នៃការទំលាក់ សម្តេច សីហនុ យើងលើកយកព្រឹត្តិការណ៍សំខាន់ មកបង្ហាញជាកាលប្បវត្តិ មុន និង ក្រោយបន្តិច នៃថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០។

នៅថ្ងៃទី **៦ មករា ឆ្នាំ ១៩៧០**, សម្តេច សីហនុ បានចាកចេញពីស្រុកខ្មែរ ទៅកាន់ស្រុកបារាំង យ៉ាងប្រយាប់ទាំងយប់ ដោយគ្មានប្រាប់រដ្ឋាភិបាលជាមុន។ ទ្រង់លើកយក

ហេតុផល នៃសុខភាព ដែលតម្រូវអោយទ្រង់ទៅព្យាបាល នៅស្រុកបារាំង។

នៅថ្ងៃទី **៣ កុម្ភៈ ឆ្នាំ ១៩៧០**, រដ្ឋសភា ចាប់យក ករណី វត់ពន្ធក្រណាត់ពីក្រុងហុងកុង ដែលមាន វរសេនីយឯក អ៊ុំ មាណូរិទ្ធ, រដ្ឋលេខាធិការ ក្រសួង ការពារផ្ទៃដីប្រទេស, មានជាប់ទាក់ទង ; លោកជា បងថ្លៃ នៃសម្តេច សីហនុ។

នៅថ្ងៃទី **៨ មីនា ឆ្នាំ ១៩៧០** មានផ្ទុះបាតុកម្ម នៅខេត្តស្វាយរៀង ប្រឆាំងនឹង វត្តមានយៀកកុង នៅក្នុងដែនដីខ្មែរ។ ពួកបាតុករ តម្រូវអោយពួកយៀកកុង ចាកចេញពីស្រុកខ្មែរ ជាបន្ទាន់។

នៅថ្ងៃទី **១១ មីនា ឆ្នាំ ១៩៧០** មានផ្ទុះបាតុកម្ម មួយទៀត នៅទីក្រុងភ្នំពេញ ប្រឆាំងនឹង យៀកកុង និង យួនខាងជើង។ ស្ថានទូត នៃរដ្ឋាភិបាលបណ្តោះអាសន្ន យួនខាងត្បូង (យៀកកុង) និង យួនខាងជើង បានត្រូវពួកបាតុករ ភាគច្រើនជា សិស្សវិទ្យាល័យ វាយកំទេច។

នៅថ្ងៃទី **១៤ មីនា ឆ្នាំ ១៩៧០**, សម្តេច សីហនុ ផ្ញើ ទូលេខចំពោះ រដ្ឋាភិបាល នៅក្នុងនោះ ទ្រង់បញ្ជាក់ថា ទ្រង់មិនគាំទ្រ ពួកបាតុករ នោះឡើយ។

នៅថ្ងៃទី **១៦ មីនា ឆ្នាំ ១៩៧០** មានការប្រជុំមួយ រវាងប្រតិភូខ្មែរ នឹង ប្រតិភូ យៀកកុង និង យួនខាងជើង តែគ្មានលទ្ធផល។ នៅថ្ងៃដដែលនេះ មានបាតុកម្មជាថ្មីប្រឆាំងនឹងយួន នៅមុខរដ្ឋសភា ដែលកំពុង ប្រជុំ ពិនិត្យ

ករណី រត់ពន្ធ ដែលមានលោក អ៊ុំ មាណូរិទ្ធ មានជាប់ទាក់ទង។ ពួកបាតុករ ទាមទារ អោយរដ្ឋសភា ដោះស្រាយជាបន្ទាន់ នូវបញ្ហា តម្រូវអោយ ទ័ពយៀកកុង និង យួនខាងជើង ដកចេញពីដែនដីខ្មែរ។ រដ្ឋាភិបាល និង មហាក្សត្រីយានី ជាមាតា របស់សម្តេច សីហនុ សម្រេចបញ្ជូនប្រតិភូមួយ មាន ឥស្សរជន បីនាក់, ទ្រង់ កន្តុល, លោក យែម សម្ប៊ូរណ៍ និង ឧប គីម អាង ទៅស្រុកបារាំង ដើម្បីពន្យល់ ដល់សម្តេច សីហនុ អំពី ស្ថានភាពពិត នៅក្នុងស្រុក តែ ទ្រង់ បដិសេធ មិនព្រមទទួលជួប ប្រតិភូនោះ។

នៅថ្ងៃទី **១៧ មីនា ឆ្នាំ ១៩៧០**, លោក នល់ លន់ ប្រកាសតាមវិទ្យុ ចាប់ឃុំ វរសេនីយត្រី ប៊ូ ហែល, មេប៉ូលិស ទីក្រុងភ្នំពេញ, ពីបទ ប៉ុនប៉ង ធ្វើរដ្ឋប្រហារ ប្រឆាំងនឹង រដ្ឋាភិបាល។

នៅថ្ងៃទី **១៨ មីនា ឆ្នាំ ១៩៧០**, នៅពេលដែល សម្តេច សីហនុ ធ្វើទស្សនកិច្ចជាផ្លូវការ នៅសហភាពសូវៀត, នៅម៉ោង ១៣កន្លះ ម៉ោងនៅកម្ពុជា សភាជាតិខ្មែរ បានបោះឆ្នោត ទំលាក់សម្តេច សីហនុ ពីតំណែង ប្រមុខរដ្ឋ។

នៅថ្ងៃទី **១៩ មីនា ឆ្នាំ ១៩៧០**, លោក លន់ នល់ ប្រកាសនូវឱសានវាទ ចំពោះ យៀកកុង និង យួនខាងជើង អោយដកកងទ័ពខ្លួន ចេញពីដែនដីខ្មែរ ក្នុងរយៈពេល ៤៨ ម៉ោង។ រីឯ សម្តេច សីហនុ ធ្វើការអំពាវនាវ តាមវិទ្យុ ពីទីក្រុង ប៉េកាំង សូមអោយខ្មែរ ងើបបះបោរ ប្រឆាំងនឹង រ

ដ្ឋាភិបាល ដឹកនាំដោយលោក លន់ នល់ មានឈ្មោះថា រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ។

យើងឈប់មួយរយៈសិន ដើម្បី ពិនិត្យ និង អត្ថាធិប្បាយ អំពីព្រឹត្តិការណ៍ ដែលមានកើតឡើងនេះ។

សំនួរ ដែលជា បេះដូង នៃព្រឹត្តិការណ៍ គឺ : តើ អ្នកណា នៅពីក្រោយ នូវ ការបះបោរ ប្រឆាំងនឹង យៀកកុង និង យួនខាងជើង នៅខេត្ត ស្វាយរៀង និង ទីក្រុងភ្នំពេញ ?

ក្នុងជំនួប សម្តេច សីហនុ ជាមួយលោក លន់ នល់[24] នៅទីក្រុងបារីស ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧០, អ្នកទាំងពីរ បានលើកយក បញ្ហា នៃវត្តមាន ទ័ពយួនកុម្មុយនិស្តនៅស្រុកខ្មែរ ដែលជាចំណុចក្តៅ នាំអោយបាត់ ភាពជឿជាក់ លើគោលការណ៍ នៃអព្យាក្រឹតភាពខ្មែរ ពីសំណាក់ សហគមអន្តរជាតិ និង ជាការរំខានដល់ ការប្រស្រ័យទាក់ទងតាមផ្លូវទូតជាថ្មី ជាមួយសហរដ្ឋអាមេរិក។ ត្រូវដឹងថា សម្តេច សីហនុ បានស្នើសុំអោយ លោក លន់ នល់ ដឹងនាំ រដ្ឋាភិបាល ស្រោចស្រង់ជាតិ ដោយមាន ផែនទីផ្លូវនយោបាយបីយ៉ាង : កែនយោបាយសេដ្ឋកិច្ច, ស្វែងរកផ្លូវថ្មី នៃអនាគតជាតិ និង ពិនិត្យឡើងវិញ នូវនយោបាយការបរទេស។

[24] លោក លន់ នល់ នៅពេលនោះ អញ្ជើញទៅព្យាបាលជម្ងឺនៅស្រុកបារាំងតាំងពីខែ សីហា ឆ្នាំ ១៩៦៩ម្លេះ។ នៅក្នុងរយៈពេលនោះ ទ្រង់ សិរិមតៈ, ឧបនាយករដ្ឋមន្រ្តីទី១ ជាអ្នក ទទួលកាន់ដំណែង បណ្តោះអាសន្ន ជានាយករដ្ឋមន្រ្តី នៃរដ្ឋាភិបាលស្រោចស្រង់ជាតិ។

នៅពេលនោះ រដ្ឋខ្មែរ ស្ថិតនៅក្នុង ភាពក្ស័យទន់ រហូត គ្មានលុយសំរាប់ ចំណាយបៀវត្ស ដល់អ្នករាជការ។ សេដ្ឋកិច្ចជាតិ ឋិតនៅក្នុង ភាពសន្លប់ល្អិតល្ហៃ (coma léthargique)។ ស្ថានភាពនេះគឺជាលទ្ធផល នៃនយោបាយសេដ្ឋកិច្ច តម្រង់ទិសទៅរក សេដ្ឋកិច្ចផែនការ នៃចលនាសង្គមរាស្ត្រនិយម។ រយៈពេល ដ៏រុងរឿង របស់ សង្គម វាមកដល់ទីបញ្ចប់, ដូច្នេះ កម្មវិធី សេរីរូបនីយកម្មសេដ្ឋកិច្ច នៃរដ្ឋាភិបាល ក្នុងវិស័យមួយចំនួន ត្រូវបានរដ្ឋសភា បោះឆ្នោតយល់ព្រមអោយអនុវត្ត។ នៅពេលសមាជជាតិ ចុងក្រោយ នៃរបបសង្គម, សម្តេច សីហនុ មានប្រតិកម្មប្រឆាំងនឹង នយោបាយសេដ្ឋកិច្ច របស់រដ្ឋាភិបាល ដោយបញ្ជាអោយរដ្ឋមន្ត្រី ស្មោះនឹងព្រះអង្គ លាលែងពីតំណែងមុនបើកសមាជជាតិ ដោយទ្រង់នឹកស្មានថា រដ្ឋាភិបាលនឹងលាលែងដែរ។ ការរង់ចាំរបស់ទ្រង់ វាកើតឡើងផ្ទុយទៅវិញ គឺថា មិនគ្រាន់តែ រដ្ឋាភិបាល មិនលាលែងតែប៉ុណ្ណោះទេ គឺថែមទាំង រើសជំនួសភ្លាម រដ្ឋមន្ត្រីលាលែងពីតំណែង ហើយនៅពេលសមាជាតិ បានតតាំង ខ្លាំងក្លានូវគ្រប់ ការចោទប្រកាន់ ពីវាគ្មិន បានរៀបចំដោយព្រះអង្គ ដើម្បីទំលាក់រដ្ឋាភិបាលអោយបាន។

ចំពោះ សម្តេច សីហនុ ព្រះអង្គខ្លួនឯង ទ្រង់មិនទទួលស្គាល់បរាជ័យ របស់សង្គម ដែលជាកូនជាទីស្រឡាញ់ របស់ទ្រង់។ ដូចយ៉ាង នៅខែ វិច្ឆិកា ឆ្នាំ ១៩៦៨ ព្រះអង្គ បាន

រៀបចំ ធ្វើបុណ្យ ដ៏អ៊ឹកធឹក នៃការរំលឹកខួបទី ១៥ឆ្នាំ នៃឯករាជ្យជាតិ ដោយមាន តាំងពិព័រណ៏ជាសាធារណៈ នៃស្នាដៃ របស់សង្គម។ ដូច្នេះ ទ្រង់មិនអាចយល់ព្រមបាននូវនយោបាយសេដ្ឋកិច្ចណាមួយ ដែលផ្ទុយ ពីនយោបាយសង្គម។ សួរថា នៅពេលជំនួប ជាមួយលោក លន់ នល់ តើទ្រង់អនុញ្ញាតអោយលោក លន់ នល់ សើរើ នូវទំនាក់ទំនងពិសេស របស់ព្រះអង្គ ជាមួយ ពួកយួនកុម្មុយនិស្ដ ដែរឬទេ ? ប្រាកដណាស់ហើយថា បញ្ហានេះ ទ្រង់ធ្លាប់បានលើកវាយក លាតត្រដាង ជាសាធារណៈ នៅឆ្នាំ ១៩៦៩ ចុះផ្សាយក្នុង ព្រឹត្តិប័ត្រ ជាភាសាបារាំង[25] « Réalité » បង្ហាញនូវទីតាំង របស់ពួកយួនកុម្មុយនិស្ដ នៅក្នុងដែនដីខ្មែរ។ មួយវិញទៀត គឺនៅថ្ងៃទី១៩ មីនា ឆ្នាំ ១៩៦៧, សម្ដេចសីហនុ បានធ្វើការអំពាវនាវសូមអោយប្រទេសទាំងឡាយទទួលស្គាល់ព្រំដែន និង គោរពបូរណភាព ដែនដីខ្មែរ។ ដូច្នេះ ច្បាស់ជាទ្រង់ លើកបញ្ហាដដែលនេះ មកពិគ្រោះគ្នាជាមួយលោក លន់ នល់ ដែលជានាយករដ្ឋមន្ត្រី ជាពុំខាន។ តែត្រង់ថា ទ្រង់ បានញុះញង់ អោយមាន ធ្វើបាតុកម្មប្រឆាំងនឹង វត្តមានពួកយួនកុម្មុយនិស្ដ នៅក្នុងស្រុកខ្មែរ វាហាក់បីដូចជា ព្រះអង្គស្មោះលើទ្រូងឯង ព្រោះនយោបាយ របស់ទ្រង់ វាពាក់ព័ន្ធនឹងបញ្ហានេះ។ មួយវិញ

25 ព្រឹត្តិប័ត្រ ចេះផ្សាយសំរាប់ រយះពេលពីថ្ងៃទី ១៦ ដល់ ថ្ងៃទី២៥ កក្កដា ឆ្នាំ ១៩៦៩។

ទៀត លោក លន់ នល់ គាត់មិនហ៊ានស្នើ នូវ វិធីនេះ នោះ ដែរ ព្រោះ បញ្ហារសើបនេះ ខ្មែរទូទៅ ទុកជាពុទ្ធសិទ្ធផ្តាច់មុខ របស់ព្រះប្រមុខរដ្ឋ។

ដូច្នេះ មេខ្លោង នៃ ការបះបោរ នៅខេត្តស្វាយរៀង វានៅតែជា កិច្ចការអាថ៌កំបាំង ចំពោះខ្មែរ។ ដែល វាជាការបើកទ្វារចំហ ដល់ការនិយាយខ្សឹបខ្សៀវ ជាការស្មាន នៅក្នុងគ្រប់មជ្ឈដ្ឋាន។ តែ ជនដែលគេសង្ស័យច្រើនជាងគេ គឺ ទ្រង់ សិរិមតៈ ឧបនាយករដ្ឋមន្ត្រីទី១ និងជារដ្ឋមន្ត្រីទទួលបន្ទុក ក្រសួងមហាផ្ទៃ ព្រោះគេសង្កេតឃើញថា គ្រប់សកម្មភាពរដ្ឋាភិបាល នៃទ្រង់ គឺមានទម្រង់ទល់មុខចំហនឹង នយោបាយ របស់សម្តេច សីហនុតែម្តង។ តែការពិត ការបះបោរ នៅខេត្តស្វាយរៀង កើតមកពីការមិនសប្បាយចិត្ត របស់ប្រជាកសិករសុទ្ធសាធ ដែលមានទំនាស់ជាមួយ ពួកយៀកកុង ព្រោះពួកនេះ ជូនកាលហាមឃាត់ពួកគាត់ មិនអោយ ដើរឆ្លងកាត់ ទីតាំងគេទៅកាន់ ដីស្រែគាត់ ដោយលើកហេតុថា រក្សាសន្តិសុខដំបន់គេ។ នៅទីតាំង យៀកកុងខ្លះទៀត ពួកទាហ៊ានយៀកកុង គេទុកខ្លួនគេជាម្ចាស់ទឹកដីតែម្តង ដែលវានាំបង្កើតរឿងរ៉ាវ ជាមួយអ្នកភូមិខ្មែរ ដែលរស់នៅក្បែរ ទីតាំងនោះ។ ការបះបោរនៅទីក្រុងភ្នំពេញ នៅថ្ងៃទី ១១ មីនា ក៏ជាការបះបោរ ដោយស្វ័យភាពដែរ ដើម្បីគាំទ្រកំហឹង នៃពួកបះបោរនៅខេត្តស្វាយរៀង។ ដោយសារ

ក្រុមប៉ូលិស សំរាប់រក្សាសេចក្តីរៀបរយ ខ្វះសមត្ថភាព វាធ្វើអោយការបះបោរនោះ ក្លាយទៅជាការវៃកំទេច ស្ថានទូត ពួកយៀកកុង និង យួនខាងជើង។ លោក អ៊ុន តាំ, នយជន[26] ខ្មែរម្នាក់, មានប្រសាសន៏ថា បើសិនជាលោកជាមេប៉ូលិស វិញ គឺលោក មិនឲការបះបោរ ក្លាយទៅជាអំពើហិង្សាដូច្នោះឡើយ។ ចំពោះលោក គឺវាមកពី កង្វះសមត្ថភាព នៃមេប៉ូលិសតែម្តង ដែលមានបេសកកម្មដើម្បី ស៊ុម នូវការបះបោរ។ សំដីនេះ បញ្ជាក់ថា ការបះបោរនោះ មិនមែនជា ការរៀបចំច្បាស់លាស់ ពីក្រុមនយោបាយណាមួយ ចង់ប្រឆាំងនឹងសម្តេច សីហនុ ព្រោះនៅពេលនោះ ពួកបាតុករ នាំគ្នាលើក ឆាយាល័ក្ខណ៏ ព្រះអង្គ។ លោក និយាយបន្ថែមទៀតថា បើគ្មាន ការវៃកំទេចស្ថានទូត គឺប្រហែលជាគ្មាន កើតព្រឹត្តិការណ៏ ថ្ងៃទី ១៨ មីនា នោះទេ។ ការបះបោរ នៅថ្ងៃទី ១៦ មីនា នៅមុខរដ្ឋសភា ក៏ជាការបះបោរដោយស្វ័យភាពដែរ ព្រោះវាជាការបន្តហេតុតែប៉ុណ្ណោះ តែនៅពេលនោះ មានការចែកខិត្តប័ណ្ណ ក្នុងនោះមាន ការញុះញុងអោយប្រឆាំងនឹងនយោបាយសម្តេច សីហនុ។ តែអ្នកចែកខិត្តប័ណ្ណពីរនាក់ត្រូវពួកបាតុករ ធ្វើប្រជាទណ្ឌ កុំតែបាន ពួកប៉ូលិស ជួយយកចេញបាន កុំអី ត្រូវគេ វៃស្លាប់ ជាពុំខាន។ តែរឿង

[26] នយជន ជាអ្នកនយោបាយ ទទួលកាន់កាប់អំណាចរដ្ឋណាមួយ ; le politique។

ពាក់ព័ន្ធនឹង ខិត្តបណ្ណនេះ វាមានទំនាក់ទំនង ដោយ ប្រយោលនឹងទ្រង់ សិរិមតៈ។
នៅក្នុង បរិបទ នៃការផ្តាច់ទំនាក់ទំនង រវាង សម្តេច នឹង រាជរដ្ឋាភិបាល ដែល សម្តេច ជាអ្នកផ្តើមផ្តាច់, ទ្រង់ សិរិមតៈ តម្រូវ មានប្រតិកម្ម, ពុំនោះសោធ គឺច្បាស់ជា ទុកឱកាសអោយសីហនុ ចាប់យកព្រឹត្តិការណ៍បាន ដោយ មានប្រតិកម្មហិង្សា ចំពោះ រាជរដ្ឋាភិបាល។ ទ្រង់យល់ ឃើញថា សីហនុ ទុកទ្រង់ជាសត្រូវទី១ ដែលត្រូវតែកំទេ ចចោល ព្រោះវាជាទម្លាប់ នៃរាជវង្សានុវង្សខ្មែរ។ បើ រង់ចាំ ប្រតិកម្ម នៃលោក លន់ នល់ នៅចំពោះមុខ គ្រោះថ្នាក់ នេះ គឺ ដូចជា រង់ចាំ ឃាតករ មកសម្លាប់ទ្រង់ តែម្តង។ មិនមែនថា ទ្រង់ គ្មានសេចក្តីទុកចិត្ត លើ លោក លន់ ន ល់ ដែលទ្រង់ទុកជា មិត្តល្អ នោះទេ តែទ្រង់ស្គាល់ ចិត្ត គំនិត នៃនាម៉ឺនខ្មែរទូទៅ ថាគ្មាន សេចក្តីក្លាហាន តាម ការអប់រំ ប្រទល់នឹង រាជសក្តិ ដែល សីហនុ ជាអវតា និង ជា ពន្លឺ នៃអត្តភាព របស់ពួកគាត់។ ត្រូវដឹងថា នាម៉ឺន ខ្មែរ មានសភាវគតិពីរយ៉ាងនៅសម័យនោះ : សភាវគតិ នៃសុភមង្គល ជាមួយ សម្តេចសីហនុ ជាព្រះ និង សភា វគតិ នៃហ្វូងសត្វ គឺថា ប្រតិបាទន៍ គ្មានលក្ខខណ្ឌ តាម លំដាប់បូរាណ[27]។

[27] លំដាប់បូរាណ ; ordre ancien។

នៅក្នុងប្រវត្តិសាស្ត្រខ្មែរ គ្រប់ការប៉ុនប៉ង របស់បថុជ្ជន ណាម្នាក់ ប្រឆាំងនឹង អំណាចស្តេច តែងតែទទួលបរាជ័យ ជានិច្ច ដូចយ៉ាង ស្តេចកន ទោះបីគាត់មាន ប្រជាប្រិយភាពច្រើនយ៉ាងណាក្តី ក៏នៅទីបញ្ចប់ គាត់ទទួលបរាជ័យ។ ដូច្នេះ គំនិតបដិវត្តន៍ ប្រឆាំងស្តេច ឬ លំដាប់បូរាណ នៅស្រុកខ្មែរ គឺជា អសិទ្ធិ (non-droit) សំរាប់ប្រជារាស្ត្រខ្មែរ។ លោក លន់ នល់ ជានាម៉ឺនខ្មែរ ទទួលការអប់រំពី សង្គមប្រពៃណី អោយគោរពបារមីស្តេច។ ចំពោះ លោក, ប្រភពដើម នៃជាតិខ្មែរ គឺ ស្ថាប័ន នៃរាជានិយម, ព្រះពុទ្ធសាសនា និង ទំនាមទំលាប់ នៃការរស់នៅ របស់ប្រជារាស្ត្រខ្មែរ តាំងពីបូរាណកាលមក។ ដូច្នេះលោក ទុកសម្តេចសីហនុ ជាតំណាងនៃប្រភពដើមខ្មែរ ដែលត្រូវតែគោរព។ បំពានដល់ បុគ្គលសីហនុ គឺទុកស្មើនឹងប្រព្រឹត្តល្មើស នៃប្រពៃណីជាតិ។ ការណ៍នេះ ជាការពិត នៅក្នុងសង្គមខ្មែរ ដែលជំរុញទ្រង់ សិរិមតៈ អោយដើរទៅមុខ មុនអ្វីដែលច្បាស់ជាមានកើតឡើង គឺ ប្រតិកម្មហិង្សា របស់សីហនុ។ ទ្រង់ដឹងថា ពេលវេលា កំពុងធ្វើការអោយសីហនុ ចំណេញកម្លាំងនយោបាយ បើទ្រង់ នៅរង់ចាំ នូវការសម្រេច របស់ លន់ នល់។ ចំពោះទ្រង់ ព្រឹត្តិការណ៍ ដែលកំពុងកើតឡើងនេះ ជាឱកាសដ៏ល្អ ដែលអាចនឹងបញ្ចប់ នូវរបៀបដឹកនាំជាតិ របស់សីហនុ ដែលធ្វើអោយប្រជារាស្ត្រខ្មែរ អាកខានដើរលើផ្លូវទំនើបនិយម និង កំពុងនាំប្រទេស

រំអិលខ្លួន ចូលក្នុងទ្រុងឃ្នួនកុម្មុយនិស្ត។ ចំពោះ ទ្រង់ សិរិមត:, ដើម្បី ការរីកចំរើន នៃប្រជាជាតិ ត្រូវចាំបាច់ ធ្វើសុខតមកម្ម (harmoniser) នូវ គោលវិធីថ្មី នឹង គោលវិធីបូរាណ ដោយថែរក្សារបស់ចាស់ និង បង្កើតរបស់ថ្មី តាមដំណើរ នៃការជឿនលឿន ទៅរក សមានកម្ម (assimilation) ពេញលេញ ដោយឆន្ទ:ស្ម័គ្រ តែជៀសវៀងដាច់ខាត បំផ្លាញប្រភពដើមពិសេស របស់ខ្មែរ ព្រោះអត្តភាពនិមួយៗ សុទ្ធតែមាន ភារ:អាស្រ័យហេតុ (raison d'être) របស់វា។ ទស្សន:នេះឯង ដែលនាំអោយ ទ្រង់ សិរិមត: ចាប់ពីដើមពេល បង្កើត ចលនាសង្គមរាស្ត្រនិយម ទ្រង់ ក្លាយជា ប្រតិជនសញ្ជឹង (opposant silencieux) នឹងនយោបាយ សីហនុ ទោះបីទ្រង់មិនចង់ក្តី។ ចំពោះទ្រង់, សីហនុ គឺដូចជាកូនក្មេង ដែលមានចិត្តសាវ៉ា ហើយ គ្មាននរណាម្នាក់ អាចបាន់ស្មានបានថា ព្រះអង្គ ចង់ធ្វើអ្វីមួយពិតប្រាកដនោះឡើយ, តែបើសិនជា សម្រេចធ្វើអ្វីវិញ ព្រះអង្គ ទុក ជនណា ដែលមិនយល់ស្របនឹង គំនិតព្រះអង្គ ជាសត្រូវនឹងព្រះអង្គតែម្តង។ ក្រោយៗមក, កបិចិត្ត (caprice) នេះ វានាំអោយ សីហនុ រស់នៅឯកា ក្នុងភពមនោគត[28] លែងដឹង នូវស្ថានភាពពិត នៃប្រជាជាតិ។ ដូច្នេះ ព្រឹត្តិការណ៏ ដែលកំពុងកើតឡើង នាំអោយទ្រង់ សិរិមត: សួរជាសំនួរ ដល់ខ្លួនឯងថា តើអាច ទុក៙

[28] Le monde imaginaire.

សីហនុ បន្តដឹកនាំជាតិ ដែលមានរបៀបគ្រប់គ្រង និង នយោបាយ ផ្ទុយនឹងប្រយោជន៍ នៃប្រជាជាតិ ដែរឬទេ ? សំនួរ បែបនេះ ទ្រង់ ក៏មានចោទសួរដែរក្នុងចិត្ត ចំពោះ លោក លន់ នល់ ដែលជាមិត្តភក្តិ និងជា គ្នីគ្នានយោបាយ នៃទ្រង់។ នៅសម័យនោះ ចំពោះមតិមហាជន គេទុក លោក លន់ នល់ ជាតំណាង នៃអភិរក្សនិយម, រីឯ ទ្រង់ សិរិមតៈ វិញ ជាតំណាង នៃទំនើបនិយម។ អ្នកនៅជុំវិញ លោកទាំងពីរនេះ ហៅលោក លន់ នល់ ថា តាខ្មៅ, រីឯ ទ្រង់ សិរិមតៈ វិញ តា-ស។ នេះគឺជាភាពខុសគ្នា រវាងអ្នក ទាំងពីរដែលកំពុងប្រឈមមុខនឹង ដោតវាសនារួម ក្នុង ព្រឹត្តិការណ៍ជាប្រវត្តិសាស្រ្តមួយ គឺ ប្រទូសភាព រវាង អំណាចរាជសក្តិ ដែលគេទុកជា អំណាចព្រះ នឹង អំណាច រាជរដ្ឋាភិបាល ដែលមាន ប្រជាពលរដ្ឋជាម្ចាស់។ នៅក្នុង វិនិបាទ (épreuve) នេះ តម្រូវអោយមានសេចក្តីក្លាហាន លើសលប់ ពីសំណាក់ ពួកគូប្រឆាំងនឹងព្រះ ព្រោះវាជា វិនិ បាទ ពិសេស ប្រទល់នឹង អំណាចរាជសក្តិ ដែលមានធាតុ សម្មតិ ៣ យ៉ាង ស្ថិតនៅលើ អំណាចមនុស្សលោក :

១. ព្រះមហាក្សត្រ ជា អាណត្តិគហក (អ្នកទទួលអំណាចពី) នៃ ព្រះធរណី។

២. ព្រះមហាក្សត្រ ជា អាណត្តិគហក នៃ ច្បាប់លោកធាតុ និង ព្រាហ្មណិកធម៌។

៣. ព្រះមហាក្សត្រ ជា អាណត្តិគហក នៃ ច្បាប់ លោកធាតុ និង ពុទ្ធកធម៌។

អំណាចនេះឯង ដែលសម្តេច សីហនុ ទ្រង់ ទាមទារ រហូតក្នុងនាមព្រះអង្គ ជា ឧភយោរាជ និង ព្រះប្រមុខរដ្ឋអស់មួយជីវិត នោះបីព្រះអង្គ បានបង្វែររាជ្យ ថ្វាយដល់ព្រះបិតា ហើយបន្ទាប់ពីព្រះបិតា សុគតទៅ ព្រះអង្គ ទុករាជបល្ល័ង អោយនៅទំនេរ ផ្ទុយនឹង រដ្ឋធម្មនុញ្ញ និង រាជប្រពៃណី។ ប្រទល់នឹង ចិត្តគំនិត អវិចារណ៏ របស់ សីហនុ បែបនេះ, វាពិបាកនឹងលើកយកច្បាប់ មករកខុសត្រូវជាមួយ ព្រះអង្គ ព្រោះព្រះអង្គ ទុកខ្លួន នៅលើច្បាប់ជាតិ។ ទ្រង់ សិរិមតៈ យល់ច្បាស់ណាស់ អំពី ចិត្តគំនិតនេះ ព្រោះទ្រង់ជាសមាជិក នៃព្រះរាជវង្សានុវង្ស។ ដូច្នេះ បើនៅតែស្វែងរកផ្លូវធម្មតា មកធ្វើជាដំណោះស្រាយ ជាមួយ សីហនុ គឺដូចជា ស្វែងរក ម្ជុល នៅក្នុងមហាសាគរ នោះឯង។ យល់ឃើញបែបនេះហើយ បានជាទ្រង់ អនុញ្ញាតឲចែកខិត្តប័ណ្ណ នៅថ្ងៃទី ១៦ មីនា។

នៅសម័យនោះ ទ្រង់ សិរិមតៈ ទ្រង់ ជាតំណាង នៃអ្នកកែទម្រង់, នៃពួក យុវអ្នករាជការ ទទួលការអប់រំទំនើប និងបញ្ញវន្ត ដែលយល់ឃើញថា ប្រជាជាតិ ត្រូវការ នូវកំណែទំរង់ ប្រកដនិយមមួយ ដើម្បី ស្រោចស្រង់ជាតិ។ ជាការពិតហើយ របបសង្គមរាស្ត្រនិយម ផ្តល់ នូវ ផាសុកភាព ជាសម្ភារៈ និង មោទនភាព មួយរយៈពេល ដល់ប្រជាជាតិ តែ

គុណលក្ខណៈនេះ គឺទុកដូចជា « សេចក្តីសុខ របស់ពួកអ្នកជក់អាភៀន » តែប៉ុណ្ណោះ។ ប្រជាជាតិ ត្រូវការអ្វីថ្មីមួយទៀត ព្រោះ សង្គម បានបង្ហាញ នូវដែនកំណត់របស់ខ្លួន មិនតែប៉ុណ្ណោះ វាក្លាយជា មារ នៃកំណែទំរង់តែម្តង។ ពីដំបូង គេចាប់ផ្តើមខ្សឹបគ្នា ចោទប្រកាន់ដល់ពួកអ្នកអបអម នៃសម្តេច សីហនុ ថាជា ប្រភព នៃអកុសល។ ក្រោយបន្តិចមក, គេ យល់ឃើញថា នយោបាយរបស់ សីហនុ វាខាយាំង មិនអោយស្រុកខ្មែរ ធ្វើទំនើបកម្មបាន។ ដូច្នេះ ពួក យុវរាជការ និង បញ្ញាវន្ត ភាគច្រើនត្រៀមខ្លួនរួចជាស្រេច ដើម្បី គាំទ្ររាល់ការផ្តួចផ្តើមកំណែទំរង់ ដែលមានទ្រង់ សិរិមតៈ ជាអវតា។ បញ្ញាវន្ត ភាគច្រើន ជា អ្នករាជការ ដូច្នេះ វាពិបាកនឹងបែងចែក អោយដាច់ស្រឡះ រវាងអ្នកពីរប្រភេទនេះណាស់។ តែក្រោយមក មានលក្ខណវិនិច្ឆ័យ បញ្ចេញដោយខ្លួនឯង នៅក្នុងមជ្ឈដ្ឋាន នៃ បញ្ញាវន្ត-មន្ត្រីរាជការជាន់ខ្ពស់ : ទុកជាបញ្ញាវន្ត គឺ អ្នកដែលមិនប្រព្រឹត្តិ នូវអំពើពុករលួយ ឬ ជាអ្នកជឿនលឿននិយម។

នៅក្នុងមជ្ឈដ្ឋាន ពាណិជ្ជករ, ស្ទើរតែទាំងអស់ មានដើមកំណើត ចិន និង យួន, ស្វាគមន៍ដល់ សេដ្ឋកិច្ចផ្សារ ដែលមាននៅក្នុងកម្មវិធី របស់រដ្ឋាភិបាលស្រោចស្រង់ជាតិ។ ដូច្នេះ វត្តមាន ទ្រង់ សិរិមតៈ នៅក្នុង រដ្ឋាភិបាល វាជាការធានាមួយបន្ថែម នូវការអនុវត្ត នៃកម្មវិធីនេះ។

ចំណែកលោក លន់ នល់ ជាអវតា នៃអ្នកអភិរក្ស ផ្ដល់ នូវការជានា ដល់មជ្ឈដ្ឋាន នៃសហធម្មិក (clergé) ពុទ្ធសាសនា។ ប៉ុន្តែ ត្រូវដឹងថា សហធម្មិក តែងតែ ប្រកាន់យកជំហរ អព្យាក្រឹត ជានិច្ច ចំពោះមុខ អំណាចរដ្ឋ រួមទាំងរាជអំណាច។ មែនពិត, ពុទ្ធសាសនាទេវតា នៅស្រុកខ្មែរជាសាសនា, តែប្រជាជនខ្មែរ ទុកជា របៀបរស់នៅ របស់ខ្លួនតែម្ដង : ខ្មែរ រស់នៅ តាមវិតិ នៃសង្គ្រោន្តពុទ្ធសាសនា, គោរព និង ហាត់ព្យាម នូវពុទ្ធសិក្ខាបទ, រហូតទុកជា គ្រឹះមួយ នៃប្រជាជាតិ ដូចយ៉ាង យកមកដាក់នៅក្នុង បាវចនៈនាជាតិ។ ដូច្នេះ ពុទ្ធសាសនា មានផលប៉ះពាល់សំខាន់ដល់ ជីវិតភាព របស់ប្រជាពលរដ្ឋខ្មែរ : ពុទ្ធសាសនា ជាកាល (ពេលវេលា នៃជីវិត) របស់ខ្មែរម្នាក់ៗ។ មហោទ្ធនុភាព អច្ឆមជាតិ និង អាថិកំបាំងនេះ ធ្វើសកម្មភាពជានិច្ច នៅក្នុងការរស់នៅ របស់ខ្មែរ។

# ភាគទី២

## វឌ្ឍកម្ម នៃកម្លាំងប្រឆាំងសីហនុ

នៅពេលរាត្រី នៃថ្ងៃទី១៦ មីនា ឆ្នាំ ១៩៧០ មានការប្រជុំពិសេសមួយ នៅគេហដ្ឋានលោក លន់ នល់ បន្ទាប់ពី សម្ដេច សីហនុ ទ្រង់ បដិសេធ មិនព្រមទទួលជួបប្រតិភូខ្មែរ ដែលបំរុងរួចស្រេចនឹងទៅ គាល់ព្រះអង្គនៅស្រុកបារាំង។ ប្រតិភូនោះ ដឹកនាំដោយ ទ្រង់ នរោត្ដម កន្ដុល ជាតំណាងពិសេស របស់ព្រះមាតាព្រះអង្គ ហើយមាន លោក យែម សម្បូរណ៍ និង ឧប គឹម អាង ជាសមាជិក ដើម្បីពន្យល់ ដល់ព្រះអង្គ អំពី ស្ថានភាពពិត ដែលកំពុងកើតឡើងនៅក្នុងប្រទេស និង ជំនួប រវាង ប្រតិភូរដ្ឋាភិបាលខ្មែរ ជាមួយ ប្រតិភូ នៃស្ថានទូត យួនខាងជើង និង យៀកកុង ដែលចាត់ទុកជាជំនួប គ្មានលទ្ធផលអ្វីបន្ដិចសោះ ព្រោះ ពួកយួន មិនព្រមលើកយកបញ្ហា នៃវត្ដមានកងទ័ពរបស់ពួកគេនៅក្នុងស្រុកខ្មែរ ហើយនឹង ព្រឹត្តិការណ៍ ចែកខិត្តប័ណ្ណនៅមុខរដ្ឋសភា នៅក្នុងខិត្តបណ្ណ មានសរសេរប្រឆាំងនឹង នយោបាយ របស់សម្ដេចសីហនុ។ អ្នកចូលប្រជុំ មាន លោក លន់ នល់ ទ្រង់ សិរិមតៈ ឧប គិម អាង (ឧបនាយករដ្ឋមន្ត្រីទី៣ ទទួលបន្ទុកក្រសួងសេដ្ឋកិច្ចជាតិ និង ហិរញ្ញវត្ថុ) ឆន សុខុម (រដ្ឋមន្ត្រីក្រសួងសិក្សាធិការជាតិ) អ៊ឹង ត្រាម៉ុញ (ទីប្រឹក្សាពិសេស របស់លោក

លន់ នល់ និង អតិតរដ្ឋមន្ត្រី)។ របៀបវារៈ គឺ ការរាស់ នៃ កម្លាំង របស់ប្រជាជាតិខ្មែរ ដើម្បី ប្រឈរមុខនឹងគ្រប់ព្រឹត្តិការណ៍ ដែលវានឹងអាចមានកើតឡើងនៅថ្ងៃស្អែក។ មកដល់រាត្រី ថ្ងៃទី១៦ មីនា គំនិតទំលាក់ សម្ដេចសីហនុ មិនទាន់ជាគំនិតដាច់ស្រេចនៅឡើយចំពោះលោក លន់ នល់ ព្រោះលោក ជាអភិរក្ស ដែលទុកសម្ដេចសីហនុ ជាគ្រឹះ នៃអភិរក្សនិយម។ ទោះបីរដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលមានលោក ជាអ្នកដឹកនាំ មានទំនាស់នយោបាយមួយចំនួនជាមួយ សម្ដេចសីហនុ តែលោកផ្ទាល់ គ្មានត្រណាក់ចិត្ត ជាមួយព្រះអង្គឡើយ។ ចំណែក សម្ដេចសីហនុ វិញ និង មាតារបស់ព្រះអង្គ ព្រមទាំង រាជវង្សានុវង្ស តែងតែទុកលោក ជាមនុស្សជឿទុកចិត្ត និងជាអ្នកការពាររបបរាជានិយម។ តាំងតែពីស្រុកខ្មែរ ទទួលបានឯករាជ្យមក សម្ដេចសីហនុ តែងតែតែងតាំងលោក លន់ នល់ ជាមេទ័ព នៃកងខេមរភូមិន្ទ ទោះបីដឹងច្បាស់ថា គាត់មានចំណេះដឹងតិចតួចក្នុងវិស័យយោធា។ ដូច្នេះ វាជាជម្រើសផ្អែកលើការជឿទុកចិត្តជាងសមត្ថកិច្ច ហើយលោក នល់ នល់ ដឹងខ្លួនច្បាស់ នូវព្រះហឫទ័យករុណានេះ។ អ្វីដែលគេទុកជា នយោបាយជាន់ខ្ពស់របស់សម្ដេចសីហនុ លោក លន់ នល់ ដឹងទាំងអស់ ហើយលោក យល់ព្រមទាំងអស់។ តែត្រូវដឹងថា នៅពេលនោះ គ្មាននរណាហ៊ាន ចេញមុខជំទាស់នឹងនយោបាយ របស់សម្ដេចសីហ

នុ នោះឡើយ។ បើមានខ្លះ ដូចករណី លោក សឹម វ៉ា, ដុក រាស៊ី, ខៀវ សំផន, ហ៊ូ យន់, ហ៊ុយ នឹម ជាអាទិ៍ ត្រូវសម្តេចសីហនុ ជេរជាសាធារណៈគ្មានសំចៃមាត់ ជូនកាលរហូតដូចករណីលោក ខៀវ សំផន ត្រូវបានអាមាត្យរបស់ព្រះអង្គ រៃសំរាតខោនៅតាមផ្លូវ និង ករណីលោក សឹម វ៉ា ឲបរិវារ ទៅវាយកំទេច រោងពុម្ភកាសែតរបស់លោក ហើយពួកអ្នកប្រឆាំងដាច់ខាត ជាពិសេស ពួកខ្មែរកុម្មុយនិស្ត ឬ ខ្មែរក្រហម ត្រូវប៉ូលិសនយោបាយ ចាប់យកទៅសម្លាប់ជាសម្ងាត់ រីឯពួកខ្មែរសេរីវិញ ដូចយ៉ាងករណី លោក ចៅ បូរី, ចៅ មាធូរ៉ា, សៅ ងុយ ត្រូវបាន តុលាសឹក កាត់ទោសប្រហារជីវិត ហើយ បាញ់ប្រហារជាសាធារណៈនៅត្រពាំងក្រឡឹង។

គេអាចចោទសួរ ជាសំនួរបានថា តើ លោក លន់ នល់ លោក បានចូលរួមជាមួយសម្តេច សីហនុ ប្រព្រឹត្តអំពើទាំងនោះដែរឬទេ ក្នុងឋានៈលោក ជាអ្នកដឹកនាំជាន់ខ្ពស់ម្នាក់ និង ជាមនុស្សជឿទុកចិត្ត របស់ព្រះអង្គ ?

សំនួរនេះ ក៏វាមានដែរនៅក្នុងសតិសម្បជញ្ញៈ របស់លោក លន់ នល់ ដែលនាំឲលោកមានការរួញរានៅក្នុងអារម្មណ៍ នឹងដាក់ចិត្ត ប្រឆាំងដាច់ខាតនឹងសម្តេចសីហនុ ជាពិសេស នៅលើចំណុច នៃវិបត្តិធំ ជាមួយយួនកុម្មុយនិស្ត ដែលលោកដឹងច្បាស់ថាសម្តេចសីហនុ ក៏កំពុង ត្រដោះន្ទូវបញ្ហាចំពាក់ចាក់ស្រះនេះដែរ តែធ្វើទៅតាមគោលការណ៍

របស់ព្រះអង្គ គឺដំណោះស្រាយតាមផ្លូវទូត។ ការវាយកំទេចស្ថានទូត យួនខាងជើង និង វៀកកុង ដោយយុវជន ដែលមិនបានគ្រោងទុក តើវាជាទិន្នការណ៍ថ្មីសំរាប់លោក លន់ នល់ និង សម្តេចសីហនុ ? ចំពោះលោក អ៊ិន តាំ ទង្វើនេះ គឺពិតជាការពួតភ្លើង នៃព្រឹត្តិការណ៍ ថ្ងៃទី១៨ មីនា។ សម្តេចសីហនុ ជាបុគ្គល មានចរិតឆេវឆាវ ដែលនាំឲព្រះអង្គ មិនអាចទប់កំហឹងព្រះអង្គបានឡើយ នៅចំពោះមុខព្រឹត្តិការណ៍បែបនេះ។ កំហឹងនេះឯង ដែលជាកត្តានាំបង្កើតកោលាហលដល់ប្រជាជាតិខ្មែរ។ នៅពេលនោះ បើព្រះអង្គ សុខចិត្តឲគេណប្រតិភូ ដឹកនាំដោយទ្រង់កន្តុល ដែលរាជរដ្ឋាភិបាល ព្រមទាំងមាតាបស់ព្រះអង្គ បំរុងបញ្ជូនចូលគាល់ ដើម្បី ថ្វាយជូនព័ត៌មាន អំពីព្រឹត្តិការណ៍ពិត ដែលកំពុងកើតមាន នៅក្នុងប្រទេស ប្រហែលនឹងអាច មានដំស្រាយ នូវការយល់ច្រឡំគ្នា រវាងព្រះអង្គ នឹង រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ។

តែដំណើរ នៃព្រឹត្តិការណ៍នេះ វានាំទៅរកទំនាស់ធំចម្បងរវាង រាជាអំណាច នឹង ប្រជាអំណាច ដែលវាស្ថិតនៅក្នុងសភាពសម្ងាត់ ចាប់តាំងពីឆ្នាំ ១៩៦៧ មកម្លេះ ដែលវាចាំតែមានផ្កាភ្លើង នឹងអាចនាំឲឆេះស្រុកខ្មែរជាភ្លើង នៃវិបត្តិនយោបាយ។

សួរថាតើទ្រង់ សិរិមតៈ ជាចំណែក នៃផ្កាភ្លើងមួយដែរឬទេ ?

ចំពោះលោក លន់ នល់ រវត្តមានទ្រង់ សិរិមតៈ នៅក្នុងរដ្ឋាភិបាល ជាទម្ងន់នយោបាយ សំរាប់បំពេញបេសកកម្មដ៏ពិបាក គឺស្រោចស្រង់ជាតិ ដែលជាគោលដៅ កំរិតដោយសម្តេចសីហនុ។ ក្នុងឋានៈ ជាឧបនាយករដ្ឋមន្រ្តីទី១ និងរដ្ឋមន្រ្តីក្រសួងមហាផ្ទៃ ទ្រង់មានភារៈរៀបចំឲមានសណ្តាប់ធ្នាប់ឡើងវិញ នូវដំណើរការ ជា ធម្មតា, ប្រក្រតី និងប្រកបតាមឋានានុក្រម រវាង រដ្ឋបាលមជ្ឈឹម នឹង រដ្ឋបាលខេត្ត និង អង្គការរដ្ឋដ៏ទៃទៀត នៅក្នុងព្រះរាជាណាចក្រ។ ត្រូវដឹងថា អភិបាលខេត្ត និង អ្នកដឹកនាំ អង្គការរដ្ឋមួយចំនួនធំ បានទទួល ដំណែង ដោយសារខ្លួនជាអ្នកអបអម នៃសម្តេចសីហនុ និង គ្រួសារ នៃអ្នកម្នាង មូនិច ដែលនាំឲពួកទាំងនោះ មិនសូវគោរព ចំពោះអំណាចក្រសួង ដែលខ្លួននៅក្រោមការត្រួតត្រា។ ស្ថានការណ៍បែបនេះ នាំបង្កើត រដ្ឋបាលស្របគ្នា ដែលជាបណ្តាញ នៃអំពើពុករលួយ បង្កើតជំងឺ រលួយជាតិ។ វាយប្រហារចំណុចនេះ គឺវាច្បាស់ជា នឹងទង្គិចអំណាចសម្តេចសីហនុជាពុំខាន ដូច្នោះ ទ្រង់ សិរិមតៈ បានក្លាយ ជាសត្រូវ នៃអំណាច របស់ព្រះប្រមុខរដ្ឋ ដែលនាំអោយសម្តេចសីហនុយល់ឃើញថា គ្រប់គម្រោង នៃរដ្ឋាភិបាលស្រោចស្រង់ជាតិ ជាវិធានការ ប្រឆាំងនឹងព្រះអង្គតែម្តង ដែលមានទ្រង់ សិរិមតៈ ជាមេនាំ។ ការប៉ះទង្គិចគំនិតគ្នាផ្ទាល់ រវាង

ស្តេចទាំងពីរអង្គនេះ នៅក្នុងសមាជាតិ ទី២៨[29] រិតតែបញ្ជាក់ ដល់សម្តេចសីហនុ ថាព្រះអង្គ កំពុងតែប្រឈមមុខ ទល់នឹងសត្រូវមួយ ដែលគ្មាន ការរញ៉េរញ៉ៃប្រឆាំងនឹងព្រះអង្គនោះឡើយ។ រីឯទ្រង់ សិរិមតៈ វិញ ទ្រង់ មានភាពស្មោះត្រង់ធម្មតា ចំពោះ សម្តេចសីហនុ ក្នុងឋានៈជាព្រះរាជវង្សានុវង្ស តែទ្រង់ មិនអនុគ្រោះ ដល់គោលវិធី នៃរបៀបដឹកនាំ របស់សីហនុ នោះឡើយ។ និវត្តន៍ នៃទ្រង់ចូលក្នុងជីវិតនយោបាយឡើងវិញ តាមការអញ្ជើញ របស់លោក លន់ នល់ ឲចូលរួម បង្កើតរដ្ឋាភិបាលស្រេចស្រង់ជាតិ វាស្ទើរតែជាការតព្វកិច្ច ជាខ្មែរមួយរូបសំរាប់ទ្រង់ដោយមើលឃើញថា ជាតិកំពុងជួបនឹង អន្តរាយគ្រប់វិស័យ។ ទំនាក់ទំនងទ្រង់ ជាមួយលោក លន់ នល់ វាមានរឿងចាស់រួមគ្នា គឺថា នៅឆ្នាំ ១៩៥១ លោកទាំងពីរ បានរួមគ្នាជួយ គណបក្សនយោបាយ ខេមរៈប៉ុណ្ណការ[30] ហើយនៅពេល បោះឆ្នោតសាកល ជ្រើសរើសតំណាងរាស្ត្រ គណបក្សនេះ ទទួលបានអាសនៈពីរ។ ទោះបីក្រោយមក លោកទាំងពីរ បោះបង់ជីវិតនយោបាយ តែលោកនៅតែ រក្សាមិត្តភាពជានិច្ច, លោក លន់ នល់ ជ្រើសរើស អាជិ

[29] សមាជជាតិទី២៨ ជាសមាជចុងក្រោយ នៃរបបសង្គមរាស្ត្រនិយម ធ្វើឡើងនៅក្នុងថ្ងៃទី ២៧, ២៨ ខែធ្នូ ឆ្នាំ ១៩៦៩។ នៅពេលសាមាជនោះ សម្តេច សីហនុ ហាមមិនឲតំណាងរាស្ត្រ ចូលរួម ព្រោះរដ្ឋសភា មានទំនាស់នយោបាយជាមួយព្រះអង្គ ដ្បិត រដ្ឋសភានេះ បោះឆ្នោតព្រមឲរដ្ឋាភិបាលធ្វើឯកជនភាវូបនីយកម្ម វិស័យធានាគារ និង សេវាធានារ៉ាប់រង។
[30] គណបក្សនេះ បង្កើតដោយលោក ញឹក ជូឡុង នៅឆ្នាំ ១៩៤៧។

ពយោធា ជាផ្លូវជីវិត រីឯទ្រង់ សិរិមត: ជ្រើសយក អាជិពទូត ជាចំណង់ចូលចិត្ត។ មាគ៌ាជីវិតពីរខុសគ្នាពិត តែនៅក្នុងគោលដៅរួម គឺទុកខ្លួនជាអ្នកបំរើជាតិ។ នៅពីចម្ងាយពិត តែទ្រង់សិរិមត: នៅតែតាមសង្កេត ការដឹកនាំរបស់សម្តេចសីហនុ ហើយតាមពេលវេលាបន្តៗមកទ្រង់មើលឃើញថា នយោបាយនោះ ទទួលបរាជ័យជាក់ស្តែង ដែលវាមាន ដើមហេតុ ពីរយ៉ាងផ្គួបគ្នាគឺ : ជម្រើសនៃបន្ទាត់នយោបាយភាន់ច្រឡំ និង ចរិត របស់ សីហនុ។ ដូចយ៉ាង សាទរ នៃរបបសង្គមរាស្ត្រនិយម មាននៅក្នុងអារម្មណ៍ខ្មែរ ប្រែក្លាយបន្តិចម្តងៗ ទៅជា ដំណើរនៃ កង្វះជំនឿ, មន្ទិល, គុណវិបត្តិ នៃខ្លឹមសាររបបតែម្តង។ ការរំដើបរំជួល ជាការបារម្ភនេះ កើតចេញពីហិង្សា នៃទ្រុស្តសីលគំនិត (mauvaises pensées) របស់សម្តេចសីហនុ ដែលជាធាតុជម្មជាតិ នៃចរិក របស់ព្រះអង្គ។ ចរិកសាវ៉ាបែបនេះ វាខាយាំងអ្នកស្នេហាជាតិគ្រប់រូបមិនឲធ្វើការបំរើជាតិបាន, វាហាក់បីដូចជា សេចក្តីស្រឡាញ់មាតុភូមិ វាជា និវារណដ្ឋាន[31] សំរាប់អ្នកទាំងនោះ។ សម្តេចសីហនុ ព្រះអង្គពាក់ មិនត្រឹមតែងារជាបីតាជាតិ គឺទ្រង់ទុកប្រជាជាតិ ជាសម្បត្តិផ្ទាល់ របស់ទ្រង់ ហើយ ទ្រង់ដឹកនាំជាតិបែបហិនហៃ[32]បំផុត។ ប្រជាភិថុតិ របស់ព្រះអង្គ វាជាអ

31 និវារណដ្ឋាន, កន្លែងហាមមិនឲរស់នៅបាន។
32 ហិនហៃ, ដែលថោកផងហៃខាងខូច។

វតា នៃ ប្រជានិយម-ផ្ដាច់ការ ដែលទុក គំនិតស្នេហាជាតិ អ្នកដទៃ ជាសត្រូវនឹងព្រះអង្គ។ បន្ទាប់ពីស្រុកខ្មែរ ទទួលបានឯករាជ្យមក ប្រទេសបានធំដឹងក្ដី តែសម្ដេចសីហនុវិញ គំនិតព្រះអង្គ ស្ថិតនៅកំចិជានិច្ច ដែលវានឹងនាំគ្រោះថ្នាក់ដល់ប្រជាជាតិ។ ចំណាប់អារម្មណ៍ របស់ទ្រង់សិរិមតៈ នេះឯង ដែលនាំឲទ្រង់មាន សេចក្ដីប្ដេជ្ញាចិត្តនឹងប្ដូររបៀបដឹកនាំ ហើយ កតិកា[33]នេះ លោក លន់ នល់ ដឹងច្បាស់ណាស់ថាទ្រង់ សិរិមតៈ មិនស្ទាក់ស្ទើរទៀតឡើយក្នុងផ្លូវចិត្ត ប្រឆាំងនឹងកបិចិត្ត[34] របស់សម្ដេចសីហនុ។ ជាឧទាហរណ៍ នៅពេលលោក លន់ នល់ អញ្ជើញទៅព្យាបាលជម្ងឺនៅប្រទេសបារាំង ពីថ្ងៃទី ៣០តុលា រហូតដល់ថ្ងៃទី១៨កុម្ភៈ ឆ្នាំ ១៩៦៩, ទ្រង់ សិរិមតៈ ត្រូវបានតែងតាំង ជានាយករដ្ឋមន្ត្រីស្ដីទី ហើយ ក្នុងរយៈពេលនោះ ទ្រង់ ដឹកនាំនយោបាយ កែទម្រង់ ដែលជានយោបាយផ្ទុយពីគំនិតរបស់សម្ដេចសីហនុ ទាំងស្រុង។ ការកែទម្រង់នេះ ជាសារមួយដល់ជីវកម្លាំងជាតិទាំងឡាយថា នៅស្រុកខ្មែរ វាអាចមាន នយោបាយផ្សេងមួយទៀតពីនយោបាយ របស់សម្ដេចសីហនុ ដែលវាអាចនាំប្រទេសចេញពីអន្តរាយជាតិ។ ចំពោះទ្រង់សិរិមតៈ ចលករ នៃអភិវឌ្ឍន៍ គឺ ព្រលឹងស្មារតីនៃមនុស្ស គឺថា ភារៈមនសិការ ជាអំណោយផល ដល់ ការ

[33] កតិកា, សេចក្ដីប្ដេជ្ញាចិត្ត។
[34] កបិចិត្ត, ចិត្តសាវ៉ា, Caprice.

អភិវឌ្ឍន៍ ប្រយ័ត និង ទទួលការខុសត្រូវ។ សេដ្ឋកិច្ចជាតិខ្មែរ ត្រូវមានមូលដ្ឋាន នូវការទំនាក់ទំនង ដែលមានគ្រឹះជាការប្តូរពាណិជ្ជកម្ម ជាមួយប្រទេសដទៃទៀត នៅក្នុងដំបន់ និង នៅលើពិភពលោក។ ដូច្នេះ វាជាការចាំបាច់នឹងបើកទ្វារប្រទេស ដើម្បីឲសេដ្ឋកិច្ចជាតិ អាចដកដង្ហើម នូវខ្យល់ នៃការរីកចម្រើន, បើនិយាយឲខ្លី គឺត្រូវធ្វើសេដ្ឋកិច្ចសេរីពិតប្រាកដ។ ការការពារ គំនិតផ្ទុយដាច់ខាតពីសម្តេចសីហនុ នៅចំពោះមុខផ្ទាល់ នៅក្នុងសមាជាតិលើកទី២៨ ដោយគ្មានស្ទើបក្នុងចិត្តសោះ ជាការបញ្ជាក់ចំពោះលោក លន់ នល់ ថា ទ្រង់សិរិមតៈ ទ្រង់នឹងដើរទៅមុខ មិនបកក្រោយវិញឡើយ គឺថា យកនូវជម្រើសនៃយោបាយថ្មី សំរាប់ស្រោចស្រង់ជាតិ ជាគំនិតស្លាពរ។ ព្រឹត្តិការណ៍ ដែលមានកើតឡើងបន្ទាប់មក វាជាលាភជ័យមួយ សំរាប់សមិទ្ធិកម្ម នូវការប្តូរនយោបាយក្បៀយធនរបស់សម្តេច សីហនុ។ ទ្រង់សិរិមតៈ មានប្រតិកម្ម ដូចលោក Jule Ferry[35] ដែលមាន ទស្សនៈថា កាលានុវត្តភាព (opportunité) វាមាន តួនាទីសំខាន់ណាស់ នៅក្នុងនយោបាយ ដែលវាប្រៀបដូចនឹង សិល្បៈ នៃវិទ្យាសាស្ត្រ។ ចំពោះទ្រង់ នៅពេលដែលការដឹកនាំផ្តាច់ការ ក្លាយជា

---

[35] នយជន (le politique) បារាំងនៅសតវត្សទី១៩ ដែលបានធ្វើកែទម្រង់សំខាន់ ដូចយ៉ាង សេរីភាព នៃសារព័ត៌មាន, សេរីភាព ឃុំ និង សហជីព, សាលាបឋមសិក្សារ បរិស័ទ ជាការិយកម្ម និង គ្មានយកតម្លៃ។

ប្រព័ន្ធ វាត្រូវមានជាចាំបាច់ គណបក្សប្រឆាំងមួយ ដើម្បីប្រឈមមុខនឹងប្រព័ន្ធនោះ។ គណបក្សប្រឆាំងនៅពេលនោះ គឺ រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ និង រដ្ឋសភាដែលទ្រង់ ទុកជាកម្លាំង នៃការកែទម្រង់ ដែលជាកាលានុវត្តភាព ដែលត្រូវតែចាប់យកជាចាំបាច់។

ការប្តេជ្ញាចិត្តខ្ជាប់ខ្ជួន តាំងពីដើមកំណើត នៃរដ្ឋាភិបាលស្រោចស្រង់ជាតិ រហូតមកដល់រាត្រីថ្ងៃទី១៦ មិនា របស់ទ្រង់ អំពីការកែទម្រង់ជាតិ នាំឲលោក លន់ នល់ ប្តូរសេចក្តីសម្រេចចិត្ត នៅចំពោះវិបត្តិនយោបាយ ដែលកំពុងកើតឡើង។ ដើមឡើយលោក ហាក់បីដាមានការទើសទាល់ចិត្តនឹងដើមគំនិត របស់ទ្រង់សិរិមតៈ ក្នុងរឿងជាប់ទាក់ទង នៃការបោះខិត្តប័ណ្ណ ប្រឆាំងនឹងសម្តេចសីហនុ ព្រោះលោក នៅមានជំនឿថា លោកនឹងអាចរកដំណោះស្រាយជាមួយនឹងសម្តេចសីហនុ បាន។ តែ ការជជែកពិភាក្សាគ្នា ក្នុងរត្តិកាលថ្ងៃទី១៦ នាំរំលេច នូវគំនិតសំខាន់ជាច្រើន ដែលធានាដល់លោកថា សម្តេចសីហនុ មិនមែនជាមនុស្ស ដែលមិនអាចប៉ះពាល់បានឡើយ។ ក្នុងករណីណាក៏ដោយ ព្រះអង្គ ក៏មិនមែនជាអាទិទេពនោះដែរ ព្រោះស្រុកខ្មែរ មានរដ្ឋធម្មនុញ្ញ សំរាប់ដោះស្រាយ ជម្លោះនយោបាយ រវាង ស្ថាប័ន និង ស្ថាប័ន។ អ្វីដែលមិនទាន់ដឹង គឺប្រតិកម្ម នៃប្រជារាស្ត្រ នៅពេលណា

ដែលមាននរណា ហ៊ានបំពានបុគ្គលសីហនុ ដែលប្រជារាស្ត្រទុកជានរទេព[36]។

នៅលើចំណុចនេះលោក ឧប គឹម អាង លោក បង្ហាញទស្សនៈ ដើម្បី ស្រាក នូវការបារម្ភរបស់លោក លន់ នល់ : *ពិតណាស់ថា ប្រជារាស្ត្រខ្មែរ នៅតែទុកក្នុងចិត្តថា សម្តេចសីហនុ ជាព្រះមហាក្សត្រ ដែលមិនអាចនរណាម្នាក់បំពានបាន តែបើហ៊ានធ្វើ វានឹងអាចនាំបង្កើតការបង្ហូរឈាម និង សង្ករនៅក្នុងព្រះនគរ។ ដូច្នេះ ការប្តូរ របបនយោបាយ របស់សម្តេច ត្រូវប្រើវិធីសាស្ត្រ តឹងរ៉ឹង និង ប្រយ័ត គឺថា បន្តុះបង្អាប់ សីហនុ ជានយជន តែជៀសនឹងប៉ះពាល់ដល់សីហនុ ជាអភិសិត្តរាជ។ ត្រូវកុំភ្លេចថា ទំនាស់ដែលមានកើតឡើង គឺជាព្រឹត្តិការណ៍ នៃប្រវត្តិសាស្ត្រ ដែល រាជរដ្ឋាភិបាល ប្រឆាំងចេញមុខនឹងព្រះម្ចាស់នៃព្រះរាជាណាចក្រ។* ទស្សនៈនេះ គឺលោក ចង់បញ្ជាក់ថា អ្វីដែលត្រូវជៀសវាង គឺ ការបំបាក់មុខ នៃរាជានិយម ដែលប្រជារាស្ត្រ ទុកជាម្លប់ នៃសេចក្តីសុខ។

ចំពោះលោក ឆន សុខុម : *រាជរដ្ឋាភិបាល ដែលទទួលអំណាចពីរដ្ឋសភា ដើម្បីដឹកនាំជាតិ ត្រូវប្រើអំណាចពេញច្បាប់នេះ ដើម្បីប្រឆាំងនឹងនយោបាយបំផ្លាញជាតិ របស់សម្តេច។ បើនៅនាំគ្នារញ៉រ៉ា ច្បាស់ជាពេលវេលា វានឹងហុចឱកាស ឲសម្តេចវិលត្រឡប់ចូលស្រុក ហើយនឹងយកជន*

36 នរទេព, ទេវតានៃមនុស្ស។

*ទាំងឡាយ ដែលទ្រង់ទុក ជាអ្នកក្បត់នឹងព្រះអង្គ ទៅប្រហារជីវិតនៅត្រពាំងក្រឡឹងជាពុំខាន។ ត្រូវដឹងថា ពួកយើងនេះឯង ដែលព្រះអង្គ ទុកក្នុងព្រះហឫទ័យរួចហើយថាជា ជនក្បត់ជាតិ, ដូច្នេះ ហេតុអ្វី ក៏យើងមានគំនិតស្រអ័ព្ទម្លេះ ដល់ទៅជាលូង់ នាំគ្នាអង្គុយចាំមច្ចុរាជ មករៀបចំពិធីហុតកម្ម (បូជាយញ្ញ)* !

រីឯទ្រង់ សិរិមត: វិញ ទ្រង់មានសម្លេងខែងពិត តែរក្សានូវអេកប្បកិរិយាស្ងប់ស្ងាត់ជានិច្ច នៅពេលដែលទ្រង់ ចង់ពន្យល់លោក លន់ នល់ អំពីនយោបាយអព្យាក្រឹត និង ចរិកគ្មានហិនហុន[37] របស់សម្ដេច : *សម្ដេច សីហនុ មិនត្រឹមតែយក យួនកុម្មុយនិស្តជាមិត្ត តែប៉ុណ្ណោះទេ គឺព្រះអង្គជួយពួកនេះផ្ទាល់ ដោយបំពាន នយោបាយអព្យាក្រឹតរបស់ព្រះអង្គតែម្ដង។ ព្រះអង្គ មានហិនលក្ខណ៍[38] មួយអាក្រក់បំផុត គឺការមិនទទួលខុសត្រូវ, នៅពេលណាដែលព្រះអង្គធ្វើខុស ព្រះអង្គតែងតែរកអ្នកណាម្នាក់ ឬ ក្រុមណាមួយ យកគេមកធ្វើជា អ្នកមានទោស ឬ ជា អ្នករងកំហុស (bouc émissaire) ដើម្បីយកមកធ្វើប្រជាទណ្ឌ នៅចំពោះមុខប្រជារាស្ត្រ។ មនុស្សបែបនេះ តើយើងនៅមានសង្ឃឹមអ្វីទៀត នឹងខ្ចីឃ្លាតរកដំណោះស្រាយ តាមផ្លូវបញ្ញាដែលជាផ្លូវដាច់ស្រយាល គ្មានទាំងទីកន្លែងដែលត្រូវទៅ*

37 ហិនហុន, ការស្គាល់ខុសត្រូវ។
38 ហិនលក្ខណ៍, ដែលមានលក្ខណ:ថោក។
*(note de bas de page - suite)*

*ដល់ផង។ សម្ដេច ទ្រង់ស្គាល់តែដំណោះស្រាយតែមួយគត់ គឺត្រូវតែ ចុះចាញ់អញ ហើយត្រូវនាំគ្នា ហ៊ៅ[39] អញតែប៉ុណ្ណោះ។ ច្បាប់ដែលសម្ដេច យកមកអនុវត្ត គឺច្បាប់សងសឹក (loi du talion) ពោលថា ជាច្បាប់ ផ្ដន្ទាទោសមនុស្ស ដោយ សម្លាប់ចោលតែម្ដង ព្រោះឯងប្រឆាំងនឹងអញ ហើយ យកខ្មោច ទៅចោលលើគំនរខ្មោច បន្ទាប់មក យកឈាម មកលាងដៃប្រលាក់ឈាម។ សម្ដេច ជាសុភាពបុរស វាគ្រាន់តែជាការស្រមៃ របស់ប្រជារាស្ត្រសុពចៈ (មិនរឹងរូស) តែបើនៅចំពោះមុខប្រជារាស្ត្រ ជាពលរដ្ឋ ស្គាល់សិទ្ធិខ្លួន ច្បាស់ជាព្រះអង្គ មានចរិក ជាបុរសអនាគម[40] ដែលមិនបិតនៅក្នុង សណ្ដាប់ធ្នាប់ នៃទសពិធរាជធម៌ ជាពុំខាន។*

នៅត្រង់ចំណុចនេះទ្រង់សិរិមតៈ មានបំណងចង់ បញ្ជាក់ថាទ្រង់ មានកង្វល់តិចតួចអំពីប្រតិកម្ម នៃប្រជារាស្ត្រគាំទ្រស្ដេចសីហនុ ព្រោះនៅក្នុងទំនៀមខ្មែរ ស្ដេចណាដែលជាអ្នកដឹកនាំជាតិ មិនគោរពទសពិធរាជធម៌ និងជាមនុស្សមានះ តែងតែប្រជារាស្ត្រស្អប់ខ្ពើមជានិច្ច ដ្បិតថា ប្រជារាស្ត្រខ្មែរជា ពុទ្ធមាមកៈ។ ប្រជារាស្ត្រខ្មែរ ជាប្រជារាស្ត្រសុពចៈពិតចំពោះអ្នកដឹកនាំ តែតែងតែ សង្រះ[41]

---

39 ហ៊ៅ, ឈរឱបដៃគំនាប់ ឬ ប្ដឹង។
40 មនុស្សអនាគម, មនុស្សតាមចិត្តទើង លះបង់នូវទម្លាប់ល្អ។
41 សង្រះ, ពីគ្រោះគ្នា, ប្រឹក្សាគ្នាអោយឃើញខុសត្រូវ។

ហើយបន្ត ដើបជាសម្ព័ន្ធ ប្រឆាំងជានិច្ចនឹងអំពើអប្រិយ នាពេលណាមានឥស្សរជនណាម្នាក់ ហ៊ានចេញមុខដឹកនាំបដិវត្តន៍។

មុននឹងមកជួបលោក លន់ នល់ ទ្រង់សិរិមតៈ បានប្រាប់លោក ឧប គឹម អាង ឲទៅសួរយោបល់លោក អ៊ិន តាំ ក្នុងឋានៈលោកជាប្រធានរដ្ឋសភាស្ដីទី អំពីលក្ខខណ្ឌ ដែលអាចបញ្ឈប់ដំណែង ប្រមុខរដ្ឋអស់មួយជីវិត។ ចំពោះលោក អ៊ិន តាំ ដំណែងនេះ ជាដំណែងតែងតាំង ដោយសភា (រដ្ឋសភា និង ក្រុមព្រឹក្សាព្រះរាជាណាចក្រ) ដូច្នេះសភា អាចដកហូតដំណែងនេះបានគ្រប់ពេលវេលា ព្រោះមានតែ ព្រះមហាក្សត្រមួយអង្គគត់ ដែលមានតំណែងអស់មួយជីវិតដែលមានចារនៅក្នុងរដ្ឋធម្មនុញ្ញ។ យោបល់នេះទ្រង់ សិរិមតៈ បានយកមកជំរាបបន្ថែមដល់លោក លន់ នល់ នៅពេលប្រជុំ ព្រោះទ្រង់យល់ឃើញថាលោក លន់ នល់ ធ្លាប់ធ្វើចៅក្រម មុននឹងធ្វើទាហ៊ាន ដូច្នេះលោកនឹងយល់អំពីបញ្ហាគតិយុត្តនេះ។ ចំណុចនេះ ហាក់បីដូចជា ទាក់ទាញការយកចិត្តទុកដាក់លោក លន់ នល់ ព្រោះនៅក្នុងជីវិត របស់លោក លោកតែងតែទុកផ្លូវច្បាប់ ជាផ្លូវសីលធម៌។ អគ្ឃយោបល់[42] របស់លោក អ៊ិន តាំនេះ វាហាក់បីជួយកំលាចិត្តលោក ឲធ្វើការសម្រេចចិត្តនៅចំពោះមុខវិញ្ញាសា នៃជីវិតរបស់លោក ដែលលោក

---

42 អគ្ឃយោបល់, យោបល់មានតម្លៃ។

នឹកនៅក្នុងចិត្តលោកថា វាអាចជាអំពើក្បត់ជាតិ ព្រោះជាអំពើក្បត់ព្រះម្ចាស់ផែនដី ដូចយ៉ាងលោក ដាប ឈួន បានប្រព្រឹត្តិ ហើយដែល មានលោក ជាមេបញ្ជាការ នៃប្រតិបត្តិការ តាមចាប់ជនក្បត់នេះ ដើម្បីប្រហារជីវិត។ យោបល់ទាំងឡាយ ដែលលោក លន់ នល់ ប្រយ័តស្ដាប់ និង ប្រមែប្រមូល យកមកពិចារណា អស់មួយរាត្រី វាមានអនុភាពខ្លាំង ទៅលើសតិសម្បជញ្ញៈ របស់លោក ដែលនាំប្ដូរ បុព្វចរិយា ពីអ្នកសីហនុនិយមគ្មានលក្ខខណ្ឌ ស្រប់ក្នុងម្លប់[43]បារមីព្រះខាន់រាជ្យ ហើយនិង ធ្លាប់អង្គុយហួប[44] ជាមន្ត្រីក្នុងក្រឡាព្រះគំនាល់ ទៅជា ឧទ្ទាមឥតសីមា, តើលោក ភាន់ប្រាជ្ញា ទេដឹង ? ទេ, លោក លន់ នល់ ក្រោយពីបានពិចារណាអស់មួយរត្តកាល វាហាក់បីដូចជាភ្ញាក់ខ្លួនថាសម្ដេច ទុកលោក ជាមនុស្សល្ងិល្ងើម្នាក់, ព្រោះនៅក្នុងជំនួប រវាងលោក និង ព្រះអង្គ នៅទីក្រុងបារីស[45] ទ្រង់បានអនុសាសដល់លោក ឲដោះស្រាយបញ្ហាយៀកកុងនៅក្នុងទឹកដីខ្មែរជាបន្ទាន់, ចុះហេតុអ្វីនៅពេលនេះ ព្រះអង្គមានប្រតិកម្មអវិជ្ជមាន ចំពោះប្រជាបាតុកម្មដោយឯកឯង ប្រឆាំងនឹងយៀកកុង រហូតចោទប្រកាន់ថា រដ្ឋាភិបាល ជាអ្នកនៅពីក្រោយ ដើម្បីប្រឆាំងនឹងព្រះអង្គ។ ការ

43 ស្រប់ក្នុងម្លប់, ឈរជ្រកម្លប់។
44 អង្គុយហួប, បែបមង្គុយបត់ជើងគាល់ក្សត្រិយ៍។
45 ជំនួបនៅខែកុម្ភៈ ឆ្នាំ ១៩៧០។

បដិសេធ នៃព្រះគំនាល់ របស់សម្តេច ជាមួយនិងប្រតិភូ រៀបចំឡើងដោយព្រះមហាក្សត្រិយានី និង រដ្ឋាភិបាល ជាចំណុចបំបែក រវាង រដ្ឋាភិបាល និង ព្រះអង្គ, មិនតែប៉ុណ្ណោះព្រះអង្គ មានប្រតិកម្មឆេវឆាវចំពោះរដ្ឋាភិបាលថែមទៀត រហូតចោទប្រកាន់រដ្ឋាភិបាលថា ជាបនក្បត់ជាតិ។ លើចំណុចនេះឯង ដែលលោក លន់ នល់ មិនអាចទទួលយកបាន ហើយទុកជា ទង្វើ នៃសង្គ្រាម ប្រកាសឡើងដោយសីហនុ ប្រឆាំងនឹងប្រជាជាតិខ្មែរ ដែលតម្រូវឲរដ្ឋាភិបាល ការ[46]មិនឲកើតឡើង ព្រោះវាជាការិយកម្មរបស់រដ្ឋាភិបាល ដែលបានទទួល សេចក្តីទុកចិត្តពីរដ្ឋសភា និង ទទួលការខុសត្រូវ នៅចំពោះមុខស្ថាប័ននេះ។ យោបល់ របស់លោក អ៊ិន តាំ ថា សភាជាតិ អាចដកតំណែងប្រមុខរដ្ឋ ពីសម្តេចបាន, គំនិតនេះ ចំពោះលោក លន់ នល់ វាត្រឹមត្រូវ អាចនឹងយកមកអនុវត្តបាន ព្រោះសភាជាតិ ជាអង្គការ តែងតាំង មុខដំណែងនេះ ដូច្នេះអង្គការនេះ ក៏មានអំណាចនឹងដកហូតវាបានដែរ។ សួរថាតើលោក លន់ នល់ អាចទុកចិត្តសភាជាតិបានដែរឬទេ ?

ដូចបានជំរាប់ខាងលើរួចមកហើយថា រដ្ឋសភានៅពេលនោះ មានសម្បូរនយោបាយជា អ្នកស្តាំនិយម ហើយគាំទ្រ

46 ការ, រារាំង, ឃាត់ខាំង។

នយោបាយ នៃការកែទម្រង់សេដ្ឋកិច្ច របស់រដ្ឋាភិបាល។ គួរលើកយកមកពិនិត្យ អំពីគំនិតនយោបាយ ខាងឆ្វេង និង ខាងស្តាំ នៅក្នុងជីវិតនយោបាយខ្មែរ ដើម្បីស្រួលយល់អំពីវិបត្តិនយោបាយនៅស្រុកខ្មែរ។

**ពួកឆ្វេងនិយម**

នៅទសវត្ស ៥០ នៅស្រុកបារាំង នៅក្នុងមជ្ឈដ្ឋាននិស្សិតខ្មែរ មានក្រុមមួយ នាំគ្នាបង្កើត ក្រុមសិក្សានយោបាយ ដែលមានឈ្មោះថា មណ្ឌល អ្នកម៉ាក្សនិយមខ្មែរ (cercle Marxiste khmer) ដែលប្រើអក្សរកាត់ ជាភាសាបារាំងថា C.M.K។ សភាជិកសំខាន់ៗ មានលោក កេង វ៉ាន់សាក់, អៀង សារី, ហ៊ូ យន់, ជួន មុំ, រ៉ត់ សាមឿន, សាឡុត ស (ប៉ុល ពត)។ ក្រោយមក ពួកនេះ នាំគ្នាបង្កើត សមាគមនិស្សិតខ្មែរ (A.E.K) ហៅថា « ខេមរៈនិស្សិត »។ បើតាមលោក កេង វ៉ាន់សាក់ សមាគមនេះ តាំងពីដើមទីមកបានកំណត់គោលដៅរបស់ខ្លួនច្បាស់លាស់ គឺ ប្រឆាំងនឹងរបបរាជានិយមនៅស្រុកខ្មែរ ដើម្បីកសាង របបលទ្ធិប្រជាធិបតេយ្យ។ នៅក្នុង ប្រឹត្តិប័ត្រលេខ១៤ ចុះផ្សាយនៅថ្ងៃទី ៦ សីហា ឆ្នាំ ១៩៥២ នូវលិខិតចំហរមួយសរសេរជាភាសាខ្មែរ ចំពោះព្រះករុណាសីហនុផ្ទាល់ ដោយចោទប្រកាន់របបរាជានិយម ថាជា ប្រភព នៃសេចក្តីទុក្ខលំបាកវេទនា របស់ប្រជាពលរដ្ឋ, ចំណុចចោទប្រកាន់ទី២ គឺ ទុកព្រះករុណាសីហនុជាអ្នកបំផ្លាញសេរីភាព របស់ប្រជានិករខ្មែរ។

តែនៅចំពោះមុខ ការវាយប្រហារនយោបាយ របស់ពួកឆ្វេងនិយមមកលើព្រះអង្គ, សម្តេចសីហនុ ទ្រង់រើសយកផ្លូវនយោបាយកណ្តាល មានសភាពណាំណួន ដើម្បីឆ្លើយតបនឹង ការញុះញង់នេះ ដែលមាន នៅក្នុងគោលការណ៍នយោបាយ របស់ចលនាសង្គមរាស្ត្រនិយម។ តែបន្ទាប់ពីមានកើតឧទ្ទាមកម្មនៅភូមិសំឡូត ដែលជាស្នាដៃ របស់ពួកកុម្មុយនិស្តខ្មែរ ក្រោមការណែនាំ របស់កម្មាភិបាលយួនកុម្មុនិស្ត ដើម្បី ប្រឆាំងនឹង រាជរដ្ឋាភិបាលទី១ (១៩៦៦) ដឹកនាំដោយលោក លន់ នល់ និង ចាប់ពីឆ្នាំ ១៩៦៧ ការផ្តួតផ្តើម នៃនយោបាយទូតខ្មែរ រកសេវនៈ[47] ឡើងវិញ ជាមួយ សហរដ្ឋអាមេរិក វានាំឲមាន ការផ្តាច់ទំនាក់ទំនង ជាមួយពួកឆ្វេងនិយម ដែលសម្តេចសីហនុព្រះអង្គ តែងតែយកវា មកធ្វើជា កូនប្រយោលនឹងពួកស្តាំនិយម។ ព្រះរាជនយោបាយថ្មីនេះ នាំឲពួកឆ្វេងនិយមប្តូរយុទ្ធសាស្ត្រ ពីសហការជាមួយព្រះអង្គ ទៅជា ការប្រឆាំងហិង្សា។ ផលវិបាកភ្លាមៗ គឺមាន ឥស្សរជនល្បីៗ និង បញ្ញវន្តឆ្វេងនិយមមួយចំនួន នាំគ្នារត់ចូលព្រៃ ទៅផ្តុំនៅក្នុងបក្សសម្ងាត់កុម្មុយនិស្តខ្មែរ[48]។ តែទោះបីយ៉ាង

---

47 សេវនៈ ឬ សេវនា, ការរាប់រកជាគ្នា។

48 ចាប់ពីឆ្នាំ ១៩៦៧ ពួកកុម្មុយនិស្តចាប់ផ្តើមធ្វើសកម្មភាពប្រឆាំងនឹងរដ្ឋាភិបាល លន់ នល់, នៅខេត្តកំពង់ចាម នៅភូមិដំបែ គណបក្សប្រជាជន ប្រជុំមួយជាសម្ងាត់ច្រើនដង ដើម្បីកំណត់យុទ្ធសាស្ត្រតស៊ូ។ នៅស្រុកព្រៃឈរ, មណ្ឌល របស់តំណាងរាស្ត្រ ហ៊ុយ នឹម មានបោះខិត្តប័ណ្ណប្រឆាំងនឹងរដ្ឋាភិបាល។ នៅខេត្ត កំពង់ធំ ស្រុកបារាយ មានបាតុកម្ម នៃប្រជា

*(note de bas de page - suite)*

៣ ព្រះអង្គមិនបោះបង់ទំនាក់ទំនងពិសេសជាមួយយួន និង ចិនកុម្មុយនិស្តនោះដែរ តែការរក្សានេះ វាមិនបាន បន្ថយកំហឹងពួកឆ្វេងនិយម ព្រោះពួកនេះទុក ការរក ទំនាក់ទំនងជាថ្មី ជាមួយសហរដ្ឋអាមេរិក ជាគ្រោះថ្នាក់ ផ្ទាល់ដល់ពួកខ្លួន។

## ពួកស្តាំនិយម

នៅពេលជាមួយគ្នានោះដែរ មានពួកនិស្សិតមួយក្រុម ទៀត នាំគ្នាបង្កើតក្រុមនយោបាយមួយដែរ ដែលមាន និន្នាការ យោល រវាង សេរីនិយម និង សង្គមប្រជាធិបតេយ្យ។ សមាជិកសំខាន់ៗមាន លោក អៀ ស៊ីចូវ, ឌុក រ៉ាស៊ី, ម៉ាន់ មូឡីវ៉ាន់, ហង្ស ធុនហាក់។ ក្រុមនេះ មិនទុកខ្លួនជា អ្នកប្រឆាំងនឹងរាជានិយម និង កម្មុយនិស្តទេ។ តែពួក គេ បង្ហាញគោលជំហរខ្លួនថា លទ្ធិកុម្មុយនិស្ត ជាលទ្ធិមួយ មិនឆបគ្នានឹងសង្គមខ្មែរ ហើយ របបរាជានិយមខ្មែរ ត្រូវ ចាំបាច់ ជា របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

នៅឆ្នាំ ១៩៥៤ ក្រុមទាំងពីរនេះ បានជួបប្រជុំគ្នានៅស្រុក ខ្មែរ នៅផ្ទះលោក ហង្ស ធុនហាក់ ដើម្បីស្វែងរកយុទ្ធសាស្ត្រ តស៊ូរួមមួយទៅរក ការកាន់កាប់អំណាច។ បើតាម ព្រឹត្តិប័ត្រប្រចាំខែឈ្មោះ ស្រុកខ្មែរ សរសេរផ្សាយថា នៅពេលប្រជុំ នោះ លោក រ៉ត់ សាមឿន ដែលជាអ្នកតំណាងពួកឆ្វេង

កសិករ ស្រែកជេរប្រមាទលោក លន់ នល់ ថាជាមនុស្ស របស់អាមេរិកាំង ដែលកំពុងលក់ស្រុកខ្មែរ អោយអាមេរិកាំង ហើយនៅ ក្នុងខត្តបណ្ណនោះ មានការអំពាវនាវសូមអោយប្រជាពលរដ្ឋ ចូលរួមធ្វើបដិវត្ត។

និយម មានយោបល់ថា : *ក្រុមរបស់ខ្លួន មិនអាចធ្វើសហការជាមួយនឹងស្ដេច សីហនុ បាននោះឡើយ ព្រោះព្រះអង្គមិនដូរគំនិត ប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ ដាច់ខាត ហើយ នៅជុំវិញព្រះអង្គ គឺមានតែជនអសមត្ថភាព និង ពុករលួយ ដូច្នេះ មានតែផ្លូវមួយគត់ដើម្បីចាប់យកអំណាច គឺការតស៊ូដោយអាវុធ។* គួរកាត់សំគាល់ថា នៅថ្ងៃទី១២ មេសា ឆ្នាំ ១៩៥៤ ពួកយួនយៀកមិញ ដែលជាសម្ពន្ធមិត្តនឹងពួកលោក រ៉ត់ សាមឿន ដែលហៅថា ពួកខ្មែរយៀកមិញ បានវាយប្រហារ រថភ្លើងដឹកអ្នកដំណើរពីភ្នំពេញទៅបាត់ដំបង នាំឲមានមនុស្សស្លាប់នឹងរបួសជាច្រើន។ ការវាយប្រហារនេះឯង ប្រហែលជាសាហេតុ នាំឲមានជំនួបរវាង ក្រុមឆ្វេងនិយម និង ស្តាំនិយម។

លោក ហង្ស ធុនហាក់ ដែលជាតំណាងពួកស្តាំនិយម មានប្រតិកម្មតបវិញថា ព្រះមហាក្សត្រ មានប្រជាប្រិយភាព, ប្រជាកសិករ មានសេចក្តីស្រឡាញ់ព្រះអង្គណាស់ : *តែខ្ញុំយល់ស្របនឹងការវិភាគ របស់បង (រ៉ត់ សាមឿន) តែពេលនេះ យើងមិនអាចប្រឆាំងនឹងព្រះអង្គបាននោះឡើយ ទោះបីយើង ប្រឹងប្រែងពន្យល់ដល់ប្រជាកសិករយ៉ាងណាក៏ដោយ ក៏ពួកគាត់មិនកំរើកប្រឆាំងនឹងសីហនុដែរ មិនតែប៉ុណ្ណោះព្រះអង្គដឹកនាំ ដោយអាងពលសក្តិ[49]។ ដូច្នេះ ខ្ញុំយល់ឃើញថា នៅក្នុងកាលៈទេសៈបែបនេះ គួរបីលៃលក*

[49] ពលសក្តិ, អំណាចកម្លាំង។

*ប្រើ កលោបាយ ធ្វើការរួបរួមជាមួយព្រះអង្គសិន ដោយប្រើ សមត្ថភាព និង ការចេះដឹង របស់យើង ចូលធ្វើជាស្នូលមានប្រយោជន៍នៅក្នុងក្រឡាអំណាច របស់ព្រះអង្គ ដើម្បីប្រឆាំងនឹងពួកអ្នកអបអមពុករលួយនៅជុំវិញព្រះអង្គ។ ការបញ្ចូលពួកយើង ទៅនៅក្បែរព្រះអង្គ គឺធ្វើតាមសម្ព័ន្ធ នៃអាពាហ៏ពិពាហ៏ របស់ពួកយើង ជាមួយបុត្រីពួកនាម៉ឺនធំៗ ដែលជាអ្នករាជានិយម ដែលជាស្ពាន សំរាប់យើង ដើរឆ្លងទៅនៅក្បែរសម្តេចសីហនុ។ មាគ៌ានេះ វាមាន ចម្ងាយវែងឆ្ងាយណាស់, តែអ្វីដែលសំខាន់ចំពោះយើង គឺយើងត្រូវរក្សា ឧត្តមគតិយើង ឲរឹងប៉ឹងជានិច្ច កុំឲភ្លួតរង្វេងនឹងអំណាច ដែលវាជា រោគឆ្លង ចំពោះអ្នកដែលមាន សតិទន់ខ្សោយ។ ពេលនេះយើងមិនអាចធ្វើពហុកិច្ច បាននោះឡើយ, ដូច្នេះ ត្រូវយើងចេះកំណត់ ជាលំដាប់តាមឋានានុក្រម ទើបគោលដៅចុងក្រោយ របស់យើង នឹងអាចមានជ័យជំនះ, អ្វីដែលសំខាន់ចំពោះយើង គឺ លទ្ធផល នៃគោលដៅចុងក្រោយ, ដូច្នោះទេឬ ?*

ពួកអ្នកស្តាំនិយម នៅពេលនោះ មានប្រមុខ គឺលោក សឺង ង៉ុកថាញ់ ដែលជាអ្នកប្រឆាំងនឹងអាណានិគមបារាំងល្បីល្បាញម្នាក់ ហើយ លោក ក៏ជាគូប្រជែងរបស់ហ្លួងសីហនុផង។ លោក សឺង ង៉ុកថាញ់ លោកបានរត់ចូលព្រៃ នៅ

ខែមីនា ឆ្នាំ ១៩៥២[50] ដើម្បី បង្កើតកម្លាំងតស៊ូដោយអាវុធប្រឆាំងបារាំង នឹងហ្លួងសីហនុ ព្រោះនៅពេលនោះលោកក៏យល់ឃើញដូចលោក រ៉ាត់ សាមឿន ថា ត្រូវតែមានការតស៊ូដោយអាវុធ ទើបអាចបង្ខំ បារាំង អោយផ្តល់ឯករាជ្យសរុបដល់ស្រុកខ្មែរ និង ហ្លួងសីហនុ ឲទ្រង់គោរព លទ្ធិប្រជាធិបតេយ្យ ស្របតាមរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧។

ក្រោយពីស្រុកខ្មែរទទួលបានឯករាជ្យសព្វសារព័ន នៅឆ្នាំ ១៩៥៣ សម្តេច សីហនុ ទ្រង់មានទម្លាប់ ហៅពួកឆ្វេងនិយម ថាខ្មែរយៀកមិញ ក្រោយមកហៅថាខ្មែរក្រហមដោយបញ្ចូល ពួកអ្នកជឿនលឿននៅក្នុងពួកនោះ និងហៅ ពួកស្តាំនិយម ថាខ្មែរសេរី ដែលមានន័យ សំរាប់សម្តេចសីហនុ ថាពួកក្បត់ជាតិ។ រីឯ ខ្មែរឥស្សរៈទាំងពីរពួកដែលជា ចលនាតស៊ូដោយអាវុធប្រឆាំងនឹងបារាំង, មួយពួក មាននិន្នាកា ទៅរក យួនយៀកមិញ និង មួយពួកទៀត ជាខ្មែរឯករាជ្យ ដែលមានមេកន្លោងធំៗ បាននាំគ្នាសុខចិត្ត ចុះចូលនឹងរាជរដ្ឋាភិបាល ដូចយ៉ាង លោក

---

50 នៅពេលដែលបារាំងវិលត្រឡប់មកស្រុកខ្មែរវិញបន្ទាប់ពីសង្គ្រាមលោកលើកទី២ លោក សឺង ង៉ុកថាញ់ ត្រូវបានអាជ្ញាបារាំងចាប់លោក យកទៅឃុំនៅស្រុកបារាំងដោយចោទប្រកាន់លោកថាចូលដៃជាមួយជប៉ុន។ នៅថ្ងៃទី៣១ តុលា ឆ្នាំ ១៩៥១ លោក រួចពីទោស រួចធ្វើមាតុភូមិនិវត្ត តែគំនិតនយោបាយ របស់លោក វាផ្ទុយស្រឡះពីហ្លួងសីហនុ នាំអោយលោកក្លាយជាសត្រូវនយោបាយ ទទួលការគំរាមកំហែង ដែលវាអាចនាំឲមានគ្រោះថ្នាក់ដល់អាយុជីវិត របស់លោក ដូចលោក អៀវ កើស ត្រូវបានជនមិនស្គាល់មុខធ្វើឃាដនៅថ្ងៃទី ១៤ មករា ឆ្នាំ ១៩៥០, នៅពេលនៅលោកជាអគ្គលេខាធិការ របស់គណបក្សប្រជាធិបតេយ្យ។

ដាប ឈួន, ពុត ឆាយ, ទ្រង់ នរោត្តម ចន្ទរង្សី ជាអាថ៌។ សម្តេចសីហនុ ទ្រង់ទុកពួកនេះជាអ្នកស្តាប់ឱវាទផ្ទាល់របស់ទ្រង់ ដែលទ្រង់ យកមកប្រើ នៅក្នុងក្រឡានយោបាយ ដើម្បី វាយប្រហារសត្រូវរបស់ទ្រង់។

## ពួកអ្នកជាតិនិយម

ក្រៅពីពួកទាំងពីរនេះ មានពួកអ្នកជាតិនិយម ដែលជាកម្លាំងភាគច្រើននៅស្រុកខ្មែរ ចូលរួមគ្នា នៅក្នុងគណបក្សប្រជាធិបតេយ្យ[51] ចេញមុខ ប្រឆាំងនឹងអាណាព្យាបាលបារាំង ដោយមិនយល់ព្រម បញ្ចូលស្រុកខ្មែរឯករាជ្យ នៅក្នុងសហភាពបារាំង ព្រោះយល់ឃើញថា វាជារូបភាពថ្មី នៃអាណានិគម ដែលបារាំង កំពុងបង្កើតឡើងនៅឥណ្ឌូចិន ដែលហ្លួងសីហនុ បានចុះហត្ថលេខាយល់ព្រមនៅថ្ងៃទី៨ វិច្ឆិកា ឆ្នាំ ១៩៤៩។ តែ សន្ធិសញ្ញានេះ រដ្ឋសភា នៅឆ្នាំ ១៩៥១ ដែលមាន គណបក្សប្រជាធិបតេយ្យជាក្រុមភាគច្រើន មិនព្រមឲសច្ចាប័ន ដែលគេអាចទុកបានថាជាសន្ធិសញ្ញាអធម្មនុញ្ញ។ ទំនាស់នេះ វានាំបង្កើតនូវទំនាក់ទំនងតឹងរឹងដ៏ឡូង រវាង ហ្លួនសីហនុ និង គណបក្សប្រជាធិបតេយ្យ និង ទំនាស់ដោយប្រយោលផង រវាង អ្នកជាតិនិយម និង ព្រះអង្គ ដែលវានាំទៅរកការរំលាយ

51 គណបក្សប្រជាធិបតេយ្យ បង្កើតឡើងនៅថ្ងៃទី ២១ មេសា ឆ្នាំ ១៩៤៦ ដែលមានជាអាទិ សមាជិកស្ថាបនិក លោក អៀវ កើស, អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស លោក ស៊ិម វ៉ា។

*(note de bas de page - suite)*

រដ្ឋសភា[52] នៅថ្ងៃទី១៣ មករា ឆ្នាំ ១៩៥៣ ហើយបន្ទាប់មក ហ្លួងសីហនុ ទ្រង់ប្រកាស ប្រទេសមានភយន្តរាយ ដើម្បីប្រមូលអំណាចនីតិប្រតិប្តិ និង នីតិបញ្ញាតិ មកនៅក្រោមរាជសក្តិ ដែលវាផ្ទុយទាំងស្រុកនឹងរដ្ឋធម្មនុញ្ញ។ ដូច្នោះ ព្រះអង្គ បានដាក់រាជ្យ នៅថ្ងៃទី២ មីនា ឆ្នាំ ១៩៥៥ ហើយនៅថ្ងៃ៦ មេសា ទ្រង់បានបង្កើត ចលនា សង្គមរាស្ត្រនិយម មានគោលបំណងនឹងប្រមូលខ្មែរ និង គណបក្សនយោបាយ ដែលមានចិត្តស្រឡាញ់ជាតិ និង ការពារប្រយោជន៍ប្រជាជាតិជាចាំបាច់។ តែការពិត ការបង្កើតនេះ គឺមានគោលដៅតែមួយគត់ គឺ ការប្រឆាំងនឹងគណបក្សប្រជាធិបតេយ្យ ដែលជាអ្នកឈ្នះ ក្នុងការបោះឆ្នោតតាំងពីឆ្នាំ ១៩៤៦ មកម្លេះ។ យុទ្ធសាស្ត្រ ដាក់រាជ្យ ដើម្បីមានសិទ្ធិពេញលេញធ្វើនយោបាយ របស់ព្រះអង្គ វានាំមកនូវលទ្ធផល ល្អប្រសើរ ដល់ព្រះអង្គ ព្រោះមានគណបក្សនយោបាយជាច្រើន និង ឥស្សរជនល្បីៗ នាំគ្នាចុះចូលចលនា សង្គមរាស្ត្រនិយម តែ ក៏មានអ្នកជាតិនិយមភាគច្រើន នាំគ្នានៅសម្ងំស្ងៀម ព្រោះបើបន្តធ្វើសកម្មភាពប្រឆាំងនឹងសម្តេចសីហនុ នៅក្បួនព្រះអង្គ គឺ « អញរស់ឯកស្លាប់ », បើមិនទេសោត គឺ ប្រកត់ជាស្លាប់ជាពុំខាន។ តែ ការសម្ងំស្ងៀមនេះ មិនស្ថិតនៅក្នុងភាពអកម្មនោះ

52 គណបក្សប្រជាធិបតេយ្យទុកការរំលាយរដ្ឋសភានេះជារដ្ឋប្រហារធម្មនុញ្ញ របស់ហ្លួងសីហនុ។

ឡើយ, សោតណាក៏ដោយ មាន អ្នកខ្លះ ចូលទៅសម្ងំ នៅក្នុងចលនាសង្គមរាស្ត្រនិយម ជាអ្នកជំនាញ ឬ អ្នកបំរើសាមញ្ញម្នាក់ តែក៏មិនទុកខ្លួនជាអាមាត្យនោះដែរ, អ្នកខ្លះទៀត យកអាជីពរៀងៗខ្លួន មកដណ្តប់ខ្លួន ក្នុងជីវិន[53], អ្នកខ្លះទៀត នាំគ្នាផ្តុំ ជា ក្រុមរិះគិតសម្ងាត់ ដើម្បីរៀបជើងល័ព្ធចំណោទ[54] ដែលត្រូវយកមកឆ្លើយនឹងបញ្ហានៅពេលមានឱកាសហុចឲ។ ចំពោះអ្នកទាំងនោះ គាត់យល់ឃើញថា សង្គមរាស្ត្រនិយម វាគ្មានធាតុជាតិនិយមអ្វីបន្តិចបន្តួចសោះឡើយ វាគ្រាន់តែជាឧបករណ៏ សំរាប់បំរើលោភចិត្ត របស់សីហនុ តែប៉ុណ្ណោះ ហើយ វាក៏ជា ជៀប[55] នៃអំណាចផ្តាច់ការផង។

ដូច្នោះនៅក្នុងរយះពេល សង្គមរាស្ត្រនិយម វាគ្រាន់តែជាវង់ក្រចកមួយ បន្ថយ នូវកម្លាំងចំណង់ប្រឆាំង គ្រប់និន្នាការនឹងអំណាចផ្តាច់ការ ដែលជាអំណាច ដែងគេឯង ដើម្បី យកឈ្នះទាល់តែបាន ទោះបី ត្រូវប្រើមធ្យោបាយអាក្រក់ និង ផ្ទុយពីប្រយោជន៏ជាតិបែបណាក៏ដោយ។ ក៏ប៉ុន្តែ សម្តេចសីហនុ ក៏ធ្វើជំនីចបន្តិចម្តងៗដោយមិនដឹងខ្លួន ដើម្បីកប់ សង្គមរាស្ត្រនិយម របស់ព្រះអង្គ ព្រោះ ជោតិព្រះអង្គ វាមានការអាប់អួរ នៅក្នុងទង្វើ

53 ជីវិន, ដំណើររស់នៅ។
54 ជើងល័ព្ធចំណោទ, លេខចំណោទដែលគិតរកចំនួនឃើញជាស្រេចហើយគ្រាន់ទុកមួយអន្លើ។
55 ជៀប, ទើបតែនឹងចេញជាក្តិបតូចៗ។
*(note de bas de page - suite)*

អសីលធម៌ ដែលព្រះអង្គធ្វើយ៉ាងណា កុំឲ្យអ្នកស្នេហាជាតិបានជំនា[56]ចំពោះជាតិ ព្រោះវាជា ការជំទាស់នឹងទ្រង់ព្រោះតែ ចរិកអត្មានិយមក្រៃពេករបស់ទ្រង់ ដែលគេអាចចាត់ទុកជាមនុស្សបំព្រៃជាតិ[57]។

## ផែនការកលយុទ្ធ

### របស់ទ្រង់ សរិមតៈ

បន្ទាប់ពី ប្រទល់ជាមួយសម្ដេច សីហនុ នៅពេលសមាជជាតិ នៅខែ ធ្នូ ឆ្នាំ ១៩៦៩ វាហាក់បីដូចជាទ្រង់ សិរិមតៈ លែងរួញរានឹងបន្ត ធ្វើកំណែទំរង់ផ្ទុយនឹង នយោបាយរបស់សីហនុ។ កម្លាំងប្រឆាំងនឹងសីហនុ ដែលកំពុង និទ្រានេះឯង ត្រូវបានទ្រង់ សិរិមតៈ ខ្ញាំយកបាន ដោយប្រើផែនការកលយុទ្ធច្រើនយ៉ាង។ ជាបឋម ត្រូវចាំបាច់ រកកម្លាំងសម្ភារៈឲ្យបានសិន។ ចំពោះទ្រង់ លោក លន់ នល់ នេះឯងជាកម្លាំងសម្ភារៈ ព្រោះគាត់នាំមក នូវកងទ័ពខ្មែរ តែទ្រង់មានជំនឿក្នុងចិត្តដែរថា បើលោក លន់ នល់ នៅរញ៉ូគំនិត ទ្រង់នឹងអាចផាត់ ទ្រព្យសកម្ម (atout) នេះបាន ព្រោះ ទ្រង់ក៏មានប្រភាពច្រើនណាស់ដែរនៅក្នុង

56 ជំនា, ដំណើរដែលប្រព្រឹត្តអំពើល្អទៅបាន។
57 បំព្រៃជាតិ, គឺញ៉ាំងជាតិរបស់ខ្លួនឲ្យប្រហែលដូចជាព្រៃ។ ព្រះសម្ពុទ្ធទ្រង់ប្រទានឱវាទថា : កុំធ្វើខ្លួនឲ្យជាមនុស្សបំព្រៃលោក។

មជ្ឈដ្ឋាន នាយទាហ៊ានជាន់ខ្ពស់ ដ្បិត ទ្រង់ ក៏ជាអតីត នាយទាហ៊ានម្នាក់ ហើយ ធ្លាប់កាន់ដំណែងជា រដ្ឋមន្ត្រី ក្រសួងការពារជាតិច្រើនដង។ ត្រូវដឹងថាសម្តេចសីហនុ ទ្រង់ បដិសេធ ជំនួយយោធាអាមេរិកាំង នៅឆ្នាំ ១៩៦៣ ដែលជាការសម្រេចចិត្តមួយ នាំឲកងទ័ពជាតិមានការ បារម្ភ ទោះបីព្រះអង្គ ធានាថា ចិនប្រជាមានិត គេនឹង ជួយខ្មែរគ្រប់មធ្យោបាយ ដើម្បី រៀបចំកងទ័ពឲទាន់សម័ យ។ តែវិធានការនេះ វានាំរសាយចំណង នូវការទុកចិត្ត គ្មានលក្ខខណ្ឌ រវាង សីហនុ និង កងខេមរៈភូមិន្ទ័ព។ កង ទ័ពនេះ ចាប់ពីឆ្នាំ ១៩៦៧ លែងជាកម្លាំង នៃសីហនុ និយមដាច់ខាតនោះឡើយ ទោះជានៅឆ្នាំ ១៩៦៨ សម្តេច សីហនុ តែងតាំងលោក ឧត្តមសេនីយ ញ៉ឹក ជូឡុង ដែល ជាអ្នកសីហនុនិយមគ្មានលក្ខខណ្ឌ ជំនួសលោក លន់ នល់ ជា អគ្គសេនាធិការ នៃកងទ័ពជាតិ ក៏ដោយ។ តែជាការ តែងតាំងអលោភោ ព្រោះ នៅឆ្នាំ ១៩៦៩ អាយុលោក ញ៉ឹ ក ជូឡុង ត្រូវចូលនិវត្តន៍ ជាចាំបាច់ តែសម្តេចសីហនុ មិន បន្ត ជាវិធានការពិសេស ដែលវាខុសពីទម្លាប់របស់ ព្រះអង្គ។ ដូច្នោះ វាទុកជាដោគជាធម្មជាតិដល់ទ្រង់ សិរិម តៈ ដែលអាចកាត់ផ្តាច់ ចំណង សីហនុ ជាមួយកងទ័ព បន្តបន្ទាប់ពីទ្រង់ ចាត់វិធានការបីយ៉ាង ដែលបាន រៀបរាប់ខាងលើរួចមកហើយ ដើម្បី បង្អត់មធ្យោបាយ ដល់សីហនុ មិនអាច ធ្វើសកម្មភាពបាន ប្រឆាំងនឹងរដ្ឋា

ភិបាល។ ចំណុចពីរទៀត ដែលទ្រង់ សិរិមតៈ ទុកជាកំហុសធ្ងន់ របស់សីហនុ គឺ ការទទួលស្គាល់[58] រដ្ឋាភិបាលបណ្ដោះអាសន្ន នៃយៀកកុង ( រដ្ឋាភិបាលបណ្ដោះអាសន្ន នៃសាធារណរដ្ឋយៀកណាម) ជារដ្ឋាភិបាលពេញច្បាប់ នៃយៀកណាមខាងត្បូង និង នៅខែឧសភា ឆ្នាំ ១៩៦៩ សម្ដេចសីហនុ បានព្យួរសកម្មភាព គណកម្មការអន្តរជាតិ ត្រួតពិនិត្យ កិច្ចព្រមព្រៀង នៃទីក្រុងហ្សឺណែវ ដែលជាមធ្យោបាយអន្តរជាតិសំខាន់ សំរាប់ ការពារ បូរណភាពទឹកដីខ្មែរ ចំពោះមុខយួនកុម្មុនិស្ត ដែលកំពុងបន្តធ្វើសង្គ្រាមនៅយៀកណាមខាងត្បូង ដែរវានឹងអាចហូរចូលមកក្នុងទឹកដីខ្មែរ។ ទ្រង់ សិរិមតៈ ឆ្លៀតយកកំហុសនេះមកធ្វើជាទោស របស់សីហនុ នៅចំពោះប្រជាជាតិ ដែលជាចំណុចមួយរសើបក្រៃនៅក្នុងអារម្មណ៍ប្រជាពលរដ្ឋខ្មែរ ដែលមតិអន្តរជាតិខ្លះទុកជា ការប្រកាន់ពូជសាសន៍ នៅពេលណាដែលខ្មែរលើកគ្រោះថ្នាក់យួនមកបរិយាយ។

តាមពិត ខ្មែរ មិនមែនជា ជនជាតិប្រកាន់ពូជសាសន៍នោះឡើយ តែជាអ្នករងគ្រោះនឹងទ្រឹស្ដី នៃការប្រកាន់ពូជសាសន៍ ព្រោះជាទ្រឹស្ដី បង្អត់ខ្មែរ ឲមានលទ្ធភាព ការពារពេញសិទ្ធិខ្លួន ជាជនរងគ្រោះ នៅចំពោះមុខ ការឈ្លានពានជាប្រព័ន្ធ នៃជាតិសាសន៍យួន មកលើជាតិសាសន៍ខ្មែរ តាំងពីសតវត្សទី១៧មកម្លេះ។

---

58 នៅថ្ងៃទី១៥ កក្កដា ឆ្នាំ ១៩៦៩។

មនស្ការ[59] របស់ទ្រង់ សិរិមត: គឺធ្វើឡើងដោយគ្មានទោស: ក្នុងអារម្មណ៍ទៅលើបុគ្គលសីហនុនោះឡើយ។ អ្វីដែលធ្វើឡើងគឺ ក្នុងគោលបំណងគោល គឺសង្គ្រោះជាតិ ស្របតាមគោលការណ៍ នៃរដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលសម្តេចសីហនុខ្លួនឯង ជាអ្នកបង្កើត។ ផែនការ កលយុទ្ធរបស់ទ្រង់ គឺបណ្តុះបណ្តាល នូវជម្រើសជំនួសនយោបាយរបស់សម្តេចសីហនុ ដែលកំពុងនាំស្រុកខ្មែរទៅរកគ្រោះថ្នាក់។ ទ្រង់ មានមនសិការថា ត្រូវហ៊ានបូជាគ្រប់បែបយ៉ាងរហូតដល់ជីវិត ព្រោះសម្តេចសីហនុ ជាមនុស្សឃោឃៅបំផុត នៅចំពោះមុខសត្រូវរបស់ព្រះអង្គ។

**របស់សម្តេច សីហនុ**

នៅចំពោះមុខមនស្ការ របស់ទ្រង់ សិរិមត: ហ៊ានតដៃនឹងព្រះអង្គ គឺថា « គំនក់ តនឹង គំនក់ » បានធ្វើឲសម្តេចសីហនុ មានការភ័យខ្លាច ហើយព្រះអង្គសំរេច យាងចេញពីប្រទេស នៅពេលអាធ្រាត ដោយប្រញាប់ ជាទីបំផុត[60] ថែមទាំង មិនថ្វាយដំណឹងជាមុន ដល់រដ្ឋាភិបាលនោះផង។ សម្តេចសីហនុ ចាប់ពីឆ្នាំ ១៩៦៦ ព្រះអង្គមានអារម្មណ៍ថាព្រះអង្គ កំពុងជួបប្រទះ កម្លាំងប្រឆាំង កើតចេញពីពួកអ្នកជាតិនិយម ដែលមានរដ្ឋសភា កើតចេញពីការ

59 មនស្ការ, ការសម្រេចចិត្តប្រកបដោយការប្តេជ្ញាចិត្ត។
60 នៅពេលរាត្រីនៅថ្ងៃទី៦ មករា ឆ្នាំ ១៩៧០។ ប្រតិកម្មបែបនេះ អ្នកខ្លះមានមតិថាជា អាការជម្ងឺ របស់សីហនុ ខ្លាចមានរដ្ឋប្រហារ ដូចនៅយៀកណាមខាងត្បូងធ្វើឡើងដោយកងទ័ពនៅថ្ងៃទី១ វិច្ឆកា ឆ្នាំ ១៩៦៣ ទំលាក់លោក ង៉ូ ឌិនដៀម រួចត្រូវទាហ៊ានសម្លាប់ចោលជាបន្ទាន់។

បោះឆ្នោតសេរីមួយ ដាក្បាលម៉ាស៊ិន។ បន្ទាប់ពី រដ្ឋសភានេះ បោះឆ្នោតប្រគល់សេចក្តីទុកចិត្តអោយរដ្ឋាភិបាលដឹកនាំដោយលោក លន់ នល់ ព្រះអង្គបង្កើតភ្លាម នូវបរិរដ្ឋាភិបាល[61]មួយ ដែលមានសមាជិក សុទ្ធតែជាអ្នកឆ្វេងនិយម ដើម្បីតាម ត្រួតពិនិត្យសកម្មភាពរដ្ឋាភិបាល។ ទង្វើនេះ គឺជាល្បែងនយោបាយរបស់សីហនុ ដែលព្រះអង្គតែងតែយកមលេង ធ្វើជា កូនប្រយោលសមាន រវាង ពួកអ្នកស្តាំនិយម និង ពួកអ្នកឆ្វេងនិយម។ ក្រោយពីលោកលន់ នល់ លាលែងពីតំណែង ព្រោះលោក មានគ្រោះថ្នាក់រថយន្ត ត្រូវចាំបាច់ ទៅព្យាបាលរបួសអស់រយៈដ៏យូរ, សម្តេចសីហនុ ព្រះអង្គបង្កើតរដ្ឋាភិបាលថ្មី ឈ្មោះថា រដ្ឋាភិបាលពិសេស[62] ដឹកនាំដោយព្រះអង្គផ្ទាល់។ រដ្ឋាភិបាលនេះឯង ដែលចាត់វិធានការដាច់ខាត ធ្វើការបង្រាបបង្ក្រាបឈាម នៃការបេះបោរប្រជាកសិករ នៅភូមិសំឡូត ដែលនាំអោយព្រះអង្គ បាត់នូវការទាក់ទងផ្ទាល់ ជាប្រយោជន៍នយោបាយ ជាមួយពួកអ្នកឆ្វេងនិយម។ តែព្រះអង្គ នៅរក្សានយោបាយទូត ដើម្បី រកសមតា រវាង លោកសេរី និងលោកកុម្មុយនិស្ត ហើយនិង ពង្រឹង សមិការ « សីហនុ = អព្យាក្រឹតភាព = សន្តិភាព » ដើម្បី បង្កួចកិត្យានុភាពនយោបាយ បែរទៅរក សេរីនិយម របស់រដ្ឋាភិបាលស្រោច

61 បរិរដ្ឋាភិបាល, contre gouvernement។
62 បង្កើតឡើងនៅថ្ងៃទី៣ មីនា ឆ្នាំ ១៩៦៧។
*(note de bas de page - suite)*

ស្រង់ជាតិ។ លើចំណុចទាំងឡាយនេះ ព្រះអង្គ មានជំនឿ ដាច់ខាត និង អាងថា អនុត្តរភាព[63] របស់ព្រះអង្គ ជាបិតាជាតិ នឹងអាចបង្វិល ស្ថានភាពនយោបាយ មកជាគុណប្រយោជន៍ដល់ព្រះអង្គ។ តែ ស្តេចសីហនុ ជាមនុស្សអនុបទេស[64] មានចរិកអវិជ្ជាមាន ដែលញ៉ាំងអោយព្រះអង្គ ធ្វើអនត្ថកម្ម[65]ប្រឆាំងនឹងប្រយោជន៍ជាតិ។

ការប្រទល់មុខគ្នា រវាង សម្តេចសីហនុ និង ទ្រង់សិរិមតៈ ដែលលោក លន់ នល់ មានការបារម្ភខ្លាច ប្រជារាស្ត្រ បកស្រាយថា ជាជម្លោះសន្តតិវង្ស មានស្នាមនៅក្នុងប្រវត្តិសាស្ត្រ ដែលជាដើមហេតុអនញ្ញ[66] នៃអត្ថង្គតជាតិ នាំអោយលោក ប្រយ័ត្នមិនអោយធ្លាក់ទៅក្នុងជម្លោះបែបនេះ។ តែលោក លន់ នល់ ក៏ដឹងជម្រៅចិត្ត របស់ទ្រង់សិរិមតៈ ដែរថា ក្នុងចំណោមព្រះរាជបុត្ររបស់សីហនុ ព្រះអង្គម្ចាស់នរោត្តម សីហមុនី ជាសំណប់ នៃទ្រង់ ទុកជាទាយាទ នៃរាជបល្ល័ង។ ដូច្នេះ ទ្រង់សិរិមតៈ មិនទុកអធិករណ៍ ជាមួយសីហនុ ជារាជ្យកិច្ចនោះឡើយ។ ការរួបរួមជាមួយទ្រង់សិរិមតៈ មានគោលដៅតែមួយគត់ចំពោះលោក លន់ នល់ គឺដាក់ប្រយោជន៍ជាតិ ពីលើប្រយោជន៍បុគ្គល។ នៅក្នុង

63 អនុត្តរភាព, ភាពនាំបុគ្គលដែលគ្មាននរណាមួយផ្ទឹមបាន។
64 អនុបទេស, ដែលឥតស្តាប់ការពន្យល់ នៃអ្នកដទៃ។
65 អនត្ថកម្ម, អំពើឥតប្រយោជន៍។
66 ដើមហេតុអនញ្ញ, ដើមហេតុតែមួយ។

ព្រឹត្តិការណ៍ ថ្ងៃទី១៨ មីនា លោក លន់ នល់ ពិតជាមនុស្ស កូនសោ តែមិនជាចលករ នៃអ្នកជាតិនិយម រុលប្រឆាំង នឹងនយោបាយរបស់សីហនុ។ អ្នកដែលនាំមុខ ដែលគ្មាន នរណាអាចប្រកែកបាន គឺទ្រង់សិរិមតៈ។ លន់ នល់ ជាមួយនឹង សិរិមតៈ វាគ្រាន់ជាសមិការ សំរាប់ធានា ចំពោះជីវកម្លាំង នៃប្រជាជាតិ ដើម្បីប្តូរចរន្ត នៃវាសនា ជាតិខ្មែរ។ លន់ នល់ ជាពលំ រីឯ សិរិមតៈ ជាបញ្ញា ដែលត្រូវ ការពលំ ដូចពលំ ត្រូវការបញ្ញា ដើម្បីឲស្រុកខ្មែរ ដើរឈាន ទៅរកសេចក្តីចំរើនរុងរឿង ព្រោះប្រជាពលរដ្ឋខ្មែរ ត្រូវការ សំទុះខ្យល់ថ្មី ដើម្បីឲមានជម្រើសជំនួសនយោបាយ របស់ សីហនុ។ នៅពេលនោះ តួនាទី របស់ទ្រង់សិរិមតៈ គឺជា អ្នកបណ្ដុះបណ្ដាល នៃជម្រើសជំនួសនោះ ឲមានកើត ឡើងជាកម្លាំជាតិ។

**សភាជាតិ**

នៅឆ្នាំ ១៩៧០ អ្នកសារព័ត៏មាន របស់កាសែត Le Monde បានសរសេរថា ការទំលាក់សម្តេចសីហនុពីមុខដំណែង ជា រដ្ឋប្រហារស្របច្បាប់ ព្រោះនៅចំពោះមុខអំណាចផ្តាច់ការ វាគ្មានការជ្រើសរើសអ្វីផ្សេងពីផ្លូវនេះឡើយ។ ចំណាប់អារ ម្មណ៏នេះ វាជាវិធីសាស្ត្រ របស់លោក លន់ នល់ ដែលមាន សភា គាំទ្រដោយកាត់យល់ ព្រោះសមាជិកភាគច្រើន ជា អ្នកជាតិនិយម ដែលសីហនុ ព្រះអង្គទុកជាអ្នកស្តាំនិយ ម។ ព្រះអង្គយកការចង្អុលនេះ មកលាបពណ៏ពួកអ្នក

ប្រឆាំងនឹង នយោបាយសង្គមនិយម របស់ព្រះអង្គនៅទសវត្ស៥០ ដូចយ៉ាងលោក ស៊ឹង ង៉ុកថាញ់ និង អតីតសមាជិកភាគច្រើន នៃគណបក្សប្រជាធិបតេយ្យ ដែលជាអ្នកជាតិនិយមសោះ តែបកប្រែថា ជាអ្នកស្តាំនិយម។ ផ្ទៀត នូវសេរីកម្ម ក្នុងក្របខណ្ឌសង្គម គឺការបោះឆ្នោតជ្រើសរើសសភាជាតិនៅឆ្នាំ ១៩៦៦ ពួកអ្នកជាតិនិយមដែលសម្ងំនិទ្រា ក្រោយពីជ័យជំនះ នៃចលនាសង្គមនេះនាំគ្នាឈរជាបេក្ខជនតំណាងរាស្ត្រ ហើយត្រូវបាន ប្រជាពលរដ្ឋបោះឆ្នោតអោយធ្វើជាតំណាង។ ដូច្នេះ សភាជាតិថ្មីនេះ មានបក្កភាព[67]នយោបាយខ្ពង់ខ្ពស់ ព្រោះពួកអ្នកតំណាងរាស្ត្រភាគច្រើន ជាអ្នកមានការពិសោធនយោបាយ។ ក្នុងចំណោមឥស្សរជន ដែលសម្តេចសីហនុ ស្នើឲជ្រើសរើសជានាយករដ្ឋមន្ត្រី[68] សភាជាតិបានជ្រើសយកលោក លន់ នល់ ដែលលោកមានកេរ៏ឈ្មោះជាអ្នកជាតិនិយម និងជាអ្នកសីហនុនិយមផង, ដែលជាលក្ខខណ្ឌពីរចាំបាច់ សំរាប់សំថៃចរិកសារ៉ារបស់សីហនុ។ មានតំណាងរាស្ត្រមួយចំនួន ចូលធ្វើជារដ្ឋមន្ត្រី នៅក្នុងរាជរដ្ឋាភិបាលដឹកនាំដោយលោក លន់ នល់ ដែលនាំបង្កើត នូវសេវនា[69] រវាង សភាជាតិ និង រដ្ឋាភិបាល ដើម្បីបំរើប្រយោជន៏ជា

67 បក្កភាព, ភាពចាស់ទុំ។
68 ពីខែតុលា ឆ្នាំ ១៩៦៦ ដល់ថ្ងៃទី៣០ មេសា ឆ្នាំ ១៩៦៧។
69 សេវនា, ការរាប់រកយកជាគ្នា។

តិ។ សភាជាតិនេះ ត្រូវបានសម្តេច សីហនុ បន្ទុយដោយមិនចំពោះ នូវតួនាទី ជាអ្នកតាមត្រួតពិនិត្យសកម្មភាពនៃអំណាចនីតិប្រតិបត្តិ ព្រោះព្រះអង្គបង្កើត បរិរដ្ឋាភិបាលមួយ មាននិន្នាការឆ្វេងនិយម ដើម្បី ពិនិត្យជាមុន នូវគ្រប់គំរោងនយោបាយ នៃរដ្ឋាភិបាល, ជូនកាលរហូតចេញមុខជំទាស់តែម្តង។ តែ សភាជាតិ ឆ្នាំ ១៩៦៦ មានទម្ងន់នយោបាយនៅចំពោះមុខ ល្បិចរបស់សីហនុ ដែលនាំឲព្រះអង្គមិនហ៊ានរំលាយ ទោះបីមានកើត ឧទ្ទាមកម្មនៅភូមិសំឡូត និង ការបាត់ខ្លួន តំណាងរាស្ត្រឆ្វេងនិយមពីររូប គឺលោក ខៀវ សំផន និង ហ៊ូ យន់។ បន្ទាប់ពី លោក លន់ នល់ លាលែងពីដំណែងនាយករដ្ឋមន្ត្រី សភាជាតិបន្តធ្វើសកម្មភាពខ្លួនតាមធម្មតាជាមួយ រដ្ឋាភិបាលដឹកនាំដោយសម្តេចសីហនុ បន្ទាប់មកជាមួយរដ្ឋាភិបាលមានឈ្មោះថា « លាភជ័យចុងក្រោយ » ដែលមានសម្តេចប៉ែន នុត ជានាយករដ្ឋមន្ត្រី[70] និងមានលោក លន់ នល់ជា ឧបនាយករដ្ឋមន្ត្រីទី៣, ហើយបន្ទាប់មក ជាឧបនាយករដ្ឋមន្ត្រីទី១។ ក្រោយពេលដែលសម្តេច ប៉ែន នុត លាលែងពីតំណែង សម្តេចសីហនុ កោះប្រជុំសមាជជាតិពិសេស ដើម្បីតែងតាំងនាយករដ្ឋមន្ត្រី ដឹកនាំរដ្ឋាភិបាលដែលព្រះអង្គថ្វាយ ឈ្មោះថា រដ្ឋាភិបាលស្រោចស្រង់ជាតិ។

[70] រដ្ឋាភិបាលនេះតែងតាំងពីថ្ងៃទី៣១ មករា ឆ្នាំ ១៩៦៨, សម្តេច ប៉ែន នុត លាលែងពីតំណែងនៅថ្ងៃទី១ សីហា ឆ្នាំ ១៩៦៩។

អស្ថិរភាព នៃអំណាចនីតិប្រតិបត្តិ ពីឆ្នាំ ១៩៦៦ មកដល់ឆ្នាំ ១៩៦៩ លាក់មុខ នូវវិបត្តិនយោបាយ នៃរបបសង្គមរាស្ត្រនិយម។ ប៉ុន្តែ សភាជាតិ វាហាក់ដូចជា ពង្រឹងតួនាទីរបស់ខ្លួន ជាស្ថាប័ន នៃប្រជាជាតិ ជៀងជា តំណាង នៃរបបសង្គមរាស្ត្រនិយម ព្រោះខ្លួនកើតចេញពីការបោះឆ្នោតសេរី។ ការវិលត្រឡប់របស់ លោក លន់ នល់ មកដឹកនាំរដ្ឋាភិបាល ដែលមានទ្រង់ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រីទី១ និង ការបោះឆ្នោតតែងតាំងលោក ចេង ហេង ដែលជាឥស្សរជន មិននៅក្នុងវង់ នៃពួកអ្នកជំនិតនឹងសម្តេចសីហនុ ជាប្រធានរដ្ឋសភា ក៏កាន់តែពង្រឹងតួនាទី របស់សភាជាតិ ក្នុងអំណាចនីតិបញ្ញាតិ និង មានផម្នានរូប នៅក្នុងមតិសាធារណៈ ជាពិសេសនៅក្នុងមជ្ឈដ្ឋានអ្នករាជការ។ ការបោះឆ្នោតយល់ព្រម[71] គំរោងច្បាប់បី របស់រដ្ឋាភិបាល ដើម្បីធ្វើសេរីកម្ម សេដ្ឋកិច្ច និងធានាគារ បង្ហាញថា សភាជាតិ លែងនៅក្នុងឥទ្ធិពលរបស់សម្តេចសីហនុ។ ទង្វើនេះ នាំឲ្យព្រះអង្គ ពិរោធ រហូតទ្រង់ ហាមមិនឲ្យពួកតំណាងរាស្ត្រ ចូលរួមប្រជុំក្នុងសមាជជាតិ។ រាជប្រតិកម្មជាក្មេងនេះ មានវិបាកផ្ទុយពីរាជហទ័យ គឺចង់បំភ័យរដ្ឋាភិបាលស្រោចស្រង់ជាតិថា ព្រះអង្គ មិនញញើតនឹងវាយប្រហារដោយចំពោះរដ្ឋាភិបាលនោះឡើយ ដូចយ៉ាងមុនបើកសម័យប្រជុំ នៃសមាជជាតិ

71 សភាជាតិបោះឆ្នោតយល់ព្រមនៅថ្ងៃទី១៥ វិច្ឆិការ ឆ្នាំ ១៩៦៩។

ព្រះអង្គបញ្ជាជាសម្ងាត់ ឲរដ្ឋមន្ត្រី ដែលជាអ្នកសីហនុ និយមងប់មុខ លាលែងពីមុខតំណាង ដោយសង្ឃឹមថា ច្បាស់ជាគណរដ្ឋមន្ត្រី នឹងសុំលាលែងពីតំណែង។ តែសេចក្តីសង្ឃឹមនេះ វាស្រកោក ព្រោះរដ្ឋាភិបាល ដឹកនាំដោយទ្រង់ សិរិមតៈ ជានាយករដ្ឋមន្ត្រីស្តីទី[72] តែងតាំងជំនួសភ្លាមៗ នូវតំណែងលាលែងនោះ។ ការសម្រេចចិត្ត ប្រកបដោយសេចក្តីក្លាហាននេះ ជាការលើកទឹកចិត្តដល់សភាជាតិ និងជាការបង្ហាញ នូវសាមគ្គីភាព របស់រដ្ឋាភិបាល ចំពោះពួកអ្នកតំណាងរាស្ត្រ ដែលបានបោះឆ្នោតយល់ព្រមផែនការរបស់រដ្ឋាភិបាល ទោះបីដឹងច្បាស់ថា ជាផែនការផ្ទុយនឹងគំនិត នៃសម្តេចសីហនុ។ បន្ទាប់ពីសមាជាតិលើកទី២៨ វាហាក់បីមានដំណើរ នៃយុគថ្មី នៃនយោបាយ ដែលនាំទៅរកការទំលាក់ សម្តេចសីហនុ ពីតំណែង។ សភាជាតិ ក្នុងការទំលាក់នេះ មានតួនាទីសំខាន់ណាស់ ព្រោះវាឲរូបភាពជាផ្លូវច្បាប់ជាប្រក្រតី បោះឆ្នោតដកហូត តំណែងប្រមុខរដ្ឋពីព្រះអង្គ ក្នុងនាមខ្លួនជាតំណាងប្រជាពលរដ្ឋ ដែលនឿយណាយនឹងនយោបាយរបស់សីហនុ ។

72 លោក លន់ នល់ អញ្ជើញទៅព្យាបាលរោគនៅប្រទេសបារាំង តាំងពីថ្ងៃទី ៣០ តុលា ឆ្នាំ ១៩៦៩។ ត្រូវដឹងថា លោក លន់ នល់ នៅពេលនោះមានចិត្តចង់លាលែងពីតំណែងដូចកាលពីឆ្នាំ ១៩៦៧ តែទ្រង់ សិរិមតៈ អន្ទង កុំឲសូមលាលែងព្រោះទ្រង់ធានាដល់គាត់ថា ទ្រង់នឹងដឹកនាំរដ្ឋាភិបាលបាន ហើយរដ្ឋាភិបាលនឹងមានការគាំទ្រមាំទាំពីសភាជាតិ ដែលជា ឱកាសល្អមួយសំរាប់ធ្វើការកែទំរង់សេដ្ឋកិច្ចជាតិ។

## រដ្ឋប្រហារស្របច្បាប់

បន្ទាប់ពីមានបាតុកម្ម នៃប្រជាកសិករ នៅខេត្តស្វាយរៀង សម្តេចសីហនុ ព្រះអង្គបានផ្ញើទូរលេខពីរច្បាប់ ជាភាសាបារាំង នៅថ្ងៃទី១២ មីនា និង ថ្ងៃទី១៣ មីនា ឆ្នាំ ១៩៧០ មកថ្វាយចំពោះមាតា របស់ព្រះអង្គ មានសេចក្តីថា :

(បកប្រែក្រៅផ្លូវការ)

« *ខ្ញុំមានទុក្ខព្រួយខ្លាំងណាស់ ដោយបានដំណឹងអំពីអំពើហិង្សា ដែលបានប្រព្រឹត្តឡើង ពីសំណាក់ជនរួមជាតិខ្លះ នៅលើស្ថានតំណាងទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យ នៃវៀតណាមខាងជើង និង រដ្ឋាភិបាលបណ្តោះអាសន្ន នៃវៀតណាមខាងត្បូង។ ខ្ញុំយល់ច្បាស់ណាស់ នូវមូលហេតុ ដែលនាំបង្កឲមានកំហឹងខ្លាំងនេះ, ប៉ុន្តែ ខ្ញុំស្គាល់ជនរួមជាតិ ដែលនាំមិនឲខ្ញុំជឿបានថា គាត់អាចនឹងប្រព្រឹត្តដល់ម្លឹង ដែលវាផ្ទុយ ពីប្រយោជន៍ខ្ពង់ខ្ពស់ និង កេរ្តិ៍ឈ្មោះល្អ នៃប្រទេសយើង។ ពិតណាស់ហើយថា ស្រុកខ្មែរ ដែលយើងស្រឡាញ់ ជាងជីវិតយើងទៅទៀត ដែលកំពុងមានគ្រោះថ្នាក់ ប៉ុន្តែ មិនមែនយកការវាយកំទេចស្ថានទូត ដែលនឹងអាចបញ្ចៀល នូវគ្រោះថ្នាក់នេះបាន។ ប៉ុន្តែ ត្រូវប្រព្រឹត្ត ដូចដែល ប្រជាជាតិ និង កងទ័ព ធ្លាប់*

តែចង្អុលបង្ហាញ។ ខ្ញុំជឿជាក់ថា ព្រឹត្តិការណ៍ផ្ទុនផ្ទួរនេះ គឺជាគោលបំណង និង រៀបចំឡើងដោយឥស្សរជន មានបំណងនឹងកំចាត់ចោល នូវមិត្តភាព រវាង កម្ពុជា និង ជុំរុំសង្គមនិយម និង បោះប្រទេសយើង ទៅក្នុងដៃ នៃមហាអំណាចចក្រពត្រ មូលធននិយម។ ឥស្សរជនទាំងនោះគាត់គិតតែពី ប្រយោជន៍ និង បក្សពួក របស់គាត់ ច្រើនជាង អនាគត នៃប្រទេស និង វាសនា នៃប្រជារាស្ត្រ។ ដោយគោរព និង ដោយសេចក្ដីស្រឡាញ់ »

« ខ្ញុំសូមអគុណយ៉ាងខ្លាំង ចំពោះព្រះករុណា ដែលមានព្រះរាជហឫទ័យក្នុងនាមព្រះរាជបល្ល័ង ចាត់វិធានការ ដើម្បីធ្វើការសម្របសម្រួល និង ធ្វើឲមានភាពប្រក្រតី នូវការទំនាក់ទំនង ជាមួយប្រទេសយៀកណាម ដែលជាការសង្គ្រោះ ដល់កិត្តិយស នៃមាតុភូមិ និង ប្រជាជាតិយើង ដែលមានជំហរអន្តរជាតិ មិនអាចប្រកែកបាន និង គ្មានជម្លោះទេ កាលពីមួយខែកន្លងទៅនេះ វាប្រែក្លាយទៅជា មានជម្លោះយ៉ាងខ្លាំង នៅក្នុង មតិសារព័ត៌មានអន្តរជាតិ ចាប់ពីមានកើតព្រឹត្តិការណ៍មក។ ខ្ញុំចង់បញ្ជាក់ ចំពោះជនរួមជាតិយើងថា ខ្ញុំមិនយល់ព្រម នូវការជ្រាតចូល នៃពួកយៀកកុង និង យៀកមិញ និង ការជ្រៀតជ្រែកខ្លះមកក្នុងកិច្ចការ នៃប្រទេសធិបតេយ្យយើង។ ពីម្សិលមិញខ្ញុំបានប្រាប់ចំពោះ ពួកអ្នកដឹកនាំសូវៀតជា

*មិត្ត។ តែបំណង របស់ពួកអ្នកផ្ទាំនិយមជ្រុល វាលើសអំពីបញ្ហាយួនទៅទៀត គឺ គេសំដៅនឹងដួរ នយោបាយជាន់ខ្ពស់ នៃកម្ពុជាតែម្តង*»

បើយកន័យ នៃទូរលេខទាំងពីរច្បាប់នេះមកវិភាគ គេមានចំណាប់អារម្មណ៍ថា តាំងពីដើមទីមក សម្តេចសីហនុព្រះអង្គ ទុកជាស្រេចថា ព្រឹត្តិការណ៍ ដែលកំពុងកើតមានឡើង នៅស្រុកខ្មែរ គឺសំដៅ ប្រឆាំងតែម្តងនឹងនយោបាយ របស់ព្រះអង្គ ព្រោះវាជាការបន្ត នូវការប្រទល់នៃវិធានការ របស់រដ្ឋាភិបាលស្រោចស្រង់ជាតិ ប្រឆាំងនឹងព្រះអង្គ។ ការយល់ឃើញដោយគ្មានការពិចារណាបែបនេះ គឺកើតចេញពីចារិកឆេវឆាវរបស់ព្រះអង្គ ដែលទុកដូចជាក្មេងលើកទំយើ, បើខឹងកាលណាគឺ យំឡាំប៉ាឥតអាចនរណាលួងបាន។ តែនរណាក៏ស្គាល់ច្បាស់ នូវរាជកំហឹងនេះដែរ វាបកប្រែរឿយៗជា ការជេរប្រមាទ គ្មានសំចៃមាត់ និង ជួនកាល រហូតដល់ទៅប្រើអាមាត្រឲប្រព្រឹត្ត នូវអំពើ សោកៅ និង ហិង្សា ចំពោះជនណាដែលធ្វើឲព្រះអង្គខឹង។

ដើម្បីទប់ស្កាត់ នូវសកម្មភាពនយោបាយ នៃពួកអ្នកប្រឆាំងនឹងគំនិតនយោបាយ របស់ព្រះអង្គ ទ្រង់បំបែកក្រសួងមហាផ្ទៃជាបីក្រសួង : ក្រសួងមហាផ្ទៃ, ក្រសួងការពារផ្ទៃប្រទេស និង ក្រសួងសន្តិសុខជាតិ, ក្រសួងទី២ និង ទី៣ គឺទទួលបញ្ជាផ្ទាល់ពីព្រះអង្គ ហើយព្រះអង្គតែង

តែតែងតាំង អ្នកស្មោះនឹងព្រះអង្គ ឥតមានលក្ខខណ្ឌ។ គ្រប់នាយករដ្ឋមន្ត្រីតែងតាំង តែងតែ សូមឈ្មោះឥស្សរជន ពីព្រះអង្គជានិច្ច ដើម្បី បញ្ចូលក្នុងគណរដ្ឋមន្ត្រី, សូម្បីរដ្ឋាភិបាលស្រោចស្រង់ជាតិ ក៏ត្រូវប្រតិបាទត៍ តាមរាជបំណងនេះដែរ។ បួនក្រសួង ដែលសម្ដេចសីហនុ បង្ខំលោក លន់ នល់ អោយតែងតាំងមនុស្ស របស់ព្រះអង្គ គឺឧបនាយរដ្ឋមន្ត្រី (លោក អឹង ហុងសាត), ក្រសួងកិច្ចការបរទេស (ទ្រង់ នរោត្តម ភូរិសារា), ក្រសួងកសិកម្ម (លោក ជួប សៅឌី), ក្រសួងឃោសនាការ (លោក ទេព ជីវខេង), ក្រសួងការពារផ្ទៃប្រទេស (លោក វរសេនីយឯក អ៊ុំ មាណូរិន, ក្រសួងសន្តិសុខជាតិ (លោក វរសេនីយឯក សូស្ថែន ហ្វែណង់ដែស)។ ក្រសួងទាំងបួននេះ មានទំនាក់ទំនងផ្ទាល់ជាមួយខុទ្ទកាល័យព្រះប្រមុខរដ្ឋ ជួនកាលទទួលបញ្ជាផ្ទាល់ពីខុទ្ទកាល័យនេះ ដោយមិនខ្វីជូនដំណឹង ជាមុនដល់នាយករដ្ឋមន្ត្រីថែមទៀតផង, ដែលគេហៅថា ភូមិបម្រុងទុក ឬ ភូមិនយោបាយជាន់ខ្ពស់ របស់សម្ដេច ព្រះប្រមុខរដ្ឋ។ រឿងដំណាលមួយ គួរលើកមករៀបរាប់នៅទីនេះ គឺដើមគំនិត របស់លោក សូស្ថែន ហ្វែណង់ដែស ធ្វើអង្កេត លើទីតាំងទ័ពយៀកកុង នៅក្នុងដែនដីខ្មែរ។ ក្រសួង របស់លោក តែងតែទទួលសេចក្តីរាយការណ៍ ពីភ្នាក់ងារយកការណ៍អំពីសកម្មភាពពួកយៀកកុង ដែលនាំឲលោក មានដើមគំនិត ធ្វើអង្កេតជាសម្ងាត់មួយ រក

ការពិត រហូតមានលទ្ធផល គួរឲមានការបារម្ភមួយ ដល់សន្តិសុខជាតិ បើយោងតាមផែនទី នៃការតាំងទ័ពយៀកកុងនៅក្នុងដែនដីខ្មែរ។ លោក ធ្វើរបាយរាយការណ៍លម្អិតមួយ យកទៅឲមិត្តភក្តិលោក គឺ លោក អុំ មាណូរិន ដែលជារដ្ឋលេខាក្រសួងការពារផ្ទៃប្រទេស និង ជាបងប្រុស របស់អ្នកម្នាង ម៉ូនិច។ លោក អុំ មាណូរិន បានយករបាយការណ៍នេះ ទៅទូលសម្តេចសីហនុ។ ព្រះអង្គទតរួចហើយ ហើយសួរសំនួរទៅលោក អុំ មាណូរិនថា តើ សូស្ថែនយល់ដូចម្តេច ? លោក ឆ្លើយថា បើខ្មែរមានទំនាស់យោធាជាមួយពួកយៀកកុង គឺច្បាស់ជាគេ វាយយកស្រុកខ្មែរបានតែពីរបីថ្ងៃតែប៉ុណ្ណោះ ព្រោះការតាំងទីទ័ព របស់គេមានយុទ្ធសាស្ត្រ និង កលយុទ្ធយោធាច្បាស់លាស់ សំរាប់ការពារផង និង វាយលុក មកលើកងខេមរៈភូមិន្ទផង។ សម្តេចសីហនុ ព្រះអង្គយករបាយការណ៍ ប្រគល់ទៅឲលោក ឧត្តមសេនីយ ញ៉ឹក ជូឡុង នៅពេលនោះលោក ជាអគ្គសេនាធិការ នៃកងទ័ពជាតិ ដើម្បីចាត់ការ។ បន្តិចទៅ លោក ញ៉ឹក ជូឡុង បានកោះហៅលោក សូស្ថែន ហ្វែណង់ដែស ជាបន្ទាន់ អោយមកជួបលោកនៅស្រុកយាក់លោមទាំងអាប្រាត ហើយនៅក្នុងជំនួបនោះ លោក ញ៉ឹក ជូឡុង បានស្តីបន្ទោសលោក ហ្វែណង់ដែស ជាខ្លាំង រហូតប្រើពាក្យអសុរោះ ដូចយ៉ាង « ឲក្ត » ថាលោក ធ្វើកិច្ចការល្ងីល្ងើ គ្មានដឹងនយោបាយជាន់ខ្ពស់ របស់សម្តេច។

បន្ទាប់មក លោក ញឹក ជូឡុង បានបញ្ជាដល់លោក ហ្វៃណង់ដែស ថាឲលោក ដុតឯកសារ ពាក់ពន្ធនឹងរឿងនេះទាំងអស់ ហើយកុំឲនិយាយប្រាប់នរណាម្នាក់ឲសោះ។ តែសម្ដេច ព្រះអង្គ និយាយប្រាប់លោក លន់ នល់ តែមិនប្រគល់ឯកសារឲគាត់ ដែលនាំឲគាត់ បន្តូចចិត្ត ជាមួយលោក ហ្វៃណង់ដែស ក្នុងឋានៈជាចៅហ្វាយផ្ទាល់ របស់លោក ហ្វៃណង់ដែស។ ចំណែក លោក សូស្ថែន ហ្វៃណង់ដែស វិញ លោក មានអារម្មណ៍ ខកចិត្តជាច្រើន ព្រោះលោកយល់ឃើញថា កិច្ចការដែលលោកបានធ្វើនោះ វាមានប្រយោជន៏សំខាន់ណាស់ដល់ប្រទេស តែបែរជាទទួលការស្តីបន្ទោសទៅវិញ។

នៅខែកុម្ភៈ ឆ្នាំ ១៩៧០ នៅរយៈពេលដែលព្រះអង្គកំពុងស្ថិតនៅស្រុកបារាំង សម្ដេច បានអនុញ្ញាត ដោយមិនប្រាប់ជាមុនដល់រដ្ឋាភិបាល ឲយន្តហោះមួយ ដឹកថ្នាំពេទ្យសំរាប់ពួកយៀកកុង ចុះដី នៅអាកាសយានដ្ឋានពោចិនតុង នៅថ្ងៃទី១៧ កុម្ភ:។ ទង្វើនេះ ដែលតម្រូវឲលោក លន់នល់ វិលត្រឡប់មកស្រុកខ្មែរ នៅថ្ងៃទី១៨ កុម្ភ: ជាប្រញាប់ តាមសំណើរបស់ទ្រង់សិរិមត: ព្រោះទ្រង់ទុករឿងនេះ ជាកិច្ចបណ្តាលរឿងហេតុ របស់សីហនុ ចំពោះរាជរដ្ឋាភិបាល។ នៅចំពោះមុខលោក លន់ នល់ ទ្រង់សិរិមត: សួរត្រង់ៗថា តើត្រូវធ្វើដូចម្ដេច នៅចំពោះរឿងនេះ ? តើលោក លន់ នល់ ដឹងរឿងនេះដែរឬទេ ? តើ ជាការវាយ

ប្រហារនយោបាយ របស់សម្តេច ចំពោះទ្រង់ ដើម្បីឲទ្រង់ លាលែងពីតំណែង ? ចំពោះទ្រង់សិរិមត: រឿងនេះ វាមាន គប់គិត ពីសំណាក់កងទ័ពអាកាស ទើបយន្តហោះនោះ អាចចុះដីបាន ដែលនាំឲទ្រង់ គិតថា លោក លន់ នល់ លេងល្បែងពីរ ចំពោះទ្រង់។ តែលោក លន់ នល់ ធានា ភ្លាមដល់ទ្រង់សិរិមត: ថាលោក ឥតដឹងរឿងនេះឡើយ ហើយ លោក នៅមានសេចក្តីទុកចិត្តទាំងស្រុងចំពោះ ទ្រង់ ហើយនឹងត្រូវការវត្តមានទ្រង់ជាចាំបាច់នៅក្នុងរដ្ឋា ភិបាល។ អ្វីដែលទ្រង់សិរិមត:បានធ្វើ នៅពេលអវត្តមាន លោក លន់ នល់ នៅក្នុងប្រទេស លោក លន់ នល់ បញ្ជាក់ ចំពោះទ្រង់ថា គាត់យល់ព្រមទាំងអស់ គ្មានក្នុងក្រៅទេ ទោះបីកិច្ចការសំខាន់ៗខ្លះ តម្រូវឲ ទ្រង់សិរិមត: ដោះ ស្រាយភ្លាមៗ មិនចាំបាច់ សួរយោបល់លោកជាមុន។ ចម្លើយទាំងឡាយ របស់លោក លន់ នល់ ត្រូវបានបញ្ជាក់ ថាគាត់ ត្រៀមខ្លួនរួចហើយ នឹងបន្តធ្វើនយោបាយ ផ្ទុយ ពីនយោបាយជាន់ខ្ពស់ វាគ្រាន់តែរង់ចាំថា តើមានខ្មែរ អ្នកក្លាហានណា ហ៊ានឈានជើងដើរលើផ្លូវនេះ។ វាមាន គំនិតបុរាណខ្មែរពីរថា « គ្មាននរណា ទ្រាំលីទម្ងន់នគរតែ ម្នាក់ឯងបានទេ » « កុំហ៊ានពេក ប្រយ័ត្នស្លាប់ ឥត អំបិលប្រលាក់ »។ គំនិតនេះ ជាទំនៀមខ្មែរ ដែលណែនាំ ឲខ្មែរ ទ្រាំរស់នៅក្នុងទុក្ខវេទនា នៅក្នុងសង្គម ដែលមាន អ្នកដឹកនាំយោយៅ។ ព្រោះថា ទម្ងន់ នៃការភ័យខ្លាច វា

ចាក់ឫសនៅក្នុងសតិ ដែលនាំឲខ្មែរបោះបង់ចោល នូវសិទ្ធិរបស់ខ្លួន។ អ្វីដែលជានយោបាយ គឺជាកិច្ចការខ្ពង់ខ្ពស់ របស់អ្នកដឹកនាំតាំងពីបុរាណកាលមក ហើយវាជា និវារណដ្ឋាន ដែលហាមដាច់ខាត មិនឲប្រជារាស្ត្រដើរចូលជាដាច់ខាត។ អ្វីជាដែលជា ការពិភាក្សានយោបាយ អ្នកដឹកនាំ គេចាត់ទុកថាជាជម្លោះ ដែលវានាំឲបែកបាក់សាមគ្គីជាតិ ហើយន័យ នៃសាមគ្គីនេះទៀត គឺត្រូវរួមគ្នានៅជុំវិញអ្នកដឹកនាំ។ គំនិត នៃគ្រឹះជាតិ ផ្តុំទៅលើតែគំនិត នៃ « អបចាយន[73] », ដូចយ៉ាងទុកព្រះមហាក្សត្រជា « មនុស្ស-អាទិទេព »។ ទស្សនៈនេះ វានៅមានខ្លឹមសារជានិច្ចនៅក្នុងប្រជានិករ តែវាមិនមែន ស្ថិតនៅលើបដិការ[74] នៃសេចក្តីស្រឡាញ់ រវាង ព្រះមហាក្សត្រ និងប្រជារាស្ត្រ តែនៅលើ រំពាត់រាជអំណាច រៃបង្ខំឲប្រជារាស្ត្រឲទទួលស្គាល់ នូវករណីយកិច្ច របស់ខ្លួន ចំពោះព្រះមហាក្សត្រ គឺ « ស្នេហា នូវរាជទណ្ឌបត្តិ » ព្រោះប្រជារាស្ត្រ រស់នៅ រង់ចាំតែវត្ថុ តែមួយគត់ ពីព្រះមហាក្សត្រ គឺ ការសង្កិតសង្កិន។

សម្តេចសីហនុ ព្រះអង្គ ជាអវតា នៃទស្សនៈនេះឯង។ មិនតែប៉ុណ្ណោះ ព្រះអង្គយកវាមកបំបោង ដើម្បីធ្វើឲបុគ្គលព្រះអង្គ ក្លាយជា អាទិទេព តែម្តង ដូចយ៉ាងព្រះអង្គតាំង

[73] Culte de personnalité។
[74] បដិការ, ភាពមានទៅវិញទៅមក។

ខ្លួនព្រះអង្គនៅខ្ពស់ លើសពីព្រះមហាក្សត្រទៅទៀត។ ជាឧទាហរណ៍ បន្ទាប់ពីព្រះបិតា របស់ព្រះអង្គ នរោត្តមសុរាម្រិត (១៨៨៦-១៩៦០) សោយទិវង្គត នៅឆ្នាំ ១៩៦០ ព្រះអង្គ ប្រើមធ្យោបាយ ដើម្បី បំបាត់ ស្ថាប័នព្រះមហាក្សត្រ ដោយទុក រាជបល្ល័ងឲនៅទំនេរ ដើម្បីលើក ខ្លួនព្រះអង្គជាអាទិទេព ព្រោះលក្ខន្តិកៈនេះ ដែលអាចឲ ព្រះអង្គស្ថិតនៅពីលើប្រជាជាតិ។ នៅពេលនោះ ពួកអាមាត្រ របស់ព្រះអង្គនាំគ្នាបង្កើត នូវបាតុភូតគ្មានការពិត គឺ នៅពេលព្រះចន្ទពេញបូណ៌មីម្តងៗ នាំគ្នាស្រែកចង្អុលថា មានព្រះភក្ត្រព្រះសីហនុ នៅក្នុងដួងព្រះខែ, តែបើនរណាម្នាក់ថា មើលមិនឃើញ គេនាំគ្នាថា នរៈនោះ គ្មានបុណ្យនៅក្នុងខ្លួនឡើយ។ សីហនុ ព្រះអង្គមិនដែលហាមប្រាប់ប្រជារាស្ត្រ កុំឲជឿអបិយជំនឿនេះឡើយ ព្រោះ ការរក្សា នូវលទ្ធិទុកឲប្រជាករល្ងង់ ជាមូលដ្ឋាន នៃសីហនុនិយម។

មូលដ្ឋាននេះឯង ដែលជាកាំបិតមានមុខពីរ បើប្រើវាមិនប្រុងប្រយ័ត្ន វានឹងអាចមុខដៃខ្លួនឯង។ ដូច្នោះ អ្វីដែលវា នឹងអាចកើតឡើង វាមានកើតឡើង ពិតមែនចំពោះសម្តេចសីហនុ ព្រោះ របបនយោបាយ របស់ព្រះអង្គវាមកដល់ទីបញ្ចប់ ដ្បិត វាជារបបពិការ ដែលត្រូវដួលដោយខ្លួនឯង។ របបនោះ នៅពេលនោះ វាដូចជា ផ្ទះឈើចាស់មួយ ដែលមានកណ្តៀរស៊ីសសរផ្ទះខាងក្នុងស្ទើរតែអស់សាច់ឈើ ចាំតែរលំ បើមាន ខ្យល់បក់គួចចំផ្ទះ។ ខ្យល់

គួចនោះ គឺជាសមាយោគ នៃកត្តាមួយចំនួន កើតមានឡើងព្រមគ្នា : សភាជាតិ អ្នកជាតិនិយម, រដ្ឋាភិបាលស្រោចស្រង់ជាតិ និង សេចក្តីក្លាហាន របស់ឥស្សរជនមួយចំនួន ដែលហ៊ាននាំគ្នាចុះទូក ដោយមិនគិតរវល់ថានឹងត្រូវចែវឆ្លងទន្លេ នៅពេលមានព្យុះសង្ឃរា។ តើភាពមោះមុតនេះ បញ្ជាក់ពី អគតិ នៅចំពោះមុខគ្រោះថ្នាក់ដល់អាត្មា ឬ សេចក្តីក្លាហាន នៅក្នុងករណីយកិច្ច ជាកូនខ្មែរ នៅពេលប្រជាជាតិ ជួបប្រទះនឹងអាសន្ន ? តែកត្តាកំណត់ គឺ ទឹកចិត្តរឹងប៉ឹង នៃយុវជន និង អ្នកចេះដឹងខ្មែរ ទាំងប្រទេស នាំគ្នាមិនគាំទ្រ នូវជម្រើសនយោបាយរបស់ស្តេចសីហនុ ដែលផ្ទុយពីប្រយោជន៍ជាតិ។ តែនៅពេលនោះ មានទ្រង់សិរិមតៈ ដែលហ៊ានកាន់ទង់ នៃបុនក្ការ ជាអ្នកដើរមុខ នាំកម្លាំង នៃការកែទំរង់ប្រជាជាតិ។ កម្លាំងនោះគឺជា ការបូករួម នៃសេចក្តីសង្ឃឹមថ្មី នៃជីវពលសក្តិ (force vive) របស់ប្រជាជាតិខ្មែរ។ បុនក្ការ គឺការសាងសង្គមយុត្តៈ (société juste) ហើយ សង្គមយុត្តៈ គឺវាគ្មានអ្វីក្រៅពី សង្គមប្រជាធិបតេយ្យ ដែលធានា នូវសេរីភាព ដល់ប្រជាពលរដ្ឋ។ ការកែទំរង់ គឺការប្តូរ នូវការគ្រប់គ្រងជារដ្ឋ ទៅជា ការគ្រប់គ្រងជាភាគកម្ម ដែលមានការចូលរួមពីកម្លាំងសេដ្ឋកិច្ច នៃប្រជាជាតិ។ ការប្តូរនេះ វានៅចំពេលវេលា នៃការពិភាក្សាវែកញែកផ្ទុយ រវាងលោកសេរី និង លោកកុម្មុយនិស្ត ស្តីពី សេដ្ឋកិច្ចសេរី និង

សេដ្ឋកិច្ចផែនការ។ ចំពោះលោកសេរី សេរីភាពបុគ្គល និង ការប្រជែង ដែលបណ្តាលមកពីទីផ្សារចំហរ វាត្រូវតែជាមូលដ្ឋាន នៃសង្គមល្អ, រីឯ លោកកុម្មុយនិស្ត វិញ យល់ឃើញថា សង្គមល្អ អាចមានកើតបាននៅក្រោមការដឹកនាំគ្រប់វិស័យ របស់បក្សកុម្មុយនិស្ត ដែលអាចធានានូវសេរីភាពសមូហជន និង សមូហភាព។ តែគំនិត នៃការកែទំរង់នៅស្រុកខ្មែរ នៅពេលនោះ វាមិនស្ថិតនៅលើការទុកទីផ្សារចំហរ ជាអ្វីទាំងអស់ នៃសេដ្ឋកិច្ច ហើយ ទុករដ្ឋ ជាអ្វីឥតប្រយោជន៍សោះនោះឡើយ។ ទីផ្សារសេរី ត្រូវចាំបាច់ មានសិទ្ធិរដ្ឋ (pouvoir régalien) ដូចយ៉ាង មុខងារ នៃរដ្ឋ ក្នុងវិស័យការពារជាតិ, ការពារសន្តិសុខសាធារណៈ និង យុត្តិធម៌ ដើម្បី ធានា នូវការអនុវត្តន៍ នៃច្បាប់រដ្ឋ។ នៅត្រង់ចំណុចនេះឯង ដែលស្តេចសីហនុ ប្រព្រឹត្តខុសឆ្គង ដោយយក ចលនាសង្គមរាស្ត្រនិយម មកជំនួសរដ្ឋ, យកអំណាចរដ្ឋមកធ្វើជាអំណាចអញ, យកសេដ្ឋកិច្ច នៃផែនការ ជាមធ្យោបាយទោល សំរាប់ធ្វើអភិវឌ្ឍន៍ជាតិ, អនុញ្ញាតអោយ កងទ័ពយួនកុម្មុយនិស្ត មកតាំងទីទ័ពនៅក្នុងដែនសីមាខ្មែរ, និង ទុកប្រជាបាតុកម្ម ជាអំពើក្បត់នឹងប្រយោជន៍ផ្ទាល់របស់ព្រះអង្គ។ កំហុសទាំងឡាយនេះ ដែលនាំអោយកើតមានឡើង ជាឧបបាតិក[75] នូវកម្លាំង នៃការការពារជាតិ របស់ប្រជាពលរដ្ឋ ពីប្រជា

75 ឧបបាតិក, កើតមានដោយខ្លួនឯង។

ពលរដ្ឋ និង ដើម្បីប្រជាពលរដ្ឋ។ កម្លាំងនេះឯង ដែលជុំរុញអោយ រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ និង សភាជាតិមត់គ្នា ដើម្បីឆ្លើយនឹងប្រជាចំណង់ ដោយប៉ផ្ចិត[76] ស្វែងរក នូវដំណោះស្រាយរួម ជាមួយស្តេចសីហនុ តែព្រះអង្គប្រានចោល គ្មានហេតុផលត្រឹមត្រូវ នូវគ្រប់សំណើរ របស់រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលព្រះអង្គខ្លួនឯង ជាអ្នកថ្វាយនាមដូច្នឹង ដើម្បី ពង្រឹងន័យ នូវបេសកកម្ម នៃការស្រោចស្រង់ប្រជាជាតិ។ ការបដិសេធ របស់ស្តេចសីហនុ ជាការមិនអាចយល់បាន សំរាប់ជនខ្មែរទាំងឡាយ សូម្បីមាតា របស់ព្រះអង្គ ក៏មានការភ្ញាក់នោះដែរ នៅចំពោះ រាជប្រតិកម្មអវិជ្ជមាននេះ។ ប្រឈមមុខនឹងកំហុសឆ្គងនេះ លោក លន់ នល់ ដែលជាអ្នកសីហនុនិយមម្នាក់ តម្រូវឲលោក ជ្រើសរើស ផ្លូវដែលទ្រង់សិរិមតៈ ជ្រើសយក គឺមិនបណ្តោយអោយស្តេចសីហនុ ប្រើអំណាចហិង្សា របស់ព្រះអង្គ ដើម្បី បន្តបំផ្លាញជាតិដូចសព្វទៀតនោះឡើយ។ ទ្រង់សិរិមតៈ ត្រៀមខ្លួនរួចស្រេចនឹងធ្វើរដ្ឋប្រហារ ព្រោះជាមួយស្តេចសីហនុ ជាជនផ្តាច់ការ វាគ្មានមធ្យោបាយផ្សេងទៀតនោះឡើយ, តែទោះបីយ៉ាងណាទ្រង់ មិនទុកអារម្មណ៍នេះ ជាកិច្ចការផ្ទាល់ខ្លួននោះឡើយ, ដូច្នេះ ការពិគ្រោះយោបល់ ជាមួយលោក លន់ នល់ និង នយជន (le politique) សំខាន់ៗ ជាការចាំបាច់។ លោក ឧប គឹម អាង

---

[76] ដោយប៉ផ្ចិត, ដោយខំប្រឹងប្រែង, en faisant effort។

ត្រូវបានទទ្រង់សិរិមត: ស្នើអោយធ្វើការទាក់ទង ជាមួយលោក អ៊ុន តាំ ពេលនោះ ជាប្រធានរដ្ឋសភាស្តីទី ដើម្បីពិគ្រោះ អំពីបញ្ហាដែលនឹងអាចកើតមានឡើង រវាងស្តេចសីហនុ និង រដ្ឋាភិបាល[77]។ លោក អ៊ុន តាំ បានផ្តល់យោបល់ថា មិនចាំបាច់ធ្វើរដ្ឋប្រហារអ្វីទេ ព្រោះរដ្ឋសភាជាតិ គាំទ្ររដ្ឋាភិបាលគ្មានការកក់ទៅហើយ វាគ្រាន់តែរដ្ឋាភិបាល ស្នើជាផ្លូវការដល់សភាជាតិ សូមអោយដកសេចក្តីទុកចិត្ត ពីសម្តេចសីហនុ ជាព្រះប្រមុខរដ្ឋ វាដូចជាគ្រប់គ្រាន់នឹងអាចធ្វើបាន។ ការសន្និដ្ឋាន របស់លោក គឺថា ប្រើមធ្យោបាយក្តៅ វាអាចនឹងនាំ បង្កើត នូវបញ្ហាឥតប្រយោជន៍ ជាមួយសភាជាតិ ជាសម្ពន្ធមិត្តទៅវិញ

---

[77] ទំនាក់ទំនង លោក អ៊ុន តាំង និង ឧប គីម អាង ជាទំនាក់ទំនងជាញាតិផង និង ជិតស្និតនៅក្នុងកិច្ចការរាជការផង, ដូចយ៉ាង នៅរយៈពេលឆ្នាំ ១៩៤៩-៥០ លោកទាំងពីរ ត្រូវបានលោក សាន យុន ដែលជា ចារក: (អ្នកចចារ) ជាមួយលោក ដាប ឈួន ដើម្បី ស្វែងរកការចុះចូល នៃជននោះ ជាមួយស្តេចសីហនុ ប្រើជានិរសាសម្ងាត់ សំរាប់ទាក់ទងជាមួយដាប ឈួន តាមលោក អ៊ុន តាំ បារាំងនៅមានអំណាចណាស់នៅក្នុងក្រសួងសន្តិសុខ ហើយបារាំងមិនសូវចូលចិត្តលោក ដាប ឈួននោះឡើយ។ នៅពេលចចារសម្ងាត់នោះ គិញបារាំងដឹករឿងនេះ គេគំរាមដល់លោកទាំងពីរថាអោយប្រយ័ន្ទខ្លួន រហូតលោកទាំងពីរ ត្រូវលាក់ខ្លួនមួយរយ: ដើម្បី សុវត្ថិភាព ទៀតផង។ នៅត្រូវដឹងថា ទូតបារាំង ឈ្មោះលោក Pierre Gorce នៅឆ្នាំ ១៩៥៩ ជាអ្នកយកគម្រោងគំនិតក្បត់ ជាមួយនឹងភស្តុតាងផង របស់លោក ដាប ឈួន ទៅថ្វាយសម្តេចសីហនុ អោយដឹង។ សួរថាតើហេតុអ្វី បានជាបារាំងលូកដៃចូល ក្នុងកិច្ចការផ្ទៃក្នុងខ្មែរ ? ព្រោះបារាំង មិនចង់អោយស្រុកខ្មែរ ធ្លាក់ទៅក្នុងដៃសហរដ្ឋអាមេរិក ដ្បិតបារាំងយល់ឃើញថា ដាប ឈួន រៀបចំធ្វើរដ្ឋប្រហារ ដោយមាន CIA និងយួនខាងត្បូង ជាអ្នកឧបត្ថម្ភ។ នៅពេលឆែកឆេរលំនៅដ្ឋាន របស់លោក ដាប ឈួន គេឃើញមានដុំមាស ២៧០ គ.ក្រ. ដែលគេសន្មត់ថាជាជំនួយរបស់ CIA ចំពោះលោក ដាប ឈួន ដើម្បីរៀបចំអំពើក្បត់។ សួរថាតើទម្ងន់មាសនេះ វាជាភត្តុតាងគ្រប់គ្រាន់សំរាប់ចោទបុគ្គលម្នាក់ថា ជាជនក្បត់ជាតិ ជាពិសេសជននោះ ត្រូវក្រុមទាហ៊ានទៅចាប់ សម្លាប់បាត់ទៅហើយ ?

ទេ។ សួរថា តើ លោក អ៊ុន គាំ ដែលជាអ្នកសីហនុនិយម ម្នាក់ ចុះហេតុអ្វី បានជាលោក បែរគំនិត ប្រឆាំងនឹង សីហនុ រហ័សបែបនេះ ? ព្រោះនៅពេលនោះ ការប្រឆាំង នឹងវិធីដឹកនាំ របស់ស្តេចសីហនុ វាជាចរន្តនយោបាយ។ ត្រូវដឹងថា គាត់ជាអ្នកសីហនុនិយម ដូចជាឥស្សរជន ដទៃទៀតដែរ តែលោក អ៊ុន គាំ ជាអ្នកបំរើប្រយោជន៍ ជាតិ មុនអ្វីទាំងអស់ ហើយលោក តែងតែស្ម័គ្រចិត្តជា និច្ច ទទួលបេសកកម្មពិបាកៗ ដើម្បីបំរើជាតិ។ តាមចិត្ត វិទ្យា លោក អ៊ុន គាំ មាន លក្ខណៈអាកប្បកិរិយា ជាអ្នក ត្រួតត្រា (dominance) គឺថា ជាជន ចូលចិត្តប្រទល់នឹងប ញ្ហា។ មានគំនិតជាអ្នកប្រកួត តែហ៊ាន ទទួលខុសត្រូវ និង គោរព វិន័យ និង ច្បាប់ ជាដាច់ខាត។ តែងតែ កំណត់ នូវគោលដៅយ៉ាងខ្ពស់ ហើយ ចង់អោយអំណាច របស់ខ្លួន ត្រូវបានទទួលស្គាល់ពីអ្នកដទៃ។ នៅក្នុងការ ទំនាក់ទំនង ជាមួយអស់គេ តែងតែបង្ហាញ នូវប្រាស័យ ទាក់ទងផ្ទាល់ ជាវិជ្ជមាន និង គ្មានក្នុងក្រៅ រហូត ជួនកាល នាំរំខានដល់អ្នកដទៃទៅវិញ។ នៅឆ្នាំ ១៩៦៦-៦៧ លោក អ៊ុន គាំ ត្រូវបានបញ្ជាវន្តខ្មែរសេរីពីររូប មាន លោក ចៅ បូរី និង ចៅ មាធូរ៉ា ធ្វើការទំនាក់ទំនងជា សម្ងាត់ ដើម្បីសូមចុះចូល។ លោក បញ្ជូនភ្នាក់ងារ របស់ លោក ទៅចរចាជាមួយអ្នកទាំងនោះ ដើម្បី រកដំណោះ ស្រាយថា ត្រូវធ្វើបែបយ៉ាងណា តែជាអកុសល អ្នកទាំង

នោះ ត្រូវបាន ប៉ូលីសនយោបាយ របស់ស្តេចសីហនុ ចាប់បាននៅក្នុងដែនដីខ្មែរ ហើយបន្ទាប់មក ស្តេចសីហនុ បញ្ជាអោយតុលាការសឹកកាន់ទោសប្រហារជីវិត។ រឿងនេះ លោក អ៊ិន តាំ មានវិប្បដិសារីជានិច្ច ព្រោះលោក យល់ឃើញថា អ្នកទាំងនោះ មានការប្រហែសខ្លួន ដោយសារគេទុកចិត្តមកលើលោកខ្លាំងណាស់ បានជានាំគ្នាចាញ់បោកគេ។ លោក អ៊ិន តាំ តែងតែនិយាយរឿងនេះ ចំពោះមិត្តភក្តិលោកថា នៅពេលលោកទៅបរលោក ព្រលឹងលោក ច្បាស់ជារីងខ្លួនណាស់ នៅចំពោះមុខព្រលឹងអ្នកទាំងពីរនោះ។ ក្នុងរឿងនេះដែរ លោក អ៊ិន តាំ យល់ឃើញថា ស្តេចសីហនុ ដឹងរឿងនេះតាំងពីដើមទីមក ហើយព្រះអង្គ លេងល្បែងទ្វេដង ជាមួយលោក ហើយ ប្រហែលជាព្រះអង្គ កំពុងលេងល្បែងនេះដដែល ជាមួយ លោក លន់ នល់ ដូចលោក តែងតែនិយាយថា បេសកកម្ម ដែលសម្តេចសីហនុ ប្រគល់អោយ រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ មានតែមួយគត់ គឺពង្រឹងការ ទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក តែព្រះអង្គ សាបព្រួស នូវសំដី មានភាពមិនច្បាស់លាស់ ជាមួយលោក លន់ នល់ ថា នយោបាយជាមួយយួនកុម្មុយនិស្ត ត្រូវតែសើររើ មើលឡើងវិញជាដាច់ខាត។ ចំពោះលោក អ៊ិន តាំ ការ មិនច្បាស់លាស់នេះឯង ដែលជាកត្តាមួយដែរ បង្កើតនូវព្រឹត្តិការណ៍ថ្ងៃទី១៨ មីនា។ ការខ្វះសេចក្តីទុកចិត្តទៅលើ

ស្តេចសីហនុនេះឯង ដែល លោក អ៊ិន តាំ សម្រេចចិត្ត ចូលរួមជាមួយលោក លន់ នល់ និង ទ្រង់សរិមតៈ ទម្លាក់ សម្តេចសីហនុ ពីតំណែង ដោយប្រើវិធី រដ្ឋប្រហារស្រប ច្បាប់នោះឯង។ រដ្ឋប្រហារ គឺត្រូវធ្វើយ៉ាងណា ទម្លាក់ស្តេច សីហនុ ជាដាច់ខាត ព្រោះជាប្រយោជន៏ជាតិ, ស្របច្បាប់ គឺយកច្បាប់មកអនុវត្តិ ព្រោះជាអំពើអហិង្សា និង មាន សភាជាតិ ជាអ្នកសម្រេច តាមការស្នើរបស់រដ្ឋាភិបាល ព្រោះជាមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យ។ ពេលនោះវា អាចធ្វើបាន ព្រោះ សភាជាតិ និង រដ្ឋាភិបាល ដើរលើផ្លូវ ស្រោចស្រង់ជាតិប្រជួសគ្នា ហើយផ្លូវនេះ វាប្រគប់គ្នា រួចវា នាំទៅរក ការប្រជល់នឹងនយោបាយ របស់សម្តេចសីហនុ។

## មានបន្ត ក្នុងភាគទី៣